ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ទស្សនៈការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះ វិស័យអប់រំថ្នាក់រាជធានី ខេត្ត

The Perception of Provincial Joint Technical Working Group Implementation (P-JTWG)

ដោយ/By

លោក ទឹម ពិន្ទុ

TOEM PENTUK

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**
National Institute of Education

# និក្ខេបបទ

# ទស្សនៈការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះ វិស័យអប់រំថ្នាក់រាជធានី ខេត្ត

## The Perception of Provincial Joint Technical Working Group Implementation (P-JTWG)

ដោយ/By

**លោក ទឹម ពិន្ទុ**

TOEM PENTUK

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**
**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេស៖ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ ឯកឧត្តម លីម សុធា**
**សាស្ត្រាចារ្យដឹកនាំរង៖ លោក ឡុច ចាន់ថន**

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា
Supported by Cambodia International Education Support Foundation ( CIESF )

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ខ៣

(**ភារសម្ងាត់**)

### លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុជន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ ៤

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ទឹម ពិន្ទុ**

សូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវស្តីពី«**ទស្សនៈការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត** (The Perception of Provincial Joint Technical Working Group Implementation)»ខាងលើសម្រាប់បំពេញលក្ខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦នៃវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ចំពោះប្រធានបទនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅតាមបណ្តាសាកលវិទ្យាល័យ និងវិទ្យាស្ថាន ឬវិទ្យាស្ថានមានតម្លៃស្មើណាមួយនៅឡើយទេ។ ចំពោះសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយដែលបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ត្រូវបានការអនុញ្ញាតពីអ្នកនិពន្ធឬចុះបញ្ជីឯកសារយោង។ ក្នុងន័យនេះ និក្ខេបបទស្រាវជ្រាវ ខាងលើពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទផ្ទាល់ប្រាកដមែន។

ថ្ងៃទី ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ទឹម ពិន្ទុ**

# ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ខ្ញុំជាសាស្ត្រាចារ្យដឹកនាំ បានឃើញ និងឯកភាពថាការសរសេរនិក្ខេបបទស្រាវជ្រាវខាងលើពិតជារបស់លោក **ទឹម ពិន្ទុ** ពិតប្រាកដមែន។

ថ្ងៃទី ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០១៩

**សាស្ត្រាចារ្យដឹកនាំ** **សាស្ត្រាចារ្យដឹកនាំរង**

...................................... ......................................

**ឯកឧត្តម លឹម សុធា** **ឡុច ចាន់ថន**

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំសម្រាប់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់មានឱកាសបន្តការសិក្សាដើម្បីបង្កើនគុណវុឌ្ឍិបន្ថែម ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទ បានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមរំលឹកគុណជូនចំពោះអ្នកមានគុណទាំងពីរ លោកឪពុក អ្នកម្តាយ ព្រមទាំងភរិយានិងបងប្អូនទាំងអស់ដែលជានិច្ចកាលផ្តល់កំលាំងចិត្ត ពេលវេលា និងការគាំទ្រនានាដល់រូបខ្ញុំគ្រប់កម្រិតសិក្សាទាំងអស់ជាពិសេសក្នុងការសិក្សា និងការស្រាវជ្រាវមួយនេះ ពិតណាស់ការជួយឧបត្ថម្ភគាំទ្ររបស់អ្នកទាំងអស់គ្នាពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់រូបខ្ញុំដោយមិនគិតពីការលំបាក និងពេលវេលាដ៏មានតម្លៃ។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណ ចំពោះសាស្ត្រាចារ្យដឹកនាំ ឯកឧត្តម **លីម សុឆា** និងសាស្ត្រាចារ្យដឹកនាំរង **ឡុច ចាន់ថន** បានចំពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ និងណែនាំរៀបចំនិក្ខេបបទនេះតាំងពីដើមរហូតដល់ចប់ប្រកបដោយជោគជ័យ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់មិត្តរួមថ្នាក់រួមជំនាន់ទាំងអស់ដែលតែងតែផ្តល់កំលាំងចិត្តដល់រូបខ្ញុំទាំងក្នុងការសិក្សា និងការសិក្សាស្រាវជ្រាវកន្លងមក។

ជាទីបញ្ចប់ ខ្ញុំបាទ សូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូ និងញាតិមិត្តទាំងអស់ សូម ឱ្យមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន និងជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបានពុទ្ធពរ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

សូមអរគុណ

# មូលន័យសង្ខេប

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសម្រុះវិស័យអប់រំថ្នាក់រាជ ធានីខេត្ត គឺជាការសិក្សាស្វែងយល់ពីទស្សនៈយល់ឃើញរបស់សមាជិក នៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត(P-JTWG)ដោយផ្ទាល់នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្តគោលដៅសម្រាប់ឆ្នាំ ២០១៧ ដល់២០១៩ ដែលមានការិយាល័យផែនការ និងគ្រប់គ្រងជំនួយជាលេខាធិការដ្ឋាន។ អ្នកស្រាវជ្រាវបានកំណត់គោលដៅសមាសភាពនៃសមាជិកនីមួយៗសម្រាប់ប្រមូលទិន្នន័យ មានដូចជា៖ លេខាធិការដ្ឋានជាអ្នកដឹកនាំដំណើរការក្រុមការងារនេះ ការិយាយល័យពាក់ព័ន្ធនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុមការងារវិស័យអប់រំ(P-ESWG) មន្ទីរវិស័យពាក់ព័ន្ធក្នុងខេត្ត និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីជាធាតុចូលសម្រាប់បង្ហាញពីយន្តការប្រតិបត្តិកន្លងមក បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរឬអនុសាសន៍។ ក្នុងនោះ ការសិក្សាស្រាវជ្រាវធ្វើឡើងទាំងបរិមាណវិស័យ និងគុណវិស័យ ដោយបានប្រមូលទិន្នន័យ និងវិភាគក្នុងប្រព័ន្ធកុំព្យូទ័រ។

ការសិក្សានេះត្រូវបានជ្រើសរើសមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន១៣នៃ២៥រាជធានីខេត្ត រួមមាន៖ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពត ព្រះសីហនុ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ ស្ទឹងត្រែង និងស្វាយរៀង។ ដើម្បីសិក្សាសន្និដ្ឋានជារួមទូទាំង២៥រាជធានីខេត្ត សរុបអ្នកចូលរួមឆ្លើយកម្រងសំណួរ និងសម្ភាសន៍មាន១៣៩រូបដែលមានតួនាទីចាប់ពីថ្នាក់ដឹកនាំមន្ទីរ លេខាធិការដ្ឋាន ប្រធាន/អនុប្រធានការិយាល័យ ប្រធាន/អនុប្រក្រុមការងារវិស័យអប់រំជាតំណាងអង្គការដៃគូអភិវឌ្ឍ ប្រធាន/អនុប្រធានឬតំណាងមន្ទីរវិស័យ និងមន្ត្រីទទួលបន្ទុកដោយផ្តោតលើ៖ ១)យន្តការនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ រួមមាន៖ ដំណើរការមុនកិច្ចប្រជុំ ដំណើរការកំឡុងពេលកិច្ចប្រជុំ និងដំណើរការក្រោយកិច្ចប្រជុំ ២)បញ្ហាប្រឈមនិងដំណោះស្រាយ ៣)សំណូមពរ/អនុសាសន៍ និង៤)ការសម្ភាសន៍។

លទ្ធផលនៃការសិក្សា អ្នកស្រាវជ្រាវបានប្រើប្រើប្រាស់ព័ត៌មានដែលបានបំពេញតាមកម្រងសំណួរទាំង១៣៩ និងបានបញ្ចូលមតិយោបល់ដែលពួកគាត់បានឆ្លើយដើម្បីធានាបានថាការវិភាគមានលក្ខណៈសមស្របឆ្លើយតបនឹងសំណួរស្រាវជ្រាវ។

ជាងចុងក្រោយ លទ្ធផលនៃការសិក្សានេះនឹងរួមចំណែកដ៏សំខាន់ក្នុងការផ្តល់នូវព័ត៌មានពីវឌ្ឍនភាពនៃការអនុវត្តនិងជាមូលដ្ឋានសម្រាប់កែលម្អលើចំណុចខ្វះខាត និងជាឯកសារពិគ្រោះសម្រាប់សិក្សាបន្តទៀត។

# Abstracts

The operation of Provincial Joint Technical Working Group (P-JTWG) is a study research of any views of P-JTWG members directly in targeted PoEs in the past three years (2017 to 2019), the planning office of PoEs is the secretary. For the targeted member responded the questionnaires including a secretariat, the relevant offices of PoEs, P-ESWG, the relevant provincial departments and stakeholders. They are inputs to express the past implementation, challenges, solutions or suggestions or recommendations. Another hands, the researchers were conducted both quantity and quality, as well as, they're analyzed in computer programs.

The research was selected 13 of 25 PoEs included Battambang, Banteay Meachey, Kampong Chnange, Pursat, Kampong Speu, Kampot, Preach Sihanauk, Kampong Thom, Preach Vihear, Odor Meanchey, Kratie, Stung Treng, and Svay Reang. They were stand for 25 PoEs and making overall conclusion. Total of respondents was 139, who were the leadership of PoEs as P-JTWG chair, chief of planning office as secretariat, chief of P-ESWG as development partners/NGOs presentative, and some chief of provincial departments, and technical staff. The processing focused on: 1) The mechanism of P-JTWG such as the pre-meeting process, the meeting process, and the post-meeting process, 2) the challenges and solutions, 3) suggestions /recommendations and 4) interviews.

The results of this research, it was used all most data of respondents in 139 questionnaire handouts and ideas, which entered in SPSS data analysis to ensure these analyzing responded to the research questions.

Finally, it would make a significant contribution to a piece of basic information of the implementation and improvement of the shortage things and it will be references further study.

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ....... i
ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ....... ii
សេចក្តីថ្លែងអំណរគុណ.......iii
មូលន័យសង្ខេប ....... iv
មាតិកា ....... 6
បញ្ជីអក្សរកាត់/ ACRONYMS AND ABBREVIATIONS.......9

## ជំពូកទី១
## សេចក្តីផ្តើម

១.១. សាវតារ.......11
១.២. លំនាំបញ្ហានៃការស្រាវជ្រាវ.......12
១.៣. គោលបំណងនៃការស្រាវជ្រាវ .......15
១.៤. សំណួរស្រាវជ្រាវ.......15
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ .......15
១.៦ ដែនកំណត់នៃការស្រាវជ្រាវ.......16
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......16

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១. ពន្យល់ពាក្យ .......18
២.២. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះ?.......22
២.៣. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ?.......23
២.៤. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត?.......24
២.៥. គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារ .......26
២.៥.១.អាទិភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ .......27
២.៥.២. សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ .......28
២.៥.៣. ភារកិច្ច និងការទទួលខុសត្រូវ .......29

## ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

៣.១. វិធីសាស្ត្រស្រាវជ្រាវ ....................32
៣.២. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....................33

## ជំពូកទី៤

## លទ្ធផលនៃការស្រាវជ្រាវ

៤.១. ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ....................35
៤.១.១. ការពិគ្រោះយោបល់....................35
៤.១.២. របៀបវារៈបានស្នើ ....................36
៤.១.៣. ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ....................36
៤.២. ការកំណត់កាលបរិច្ឆេទកិច្ចប្រជុំ....................37
៤.៣. នីតិវិធីកំណត់របៀបវារៈសម្រាប់កិច្ចប្រជុំ ....................38
៤.៣.១. ការពិនិត្យលើផ្នែកពាក់ព័ន្ធ ....................38
៤.៣.២. ការពិគ្រោះយោបល់ ....................39
៤.៣.៣. ខ្លឹមសាររបៀបវារៈ....................39
៤.៣.៤. វិស័យពាក់ព័ន្ធនឹងរបៀបវារៈ....................40
៤.៣.៥. ប្រធានបទនៃរបៀបវារៈ....................41
៤.៤. ការសម្របសម្រួលរបស់លេខាធិការដ្ឋាន....................41
៤.៥. ការរៀបចំបទបង្ហាញក្នុងកិច្ចប្រជុំ....................42
៤.៦. ការដំណើរការកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ....................43
៤.៦.១. ចំនួនកិច្ចប្រជុំប្រចាំឆ្នាំ....................44
៤.៦.២. ការដឹកនាំកិច្ចប្រជុំ ....................44
៤.៦.៣. ការចូលរួមកិច្ចប្រជុំ ....................45
៤.៦.៤. ការផ្តល់យោបល់របស់សមាជិកក្នុងកិច្ចប្រជុំ....................46
៤.៦.៥. ការរៀបចំរបាយការណ៍កិច្ចប្រជុំ ....................47
៤.៧. បញ្ហាប្រឈមដែលកើតមាន ....................49
៤.៨. ដំណោះស្រាយ....................50
៤.៩. សំណូមពរ ....................50

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ .សេចក្តីសន្និដ្ឋាន....................................................................................................53
៥.២.សំណូមពរ...................................................................................................................57

ឯកសារយោង.....................................................................................................................59

ឧបសម្ព័ន្ធទី១.....................................................................................................................60

ឧបសម្ព័ន្ធទី២ ...................................................................................................................80

ឧបសម្ព័ន្ធទី៣ ...................................................................................................................88

## បញ្ជីអក្សរកាត់/ ACRONYMS AND ABBREVIATIONS

| | |
|---|---|
| CDC | Council for the Development of Cambodia ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| JTWG-Edu | Joint Technical Working Group for Education<br>ក្រុមការងារបច្ចេកទេសចម្រុះវិស័យយអប់រំថ្នាក់ជាតិ |
| P-JTWG | Provincial Joint Technical Working Group for Education<br>ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត |
| ILO | International Laboure Organization អង្គការពលកម្មអន្តរជាតិ |
| GDCC | Government-Donor Coordination Committee<br>គណៈកម្មាធិការកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល |
| UNESCO | The United Nations Educational, Scientific and Cultural Organization<br>អង្គការសហប្រជាជាតិសម្រាប់អប់រំ វិទ្យាសាស្រ្ត និងវប្បធម៌ |
| ESWG | Education Sector Working Group ក្រុមការងារវិស័យអប់រំ |
| P-ESWG | Provincial Education Sector Working Group<br>ក្រុមការងារវិស័យអប់រំថ្នាក់រាជធានីខេត្ត |
| NEP | NGOs Education Partnership ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| MoEYS | Ministry of Education, Youth and Sport<br>ក្រសួងអប់រំ យុវជន និងកីឡា |
| ESP | Education Strategic Plan<br>ផែនការយុទ្ធសាស្រ្តវិស័យអប់រំ |
| AOP | Annual Operational Plan<br>ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| PoE | Provincial of Education department<br>មន្ទីរអប់រំ យុវជន និងកីឡា |
| DoE | District of Education  office<br>ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ |
| PoD | Provincial of Department មន្ទីរវិស័យរាជធានី ខេត្ត |

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះក្នុងឆ្នាំ២០០៤ សម្រាប់យន្តការក្នុងការសម្របសម្រួល និងពិគ្រោះយោបល់។ តំណាងក្រសួង និងស្ថាប័ន្ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលបានចូលរួមបំពេញការងារក្នុងយន្តការនេះ ដើម្បីឈានទៅអនុវត្តឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដែលបានបែងចែកក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។ ផ្អែកតាមសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ដែលរាជរដ្ឋាភិបាលបានដាក់អនុវត្តនៅឆ្នាំ២០១០ រហូតមកដល់បច្ចុប្បន្ន(*សេចក្តីសម្រេច រាជរដ្ឋាភិបាល លេខ ៦៨សសរ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩*)។

គោលដៅចំបងនៃក្រុមការងារបច្ចេកទេសចម្រុះនេះគឺ គាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីៈ ១)អនុវត្តផែនការតាមអនុវិស័យ និងការដ្ឋានកែទម្រង់ ២)កៀរគរ និងសម្របសម្រួលការប្រើប្រាស់ធនធានទាំងអស់ និង៣)សម្រេចឱ្យបាននូវលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ក្នុងគោលដៅគ្រប់គ្រងធនធានទាំងអស់ ដើម្បីឈានទៅសម្រេចនូវអាទិភាពដែលបានចែងក្នុងយុទ្ធសាស្ត្រ និងផែនការជាតិ និងតាមវិស័យ។ ដើម្បីបន្តជម្រុញប្រសិទ្ធភាពឱ្យកាន់តែខ្ពស់ ក្រុមការងារបច្ចេកទេសច្រុះនីមួយៗត្រូវពិនិត្យ និងកែសម្រួលជាប្រចាំអំពីរបៀបរបបស្តីពីភាពជាដៃគូដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចនូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍។ ការពិនិត្យឡើងវិញអំពីប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះបានរំលេចអំពីឧត្តមានុវត្តន៍ និងបញ្ហាប្រឈមមួយចំនួនដែលជិះឥទ្ធិពលដល់លទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះក្នុងការសម្រេចគោលដៅទាំងនេះ។ ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ គឺជាអង្គភាពសម្រាប់ផ្តល់ការគាំទ្រ និងកិច្ចសម្របសម្រួល ហើយមិនមែនបង្កើតឡើងដើម្បីធ្វើការជំនួសឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួង និងស្ថានប័នសាមីឡើយ។ ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានគណនេយ្យភាពចំពោះក្រសួង និងស្ថាប័នរបស់ខ្លួន(*សេចក្តីសម្រេច រាជរដ្ឋាភិបាល លេខ៦៨សសរ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩*)។

ចំពោះក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ជំរុញវិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសទៅដល់មូលដ្ឋានផ្ទាល់តាមការធ្វើវិមជ្ឈការទៅដល់ថ្នាក់ក្រោមជាតិដែលជាអ្នកនុវត្តផ្ទាល់ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ(JTWG-Ed)បានបង្កើតឡើងដោយ

ផ្អែកលើសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)កាលពីខែតុលា ឆ្នាំ២០១០ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៨សសរ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០។ ជាមួយគ្នានោះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ(រាជធានីខេត្ត) បានបង្កើតឡើងយោងតាមសេចក្តីណែនាំលេខ ០៤ អយក.សណន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ របស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តទាំងអស់ឱ្យបង្កើតក្រុមការងារបច្ចេកទេសរបស់ខ្លួន និងដាក់ឱ្យដំណើរប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ គោលបំណងរួមនៃក្រុមការងារបច្ចេកទេសចម្រុះរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ឬហៅថាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ ដែលមានសមាសភាពសមាជិកក្រុមការងារមកពីការិយាល័យពាក់ព័ន្ធនៃមន្ទីរអ.យ.ក តំណាងដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល និងមន្ទីរពាក់ព័ន្ធនានា គឺសំដៅលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក៏ដូចជាអ្នកដែលមានការពាក់ព័ន្ធទាំងអស់។ ទន្ទឹមនឹងនោះក៏មានបញ្ហាប្រឈមមួយចំនួនលើដំណើរការរៀបចំកិច្ចប្រជុំ យន្តការសម្របសម្រួល និងការសចូលរួមរបស់សមាជិក និងលទ្ធផលនៃកិច្ចប្រជុំជាដើម ហាក់ដូចជានៅមានកម្រិតដែលទាមទារឱ្យក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាដៃគូអភិវឌ្ឍន៍ ផ្នែកពាក់ព័ន្ធចូលរួមដោះស្រាយទាំងអស់គ្នា។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ចាប់ពីឆ្នាំ២០១៧-២០១៩ ពាក់ព័ន្ធនឹងដំណើរការប្រជុំក្រុមការងារនេះទាំង២៥រាជធានីខេត្តនៅមានកម្រិតនៅឡើយ និងបញ្ហាប្រឈមមួយចំនួនត្រូវការចូលរួមដោះស្រាយគ្រប់ផ្នែកពាក់ព័ន្ធ។

## ១.២. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំគឺ ជាយន្តការប្រជុំពិភាក្សាពិគ្រោះយោបល់កម្រិតនយោបាយ និងកម្រិតបច្ចេកទសដ៏មានសារៈសំខាន់ក្នុងការលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងការកៀរគរធនធាន និងបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍វិស័យអប់រំនៅមូលដ្ឋាន តាមរយៈដំណើរការកិច្ចប្រជុំនីមួយៗដែលត្រូវបានរៀបចំឡើងជាប្រចាំត្រីមាស(៤ត្រីមាសក្នុងមួយឆ្នាំ)សម្រាប់មន្ទីរអប់រំ យុវជន និងកីឡាទូទាំង២៥រាជធានីខេត្តប្រតិបត្តិ។ ក្រុមការងារនេះបានបង្ហាញពីវឌ្ឍនភាព និងលទ្ធផលដែលកើតចេញពីយន្តការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កានៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដោយឡែកមន្ទីររាជធានីខេត្តមួយចំនួនមិនទាន់បានដំណើរក្រុមការងារនេះពេញ

លេញនៅឡើយ និងមានបញ្ហាប្រឈមនានាជាច្រើនបង្កដល់ការរាំងស្ទះនៃដំណើរការក្រុមការងារនេះ។

ការពិនិត្យឡើងវិញវឌ្ឍនភាពដំណើរក្រុមការងារនេះ និងបញ្ហាប្រឈមក្នុងឆ្នាំ២០១៧ ដល់២០១៩ បានបង្ហាញថា៖

ក.ដំណើរការកិច្ចប្រជុំ




(ប្រភព៖នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា២០១៧-២០១៩)

- ឆ្នាំ២០១៧ រាជធានី ខេត្ត បានដំណើរការប្រជុំ មាន ១៨ ខេត្ត/២៥រាជធានីខេត្ត ស្មើ ៧២%
- ឆ្នាំ២០១៨ រាជធានី ខេត្ត បានដំណើរការប្រជុំ មាន ១៦ ខេត្ត/២៥រាជធានីខេត្ត ស្មើ ៦៤%
- ឆ្នាំ២០១៩ រាជធានីខេត្ត បានដំណើរការប្រជុំ មាន ២១ ខេត្ត/២៥រាជធានីខេត្ត ស្មើ ៨៤%
- កិច្ចប្រជុំជាអតិបរមា ៤ដងក្នុង១ឆ្នាំ មាន៤ខេត្តដែលសម្រេចបានក្នុងឆ្នាំ២០១៩ ស្មើ១៦.៦%។

ខ. បញ្ហាប្រឈម៖

| ឆ្នាំ | បញ្ហាប្រឈម |
|---|---|
| ២០១៧ | - កម្រិតយល់ដឹងនៃសមាជិកពីសារសំខាន់ និងតួនាទីរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ<br>- កាផ្លាស់ប្ដូរសមាសភាព និងការចូលរួមពីភាគីពាក់ព័ន្ធនៃក្រុមការងារ<br>- សមត្ថភាពក្នុងការសម្របសម្រួលរបស់លេខាធិការដ្ឋានលើការរៀបចំកិច្ចប្រជុំឱ្យមានប្រសិទ្ធិភាព<br>- ភាពមមាញឹករបស់សមាជិកក្រុមការងារ<br>- ការពិនិត្យតាមដាន និងវាយតម្លៃទៅលើការអនុវត្តចំណុចដែលបានសម្រេចក្នុងកិច្ចប្រជុំលើកមុន |

| | |
|---|---|
| | - ថវិកាសម្រាប់ដំណើរការប្រជុំ |
| ២០១៨ | - ការប្រជុំមិនតាមផែនការសកម្មភាពប្រចាំឆ្នាំ<br>- ការសម្របសម្រួលរបស់លេខាធិការដ្ឋានជួបការលំបាកច្រើន<br>- ខេត្តមួយចំនួនមិនទាន់ធ្វើបច្ចុប្បន្នភាពក្រុមការងារ<br>- ការកំណត់របៀបវារៈ (ការពិភាក្សា ចំនួន ភាពពាក់ព័ន្ធ រយៈពេល)<br>- កិច្ចសហការរវាងមន្ទីរពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សម្រាប់វិស័យអប់រំ<br>- ការផ្តល់ធាតុចូលពីផ្នែកពាក់ព័ន្ធ<br>- ថវិកាសម្រាប់ដំណើរការប្រជុំ<br>- សមាសភាពក្រុមការងារP-JTWG ពុំមានសិទ្ធិសម្រេច ឬផ្តល់យោបល់ជាផ្លូវការជូនអង្គប្រជុំ<br>- សមាសភាពចូលរួមមិនគ្រប់គ្រាន់ និងមិនមែនជាសមាជិកក្រុមការងារ<br>- ការកំណត់ពីតួនាទី និងការទទួលខុសត្រូវនៃក្រុមJTWGតាមសេចក្តីណែនាំលេខ០៤មិនទាន់ច្បាស់លាស់<br>- សមត្ថភាពនៃក្រុមលេខាធិកាដ្ឋាន លើការងារសម្របសម្រួល និងរៀបចំរបាយការណ៍<br>- ប្រសិទ្ធភាពនៃការអនុវត្តក្រោយស្មារតីកិច្ចប្រជុំ |
| ២០១៩ | - ការរៀបចំផែនការសកម្មភាពមានតែពីភាគីមន្ទីរអយក និងក្រុមការងារវិស័យអប់រំ<br>- ការប្រជុំមិនតាមផែនការសកម្មភាពប្រចាំឆ្នាំ<br>- ភាពមមាញឹកនឹងការងាររបស់លេខាធិការដ្ឋាន<br>- សមត្ថភាពលេខាធិការដ្ឋានទាក់ទងនឹងការសម្របសម្រួល និងការរៀបចំរបាយការណ៍<br>- សមាសភាពចូលរួមប្រជុំមិនមែនជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះ<br>- ពុំទាន់មានកម្មវិធីពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តតាមស្មារតីអង្គប្រជុំ |

(ប្រភព៖ នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា ២០១៧-២០១៩)

ការវាយតម្លៃលទ្ធផលនៃមូលនិធិភាពជាដៃគូដើម្បីអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំដំណាក់កាលទី១ និងទី២នៅកម្ពុជាបានបង្ហាញថាការសម្របសម្រួលក្នុងវិស័យអប់រំបានរីកចម្រើន ដែលរួមចំណែកដល់ប្រសិទ្ធិភាពប្រសើរនៃអន្តរាគមន៍កសាងសមត្ថភាពអប់រំនានា ជាពិសេស ភាពដឹកនាំ របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ គឺខ្លាំងដែលរួមចំណែកដល់ការអភិវឌ្ឍ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយ និងកម្មវិធីនានា។ ដោយឡែក ថ្នាក់រាជធានី ខេត្តមានបទពិសោធន៍ក្នុងការសម្របសម្រួល ក្នុងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជនីខេត្ត ប៉ុន្តែក្រុមការងារនេះមិនសុទ្ធតែដំណើរការពេញលេញនោះទេ។ នៅថ្នាក់ស្រុកការសម្របសម្រួលគឺនៅតែមានតិចតួច។ ការប្រឈមនៃការសម្របសម្រួលនៅតែមានរវាងនាយកដ្ឋានបច្ចេកទេសផ្សេងៗនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងផ្សេងៗ ឧទាហរណ៍នៅក្នុងក្របខណ្ឌនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការជាតិ។ ក្រុមការងារបច្ចេកទេសចម្រុះថ្នាក់ខេត្តមួយចំនួនមិនទាន់ដំណើរការពេញលេញនៅឡើយ

ទេ ហើយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តត្រូវការសមត្ថភាពបន្ថែមទៀតដើម្បីឆ្លើយតប ទៅនឹងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធចម្រុះនៅថ្នាក់រាជធានីខេត្ត *(របាយការណ៍វាយតម្លៃលទ្ធផល CDPF Phase I & Phase II, Unicef ប្រចាំកម្ពុជាខែមេសា ឆ្នាំ២០១៨)*។

ដូចនេះ អ្នកស្រាវជ្រាវសង្កេតឃើញថាដំណើរការ និងបញ្ហាប្រឈមដែលបានលើកឡើង ខាងលើស្របពេលដែលក្រសួងអប់រំ យុវជន និងកីឡាន និងដៃគូអភិវឌ្ឍន៍ រួមទាំងផ្នែកពាក់ព័ន្ធ នៅតែកំពុងជំរុញ និងគាំទ្រយន្តការនេះដល់ថ្នាក់ក្រោមជាតិ ប៉ុន្តែបើពិនិត្យពីដំណើរក្រុមការងារ នេះពីមួយឆ្នាំទៅមួយឆ្នាំ ហាក់ដូចជាមិនទាន់មានភាពល្អប្រសើរតាមអ្វីដែលក្រសួងបានកំណត់ ក្នុងសេចក្តីណែនាំនៅឡើយ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមិនទាន់ត្រូវ បានអ្នកស្រាវជ្រាវពីមុនលើកយកមកសិក្សានៅឡើយ ជាហេតុជំរុញឱ្យអ្នកស្រាជ្រាវជ្រើសរើស ប្រធានបទនេះឡើងដើម្បីសិក្សាឱ្យកាន់តែស៊ីជំរៅលើកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ដំណើរកិច្ច ប្រជុំ និងការឆ្លុះបញ្ចាំងពីផ្នែកពាក់ព័ន្ធសម្រាប់ធ្វើការកែលម្អឱ្យប្រសើរឡើងដល់ដំណើរកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ និងរក្សានូវយន្តការនេះឱ្យជានាបាននិរន្តរភាពប្រកប ដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងសិក្សាលើ៖

- យន្តការនៃដំណើរកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត និង
- បញ្ហាប្រឈម និងដំណោះស្រាយដែលកើតមាន។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងខាងលើ អ្នកស្រាវជ្រាវបានលើកយកសំណួរស្រាវជ្រាវចំនួន ពីរដែលឆ្លើយតបមានដូចខាងក្រោម៖

១. តើយន្តការនៃដំណើរការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត យ៉ាងណាខ្លះ?

២. តើក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តមានបញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ/អនុសាសន៍អ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាលើប្រធានបទនេះ នឹងរួមចំណែកយ៉ាងសំខាន់ដើម្បីផ្តល់ជាធាតុ ចូលដើម្បីជាមូលដ្ឋានរកចំណុចត្រូវកែលម្អ ដំណោះស្រាយ និងយុទ្ធសាស្ត្រសមស្រប ម្យ៉ាងវិញ ទៀតជាផែនទីបង្ហាញផ្លូវសម្រាប់តម្រង់ទិស ការអនុវត្តនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ថ្នាក់រាជធានីខេត្តឱ្យកាន់ល្អប្រសើរ និងមានប្រសិទ្ធភាព សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ជា ពិសេសមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តទាំង២៥។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅតាមបណ្ដាមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន១៣ ក្នុងចំណោមមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តចំនួន២៥ ដើម្បីធ្វើការសិក្សាពីទស្សនៈដោយផ្ដោតលើយន្តការនៃការអនុវត្តក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំរយៈពេលបីឆ្នាំកន្លងមក (២០១៧-២០១៩) និងបញ្ហាប្រឈម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកជា ៥ជំពូក ដូចខាងក្រោម៖

១. **ជំពូកទី១ សេចក្ដីផ្ដើម៖** សាវតា លំនាំបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

២. **ជំពូកទី២ រំលឹកទ្រឹស្ដី៖** ផ្ដោតលើ ពន្យល់ពាក្យ អ្វីជាក្រុមការងារបច្ចេកទេសចម្រុះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្ត គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ រួមមាន៖ ការងារអាទិភាពសមាស និងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។

៣. **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យសំណាក និងការ ការកំណត់ទំហំ និងដែនកំណត់នៃសំណាក និងឧបករណ៍វិភាគទិន្នន័យ។

៤. **ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ៖** អ្នកស្រាវជ្រាវធ្វើការបង្ហាញពីលទ្ធផលវិភាគសំណាកដែលបានឆ្លើយតាមកម្រងសំណួរ។

៥. **ជំពូកទី៥ សេចក្ដីសន្និដ្ឋាន និងសំណូមពរ៖** អ្នកស្រាវជ្រាវបានសំយោគខ្លឹមសារនៃលទ្ធផលស្រាវស្រាវដើម្បីធ្វើការសន្និដ្ឋានជារួមក្នុងការកំណត់បានជាយន្តការ បញ្ហាប្រឈម និងសំណូមឱ្យឆ្លើយតបនឹងសំណួរស្រាវជ្រាវដែលបានកំណត់សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំធ្វើជាមូលដ្ឋានសម្រាប់ពិភាក្សានិងពិចារណាកែលម្អការប្រតិបត្តិឱ្យកាន់តែប្រសើរ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

## រំលឹកទ្រឹស្តី

### ២.១. ពន្យល់ពាក្យ

បើតាមវចនានុក្រមខ្មែរ (ព្រះសង្ឃរាជ ជួន ណាត, ១៩៦៧) ៖ ១)«ការប្រតិបត្តិ»គឺមកពីពាក្យ« បដិបត្តិ»( បា. ឬ សំ. ) ការប្រព្រឹត្ត, កាន់, ធ្វើតាម; ច្រើននិយាយថា សេចក្តីបដិបត្តិ, ការប្រតិបត្តិ។ ខ្មែរយើងប្រើជា កិ. ផងក៏បាន : ត្រូវបដិបត្តិតាមច្បាប់; ឈ្មោះនុះគ្រាន់តែចេះធម៌ចាំច្បាស់ ប៉ុន្តែមិនប្រតិបត្តិតាម។ ២)«ប្រជុំ» (កិ.) មានន័យថា ធ្វើឲ្យជុំគ្នា, ប្រមូលឲ្យចួបជុំគ្នា, មកចួបជុំគ្នា។ ប្រជុំជន ( —ជន់ ) ពួកជនដែលកំពុងប្រជុំគ្នា ។ ទីប្រជុំ ទីដែលចួបជុំគ្នា ។ ប្រជុំជាតក ( —ដក់ ) ប្រជុំរឿងក្នុងអតីតជាតិ។ ការប្រជុំ គឺនៅពេលណាដែលមនុស្សពីរ ឬច្រើនគ្នាមកជួបជុំគ្នា ដើម្បីផ្តល់ និងទទួលព័ត៌មាន ចែករំលែកគំនិតពិភាក្សាពីបញ្ហានានាដែលប៉ះពាល់ដល់គេ ឬដើម្បីធ្វើការសម្រេចចិត្តនានា ជាមួយគ្នានោះ អង្គប្រជុំគឺជាផ្នែកដ៏សំខាន់មួយនៃការចូលរួមរបស់សមាជិក និងជាពិសេសសម្រាប់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ដូចនេះជាការសំខាន់ គឺត្រូវប្រើពេលវេលាអង្គប្រជុំនេះឱ្យមានប្រយោជន៍បំផុត (ILO, p42-44, 2007) ។

សមាជិកទាំងឡាយចង់បានការប្រជុំមួយដែលមានគោលបំណងច្បាស់លាស់ និងលទ្ធផលក្នុងការសម្រេចចិត្តច្បាស់លាស់ (ILO, p42-44, 2007)។ ដូច្នេះការរៀបចំកិច្ចប្រជុំគឺជាដំណើរការនៃការប្រមូលផ្តុំមនុស្សដើម្បីជួបជជែកពិភាក្សាលើបញ្ហាផ្សេងដើម្បីធ្វើសេចក្តីសម្រេចចិត្តតាមពេលវេលា និងទីកន្លែងជាក់លាក់មួយ ។ ការរៀបចំកិច្ចប្រជុំមាន៤ជំហាន៖

➢ ជំហានទី១៖ ការរៀបចំអង្គប្រជុំ

- សម្រេចអំពីគោលបំណងនៃកិច្ចប្រជុំ។ តើការប្រជុំនេះរៀបចំដើម្បីផ្តល់ព័ត៌មានដល់សមាជិកឬ? ឬជាការប្រមូលព័ត៌មាន? ជាការពិភាក្សាបញ្ហាពិសេសណាមួយ? ដើម្បីសម្រេចថាតើត្រូវអនុវត្តសកម្មភាពយ៉ាងណា?
- បង្កើតគោលបំណងដែលមានលក្ខណៈ SMART
    - Specific ជាក់លាក់
    - Measurable វាស់វែងបាន
    - Attainable អាចសម្រេចបាន
    - Realizable មានភាពប្រាកដនិយម
    - Time Limited កំណត់ពេលវេលាច្បាស់លាស់

- ជ្រើសរើសមនុស្សឱ្យត្រូវសម្រាប់ចូលរួមប្រជុំៈ អ្នកដែលមានចំណែកក្នុងការពិភាក្សា និងអ្នកដែលអាចទទួល និងបញ្ជូនព័ត៌មានបានទៅកាន់អ្នកដទៃបាន
- តើពេលណាសមរម្យបំផុតសម្រាប់ស្ត្រីក៏ដូចជាបុរស? តើទីកន្លែងណាដែលសមរម្យសម្រាប់ការប្រជុំមានលទ្ធភាពអាចធ្វើទៅបានស្ងាត់ និងមានសម្ភារៈជំនួយគ្រប់គ្រាន់
- សម្រេចថាអ្នកណានឹងដឹកនាំ ឬធ្វើជាប្រធានអង្គប្រជុំ ហើយអ្នកណាជាអ្នកសរសេរកំណត់ហេតុ
- រៀបចំរបៀបវារៈសម្រាប់ការប្រជុំ ហើយបញ្ចូលប្រធានបទទាំងអស់សម្រាប់ពិភាក្សា
- ផ្ញើលិខិតអញ្ជើញ ដែលមានបញ្ជាក់ច្បាស់លាស់ពីគោលបំណងរបស់អង្គប្រជុំ ប្រធានបទដែលនឹងត្រូវពិភាក្សា ពេលវេលា និងទីកន្លែងប្រជុំ វិធីរកទីកន្លែងប្រជុំ និងអ្វីដែលគេត្រូវយកជាប់មកជាមួយ។

➢ ជំហានទី២ ការប្រព្រឹត្តិទៅនៃអង្គប្រជុំ

- ជ្រើសរើសអ្នកសម្របសម្រួលដែលមានទំនាក់ទំនងល្អ និងអាចស្តាប់គ្នាបាន
- រៀបចំបន្ទប់ៈ រៀបចំកៅអីជារង្វង់មូល ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិភាក្សាគ្នាដោយចំហ ហើយអនុញ្ញាតឱ្យអ្នកផ្សេងទៀតអាចមើលឃើញនរណាម្នាក់កំពុងនិយាយដោយមិនចាំបាច់ងាកមើលជុំវិញនោះទេ
- ប្រកដប្រជាថាអ្នកសម្របសម្រួលនិងអ្នកចូលរួមទាំងអស់បានធ្វើការណែនាំឱ្យស្គាល់គ្នា
- បើកការពិភាក្សា និងផ្តល់នូវព័ត៌មានសំខាន់ៗដោយច្បាស់លាស់
- ពន្យល់ពីរបៀបវារៈនិងស្នើការឯកភាពទៅលើប្រធានបទនិងលំដាប់លំដោយនៃការពិភាក្សា
- បើចាំបាច់ អានរបាយការណ៍ប្រជុំលើកមុន ហើយស្នើការឯកភាពរលើរបៀបវារៈរបស់អង្គប្រជុំនោះ
- ណែនាំការពិភាក្សា និងធ្វើឱ្យប្រកដប្រជាថាគ្រប់គ្នា អាចចូលរួមហើយគ្មាននរណាម្នាក់ដាក់សម្ពាធលើការពិភាក្សានោះឡើយ
- ធានាថាមានការឯកភាពគ្នាលើលទ្ធផលប្រធានបទនីមួយៗ។ ព្យាយាមឈានឱ្យដល់ការសម្រេចចិត្តដោយសម្លេងឯកច្ឆ័ន្ទ ឬការបោះឆ្នោត។ តើត្រូវប្រមូលព័ត៌មានបន្ថែមដោយរបៀបណាប្រសិនបើអ្នកចូលរួមមិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់ឈានទៅរកការសម្រេចបានល្អ

➢ ជំហានទី៣៖ ការបញ្ចប់អង្គប្រជុំ

- ពិនិត្យការសម្រេចចិត្តសំខាន់ៗឡើងវិញ ព្រមទាំងផែនការសកម្មភាព
- ចាត់ចែងមនុស្សឱ្យទទួលភារកិច្ច ដែលនឹងត្រូវអនុវត្ត ហើយរៀបចំពេលវេលា និងកំណត់ពេលការងារ
- ស្នើសុំចម្លើយតបអំពីការប្រជុំនោះ
- ស្នើសុំការឯកភាពអំពីការប្រជុំលើកក្រោយទៀត

➢ ជំហានទី៤៖ របាយការណ៍ប្រជុំ

- រួមមានៈ ឈ្មោះរបស់អង្គភាព ដែលបានអញ្ជើញឱ្យចូលរួមប្រជុំ គោលបំណង ទីកន្លែង ថ្ងៃ ខែ ឆ្នាំ និងម៉ោងពេលវេលាប្រជុំ ហើយនឹងបញ្ជីឈ្មោះអ្នកចូលរួម។
- រៀបរាប់ការសម្រេចចិត្តផ្សេងៗដែលបានធ្វើនិងកត្តាសំខាន់ៗនៃការពិភាក្សាដែលនាំឱ្យមានការសម្រេចនោះ ។

ការចូលរួមគឺសំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរសនិងស្ត្រី (អាជ្ញាធរ ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត) ក្នុងដំណើរការសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ និងសារសំខាន់នៃការចូលរួមគឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើការសម្រេចចិត្ត (ILO, p42-44, 2007) ។ ជាមួយគ្នានេះដែរ នៅក្នុងគោលការណ៍ទាំង៩នៃអភិបាលកិច្ចល្អក៏មានគោលការណ៍ក្នុងចំណោម៩នេះនិយាយពី« ការចូលរួម» ជាទូទៅការចូលរួមធ្វើឡើងតាមពីររបៀបគឺ ១)ការចូលរួមដោយផ្ទាល់៖ការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់នៅក្នុងដំណើរការងនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ ។ ក្នុងរបប ប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិចូលរួមដោយផ្ទាល់ពាក់ព័ន្ធទៅនឹងកិច្ចការ សាធារណៈនិង នៅក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន។ ២)ការចូលរួមតាមរយៈអ្នកតំណាង៖ ជាអ្នកតំណាងរបស់ ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តនិងអនុវត្តសេចក្តីសម្រេចនោះ។ អ្នកតំណាងត្រូវតែបំពេញតួនាទីជាអ្នកតំណាងឱ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ (ក្រសួងមហាផ្ទៃ, p6-10, 2013)។

ការសម្របសម្រួល គឺជាសកម្មភាព និងដំណើរការនៃការជួយក្រុមមួយឱ្យធ្វើអ្វីមួយកាន់តែងាយស្រួលតាមមធ្យោបាយនានាដូចជាការពិភាក្សាបញ្ហា និងការផ្តល់អនុសាសន៍ជាជាងការបញ្ជាឱ្យគេធ្វើ។ ការសម្របសម្រួលគឺជាអ្នកដែលជួយក្រុមមួយឱ្យធ្វើអ្វីៗកាន់តែងាយស្រួលជាងមុនដោយធ្វើការពិភាក្សាបញ្ហា និងការផ្តល់អនុសាសន៍។ល។ ជាជាងការប្រាប់នូវអ្វីខ្លះដែលត្រូវធ្វើ

(គេហទំព័រកាសែតថ្មីៗ ចុះថ្ងៃទី០៤ មិថុនា ២០១៥)[1]។ ការផ្តល់និយមន័យនៃពាក្យ«ការសម្របសម្រួល» ដែលឯកភាពគ្នាមួយនោះមិនមែនជាការងាយស្រួលទេ ពាក្យនេះរួមមានអត្ថន័យដែលមានតួនាទីផ្សេងគ្នានានាហើយយើងមិនអាចរកពាក្យណាមួយមកជំនួសពាក្យនេះទាំង ស្រុងបានទេ[2] ដូចជា៖

-ទី១៖ អ្នកសម្របសម្រួលត្រូវធ្វើការងារជាក្រុម។ ប្រសិនបើនរណាម្នាក់ត្រូវការជំនួយ ឬអនុសាសន៍ដើម្បីដោះស្រាយស្ថានភាពលំបាកណាមួយនោះ គេអាចប្រើប្រាស់នូវវិធីសាស្ត្រដូចជាការបង្រៀន ឬការណែនាំ។

-ទី២៖ អ្នកសម្របសម្រួលមិនមែនជាសមាជិកនៃក្រុមដែលពាក់ពន្ធ័នោះទេ។ ភាពអព្យាក្រឹត្យគឺសំខាន់ណាស់សម្រាប់ការសម្របសម្រួលក្រុម។ ប៉ុន្តែលក្ខណ្ឌនេះមិនសុទ្ធតែត្រឹមត្រូវនោះទេក្នុងការអនុវត្តជាក់ស្តែង។ អ្នកគ្រប់គ្រងឬអ្នកដឹកនាំក្រុមអាចត្រូវបានគេស្នើឱ្យធ្វើការងារអ្នកសម្របសម្រួល។ ការសម្របសម្រួលប្រើប្រាស់បានក្នុងស្ថានភាពជាច្រើន និងការបណ្តុះបណ្តាលជាផ្នែកមួយដែលត្រូវការការសម្របសម្រួល។

អ្នកសម្របសម្រួល៖ អ្នកសម្របសម្រួលដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចប្រជុំ ព្រោះត្រូវសម្របសម្រួលសមាជិកទាំងអស់ឱ្យបញ្ចេញគំនិតយោបល់ លើកពីបញ្ហា និងដំណោះស្រាយម្តងម្នាក់ៗ ដោយមិនអនុញ្ញាតឱ្យសមាជិកណាម្នាក់និយាយកាត់គ្នា និយាយបែបវាយប្រហារ និងនិយាយទម្លាក់កំហុសដាក់គ្នាជាដើម។ បន្ទាប់មកត្រូវប្រមូលគំនិតយោបល់ទាំងនោះមកបញ្ចូលគ្នា និងបន្ទាប់ពីបិទកិច្ចប្រជុំអ្នកសម្របសម្រួលត្រូវរំលឹកខ្លឹមសារឬលិទ្ធផលប្រជុំដោយសង្ខេប ដើម្បីឲ្យសមាជិកទាំងអស់បានដឹង និងយល់កាន់តែច្បាស់ម្តងទៀត(គេហទំព័រកាសែតថ្មីៗ ចុះថ្ងៃទី០៤ មិថុនា ២០១៥)[3]។ អ្នកសម្របសម្រួលកិច្ចពិភាក្សាជាអ្នកដែលដឹកនាំកម្មវិធីពិភាក្សាទាំងមូលឱ្យមានរបៀបរៀបរយ និងបំផុសឱ្យអ្នកចូលរួមមានចម្ងល់ ឬរីករាយតាមការកែច្នៃជាក់ស្តែងរបស់គាត់ទៅតាមស្ថានការណ៍នៅលើឆាក។ ដើម្បីបង្កើត និងដឹកនាំកិច្ចពិភាក្សាបានល្អ លុះត្រាតែអ្នកសម្របសម្រួលស្គាល់ប្រធានបទច្បាស់ និងវាគ្មិនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន (គេហទំព័រឡារ៉ែន News ចុះថ្ងៃទី១០ ខែវិច្ឆិកា ២០១៧)[4] ។

1 https://thmeythmey.com/?page=detail&id=27185

2 bid

3 https://thmeythmey.com/?page=detail&id=27185

4 (http://www.lareine.com.kh/news/education/14373/)

## ២.២. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះ?

ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់គឺជាអង្គភាពសម្រាប់ផ្តល់ការគាំទ្រ និងកិច្ចសម្របសម្រួល ដើម្បីគាំទ្រការអនុវត្តឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ក្រុមការងារបច្ចេកទេសចម្រុះទាំងនេះមិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួងនិងស្ថាប័នសាមីឡើយ។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះដែលតំណាងឱ្យរាជរដ្ឋាភិបាលនៅក្នុងក្រុមការងារនីមួយៗទទួីមនឹងជំរុញឱ្យមានការពិភាក្សា និងការឯកភាពគ្នាក៏ជាអ្នកមានសិទ្ធិសម្រេចចុងក្រោយលើការងារទាំងឡាយរបស់ក្រុមការងារផងដែរ(CDC, 2010)[5]។

បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសចម្រុះចំនួន២០ត្រូវបានបង្កើត និងកំពុងបំពេញការងាររបស់ខ្លួន តាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។ ក្រុមការងារបច្ចេកទេសចម្រុះគឺជាយន្តការសំខាន់សម្រាប់ពិគ្រោះយោបល់កម្រិតបច្ចេកទេស និងសម្រាប់តម្រង់ទិស ការធ្វើកម្មវិធីនីយកម្មធនធានរបស់ក្រសួងនិងស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ ទោះបី ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានបញ្ជាក់ពីភាពចាំបាច់ក្នុងការបន្តអនុវត្តសកម្មភាពការងារ ក៍យន្តការត្រូវពិនិត្យសាលភាពការងារឡើងវិញដើម្បីឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍ ដែលបានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា (CDC, 2019)[6]។ ក្រុមការងារនេះមានគោលបំណងដើម្បីៈ

- លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ភាពជាដៃគូកម្រិតបច្ចេកទេសសម្រាប់សម្របសម្រួលនិងកៀរគរហិរញ្ញប្បទានប្រតិបត្តិការ
- ជំរុញការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងតម្រូវការអាទិភាពរបស់ក្រុមការងារ
- តាមដានវឌ្ឍនភាពក្នុងការអនុវត្តសម្មភាពរួមគ្នា រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលបានរំលេចក្នុងផែនការសកម្មភាព និងសូចនាករតាមដានរួមគ្នា

---

5 សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ខែតុលា ឆ្នាំ២០១០

6 សេចក្តីណែនាំស្តីពីក្រុមការងារបច្ចេកទេសចម្រុះខែមេសា, ឆ្នាំ២០១៩
http://www.cdc-crdb.gov.kh/cdc/twg_guideline.htm

- បំពេញបន្ថែមឱ្យយន្តការភាពជាដៃគូដទៃទៀត ដូចជាកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី ខេត្ត និងកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ។

## ២.៣. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ?

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ(JTWG-Education) គឺជាក្រុមមួយដែលបង្កើតឡើងសម្រាប់ជាដៃគូពិគ្រោះយោបល់កម្រិតថ្នាក់ដឹកនាំជាមួយអ្នកពាក់ព័ន្ធទាំងអស់ទៅលើវិស័យអប់រំដែលមានសមាសភាពរួមមាន៖រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ តំណាងសង្គមស៊ីវិលនិងអង្គការយូណេស្កូ(គេហទំព័រUNESCO Phnom Penh, Cambodia)[7] ។ គោលបំណងរួមរបស់ក្រុមការងារនេះគឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពជំនួយ និងភាពជាដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ការសម្រេចបាននូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងកម្មវិធីកំណែទម្រង់ពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះគោលការណ៍ភាពជាដៃគូសម្រាប់វិស័យអប់រំដើរតួជាមគ្គុទ្ទេសសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ រៀបចំរបាយការណ៍លទ្ធផលទៅកាន់គណៈកម្មាធិការកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល(GDCC)។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំត្រូវប្រជុំ៤ដងក្នុង១ឆ្នាំឬរៀងរាល់ត្រីមាសម្តង(៣ត្រីមាសសម្រាប់ប្រជុំពិភាក្សា និងមួយត្រីមាសទៀតសម្រាប់ធ្វើអង្គវិបស្សនា)(គេហទំព័រUNESCO Phnom Penh, Cambodia)។

អង្គការយូណេស្កូ(UNESCO) គឺជាប្រធានក្រុមការងារវិស័យអប់រំ(ESWG) ប្រចាំខែដែលជាវេទិកាសម្របសម្រួលមួយក្នុងចំណោមដៃគូអភិវឌ្ឍន៍ក្នុងវិស័យអប់រំ ម្យ៉ាងវិញទៀត អង្គការយូណេស្កូដើរតួជាលេខាធិការដ្ឋានក្រុមESWG។ តាមរយៈក្រុមការងារESWG រួមជាមួយដៃគូអប់រំផ្សេងទៀតនៅកម្ពុជា អង្គការយូណេស្កូចូលរួមយ៉ាងសកម្មក្នុងការចែករំលែកព័ត៌មាន ការពិភាក្សាគោលនយោបាយ កម្មវិធីរួមគ្នា និងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងអប់រំ យុវជននិងកីឡាស្តីពីការអភិវឌ្ឍឯកសារគោលនយោបាយ (រួមទាំងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិការប្រចាំឆ្នាំ)ការអភិវឌ្ឍសមត្ថភាព និងការសម្របសម្រួលលើព្រឹត្តិការណ៍សំខាន់ដូចជា៖សន្និបាតអប់រំ និងការគាំទ្រការជជែកពិភាក្សា និងការអនុវត្តប្រសិទ្ធភាពជំនួយ។ អង្គការយូណេស្កូរួមចំណែកជាពិសេសក្នុងការសម្របសម្រួលនិងដឹកនាំការពិភាក្សាស្តីពីការអប់រំសម្រាប់

[7] http://www.unesco.org/new/en/phnompenh/education/unesco-working-groups-in-education/education-sector-working-group/

ទាំងអស់គ្នា ការបណ្ដុះបណ្ដាលគ្រូបង្រៀន អក្ខរកម្មនិងការអប់រំក្រៅប្រព័ន្ធនិងផ្នែកដទៃជាច្រើន។ ក្រុមការងារESWG (ក៏ដូចជាJTWG) គឺជាវេទិកាមួយក្នុងចំណោមវេទិកាដ៏មានប្រសិទ្ធភាពបំផុតក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលដើម្បីសម្របសម្រួលសកម្មភាពរបស់ពួកគេឱ្យឆ្លើយតបនឹងគោលបំណងប្រសិទ្ធភាពជំនួយ។ ការចូលរួមប្រកបដោយនិរន្តរភាពនិងទូលំទូលាយរបស់សមាជិកក្រុមESWGចំពោះសកម្មភាពការងារនេះគួរត្រូវបានលើកទឹកចិត្ត និងធានា(UNESCO Phnom Penh, Cambodia)[8]។

## ២.៤. អ្វីជាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត?

ដោយឡែកចំពោះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត(Provincial JTWG) គឺជាក្រុមមួយដែលបង្កើតឡើងដោយការចាត់តាំងបញ្ចូលជាសមាជិកតាមសមាសភាពដែលមកពីមន្ទីរវិស័យនៃក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកពាក់ព័ន្ធផ្សេងៗ ដើម្បីជួយសហការ និងគាំទ្រជំរុញក្នុងការអភិវឌ្ឍវិស័យអប់រំនៅមូលដ្ឋាន ឬតាមរាជធានីខេត្តទាំង២៥ ដែលមានមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តជាលេខាធិការដ្ឋាននិងជាអ្នកដឹកនាំដំណើរប្រជុំក្រុមការងារនេះ ដើម្បីជួបប្រជុំគ្នាពិភាក្សា ពិគ្រោះយោបល់ និងដោះស្រាយរួមគ្នារៀងរាល់មួយត្រីមាសម្ដងដោយធ្វើឡើង៤ត្រីមាស/ឆ្នាំ(MoEYS, 2011)។ ក្រុមការងារនេះត្រូវបានកំណត់ពីតួនាទី ការទទួលខុសត្រូវ និងប្រធានបទពិភាក្សាដែលបានកំណត់ក្នុងសេចក្ដីណែនាំ និងតាមផែនការសកម្មភាពប្រចាំឆ្នាំ។ ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់គឺជាអង្គភាពសម្រាប់ផ្ដល់ការគាំទ្រ និងកិច្ចសម្របសម្រួល ហើយក៏មិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួង និងស្ថាប័នសាមី(MoEYS, 2011)។ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ជាតិ ត្រូវបានបង្កើតឡើង តាមលិខិតឧទ្ទេសនាមលេខ ២៩៨១ អយក.ឧទន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ និងបន្តអនុវត្តសកម្មភាពការងាររបស់ខ្លួន ដោយសម្រេចបានសមិទ្ធិផលដែលគួរឱ្យកត់សម្គាល់ជាច្រើន។ ឆ្លងតាមបទពិសោធន៍ជោគជ័យពីថ្នាក់ជាតិនេះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ត្រូវបានបង្កើតឡើងតាមសេចក្ដីណែនាំលេខ ០៤ អយក សណន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១(MoEYS, 2011)។ ឆ្លងតាមការអនុវត្តការងារដល់ដំណាក់កាលថ្មីនេះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំទាំងថ្នាក់ជាតិ និងរាជធានី ខេត្ត នៅតែជាយន្តការដែលមានប្រសិទ្ធ

[8] http://www.unesco.org/new/en/phnompenh/education/unesco-working-groups-in-education/education-sector-working-group/

ភាពក្នុងភាពជាដៃគូសហការ កិច្ចសន្ទនាកម្រិតគោលនយោបាយ និងបច្ចេកទេស ជាពិសេសការកៀរគរធនធានពីដៃគូដើម្បីបំពេញបន្ថែមរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យសម្រេចបានវត្ថុបំណងក្នុងកំណែទម្រង់វិស័យអប់រំនៅថ្នាក់មូលដ្ឋាន។

ទោះជាយ៉ាងនេះក្តី ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ប្រែប្រួលយ៉ាងឆាប់រហ័សនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៦នៃរដ្ឋសភា ជាពិសេសដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ ដែលត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងយោងតាមរបត់ថ្មីនៃការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៩-២០២៣ សេចក្តីណែនាំស្តីពីការលើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ត្រូវបានរៀបចំឡើងវិញដើម្បីពង្រឹងប្រសិទ្ធភាពការងារតាមរយៈការបញ្ជ្រាបការយល់ដឹងពីគោលបំណង គោលការណ៍ណែនាំអាទិភាពការងារ និងយន្តការងារ រួមជាមួយនឹងកម្មវិធីការងារច្បាស់លាស់ ដែលអាចឆ្លើយតប និងឈានទៅសម្រេចបានវត្ថុបំណងការងារវិស័យអប់រំស្របនឹងស្ថានភាពជាក់ស្តែងរបស់ខ្លួន(CDC, 2019)។ ចំពោះការបង្កើតក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានីខេត្តនេះ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងគោលបំណង៖ ១)លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ភាពជាដៃគូកម្រិតបច្ចេកទេស សម្រាប់សម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ២)ជំរុញការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងតម្រូវការអាទិភាពរបស់ក្រុមការងារ ៣)តាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពរួមគ្នារវាងស្ថាប័នរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលបានរំលេចសកម្មភាពក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និង ៤)បំពេញបន្ថែមឱ្យយន្តការភាពជាដៃគូដទៃទៀត តាមរយៈកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី ខេត្ត និងកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ(MoEYS, 2011)។ ក្នុងន័យនេះ ដោយឈរលើមូលដ្ឋានដែលមានស្រាប់ ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់រាជធានី-ខេត្ត នៅតែជាយន្តការសម្រាប់ផ្តល់ការគាំទ្របច្ចេកទេស និងកិច្ចសម្របសម្រួលបន្ថែម តែមិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់ជាមួយនឹងក្រសួងសាមី ស្ថាប័នឬអង្គភាពដទៃទៀតឡើយ (MoEYS, ២០១១)[9] ។

ម្យ៉ាងវិញទៀតចំពោះក្រុមការងារវិស័យអប់រំថ្នាក់រាជធានីខេត្ត( Provincial-ESWG) គឺជាក្រុមបណ្តាញរបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NEP) ដែលមានសមាស

[9] សេចក្តីណែនាំលេខ០៤ អយក.សណន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ភាពមកពីអង្គការ សង្គមស៊ីវិល(អង្គការក្នុងស្រុក និងអន្តរជាតិ មិនមែនរដ្ឋាភិបាល)ដែលសកម្មនៅក្នុងវិស័យអប់រំ និងមានគោលបំណងធ្វើការរួមគ្នាក្នុងការនាំយកការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងគោលនយោបាយអប់រំ និងការអនុវត្តនានាតាមរយៈការធ្វើការរួមគ្នា ការផ្សារភ្ជាប់គ្នាទៅវិញទៅមក ការចែករំលែកព័ត៌មានរួមគ្នាត្រួតពិនិត្យការផ្តល់សេវាអប់រំ និងធ្វើការតស៊ូមតិនិងពិភាក្សាគោលយោបាយរួមគ្នា នៅថ្នាក់រាជធានី-ខេត្ត (NEP, 2017) ។ នៅដើមឆ្នាំ២០០០ អង្គការមិនមែនរដ្ឋាភិបាលនានា ដែលផ្តោតលើវិស័យអប់រំធ្វើការដាច់ដោយឡែកៗពីគ្នាជាមួយវិធីសាស្រ្តផ្សេងៗគ្នាក្នុងការតស៊ូមតិ។ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ និងបានក្លាយជាតំណាងឲ្យសំឡេងនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់នៅក្នុងវិស័យអប់រំ ដោយសារអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ជាអង្គការសមាជិកភាពតែមួយគត់សម្រាប់អង្គការសង្គមស៊ីវិលដែលផ្តោតលើវិស័យអប់រំនៅប្រទេសកម្ពុជា មានសមាជិកជាអង្គ-ការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិប្រមាណជាង១៣០អង្គការ ដែលធ្វើការនៅគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា (NEP, 2017)។ ចាប់តាំងពីឆ្នាំ២០១២មក អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលបានសម្របសម្រួល និងគាំទ្រការបង្កើតក្រុមការងារវិស័យអប់រំថ្នាក់រាជធានីខេត្តនៅទូទាំងប្រទេសកម្ពុជា ។ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់រាជធានីខេត្ត ចំនួន០៥ ត្រូវបានបង្កើតឡើងរហូតដល់ឆ្នាំ២០១៣ បណ្តាញក្រុមការងារចំនួន១២ ត្រូវបានបង្កើតឡើង។ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នមានចំនួន២៤រាជធានីខេត្តនៃព្រះរាជាណាចក្រកម្ពុជា (NEP, 2017)[10]។

## ២.៥. គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត

ដើម្បីជំរុញការអនុវត្តរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តប្រកបដោយប្រសិទ្ធភាពស្របតាមយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣(CDC, 2019) មន្ទីរអប់រំ យុវជន និងកីឡាត្រូវប្រកាន់ភ្ជាប់គោលការណ៍សំខាន់បួនដូចខាងក្រោម៖

**១.ភាពជាម្ចាស់៖** ត្រូវប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋានដោយឈរលើគោលការណ៍ភាពជាម្ចាស់ដើម្បីពង្រឹងទំនាក់ទំនងដែលមានការទុកចិត្ត និងការគោរពគ្នា ទៅវិញទៅមកតាមរយៈការអនុវត្តផែនការសកម្មភាពការងារផ្អែកលើលទ្ធផល។

[10] សៀវភៅណែនាំស្តីពីការដឹកនាំបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ខែកុម្ភៈ ឆ្នាំ២០១៧ ទំព័រ៥-៧ http://memlib.nepcambodia.org/libraries?page=2

**២.ភាពជាដៃគូ៖** ត្រូវដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូក្នុងមូលដ្ឋានទាំងអស់ដើម្បីកៀរគរធនធាន សំដៅសម្រេចបានលទ្ធផលដែលបានកំណត់ក្នុងចំណុចដៅរបស់ក្រុមការងារស្របតាមផែន ការប្រតិបត្តិប្រចាំឆ្នាំ និងឈានទៅសម្រេចបានចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្ដីពីការអប់រំនៅកម្ពុជាឆ្នាំ២០៣០។

**៣.ការតម្រឹម និងលទ្ធផល៖** យន្តការនៃភាពជាដៃគូ និងការសម្របសម្រួលត្រូវបញ្ជាក់នូវគោល ដៅច្បាស់លាស់ ដើម្បីតម្រឹមធនធានជាមួយនឹងអាទិភាព និងកំណត់ប្រព័ន្ធពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពដែលត្រូវប្រើប្រាស់ដោយផ្សារភ្ជាប់ទៅនឹងក្របខណ្ឌលទ្ធផលដែលមានស្រាប់។

**៤.គណនេយ្យភាព៖** សមាជិកក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តទាំងអស់ត្រូវមានគណនេយ្យភាពទៅវិញទៅមកក្នុងការសម្រេចលទ្ធផលការងារ។

### ២.៥.១.អាទិភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

សេចក្ដីណែនាំបានកំណត់អាទិភាពការងារ៥ សម្រាប់ក្រុមការងារ ប៉ុន្តែ ក្រុមការងារថ្នាក់រាជធានី ខេត្តនីមួយៗ អាចកំណត់គោលការណ៍ឱ្យបានកាន់តែជាក់លាក់ ឬសម្រួចគោលការណ៍ដើម្បីកំណត់អាទិភាពការងាររបស់ខ្លួន ដោយផ្អែកលើតម្រូវការ ធនធាន និងសមត្ថភាពដែលមានស្រាប់៖

១. ធានាឱ្យបាននូវការតម្រឹម ការសម្របសម្រួល និងការកៀរគរ និងប្រើប្រាស់ធនធានឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ តាមរយៈ ការប្រមូល កត់ត្រា និងប្រើប្រាស់ព័ត៌មានពាក់ព័ន្ធនឹងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ក្នុងមូលដ្ឋាន សម្រាប់ការរៀបចំផែនការ និងសម្រេចចិត្តផ្សេងៗ

២. លើកកម្ពស់កិច្ចពិគ្រោះយោបល់រវាងមន្ទីរអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ ទៅលើប្រធានបទសំខាន់ៗ ដែលទាមទារការពិភាក្សា និងស្វែងរកដំណោះស្រាយរួមគ្នា

៣.ពិនិត្យនិងតាមដានវឌ្ឍនភាពនៃការអនុវត្តការងារទៅតាមពេលវេលាជាក់លាក់ជាប្រចាំអំពីសមិទ្ធកម្ម និងបញ្ហាប្រឈម

៤. ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ត្រូវផ្ដោតការងារជាសំខាន់ទៅលើប្រធានបទ ឬការងារអន្តរវិស័យ ដែលក្រុមការងារមកពីស្ថាប័ន មន្ទីរ អង្គភាព ផ្សេងទៀតអាចផ្ដល់ការគាំទ្រ រួមមាន៖ យេនឌ័រ បរិស្ថាន សណ្ដាប់ធ្នាប់សង្គម សុវត្ថិភាពចំណីអាហារចរាចរណ៍ និងការងារអភិបាលកិច្ចជាដើម និង

៥. ចែករំលែកព័ត៌មាន គឺជាកិច្ចការជាមូលដ្ឋានរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ដែលជាវេទិការសម្រាប់ក្រុមការងារផ្ដល់ព័ត៌មានបច្ចុប្បន្នភាពអំពីដំណើរ

ការរៀបចំផែនការ ឬដំណើរការការអនុវត្តសកម្មភាព សមិទ្ធិផលសម្រេចបាន បញ្ហាប្រឈមអន្តរវិស័យ ដែលជាផ្នែកមួយនៃការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងការងារ ដើម្បីអ្នកពាក់ព័ន្ធអាចទទួលបានព័ត៌មានត្រឹមត្រូវ ទាន់ពេលវេលា ដល់សមាជិកគ្រប់រូបអំពីកិច្ចប្រជុំសម្រាប់ការសម្រេចចិត្ត និងអន្តរាគមន៍មានប្រសិទ្ធភាព និងទាន់សភាពការណ៍(CDC, 2019)។

## ២.៥.២. សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំនៅតាមមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា ស្នើឱ្យមានសមាសភាពដូចជា តំណាងគណៈអភិបាលរាជធានី-ខេត្ត ជាប្រធានកិត្តិយសនៃក្រុមការងារ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ជាប្រធានដឹកនាំកិច្ចប្រជុំប្រចាំការ ថ្នាក់ដឹកនាំ តំណាង ឬមន្ត្រីជំនាញមកពីមន្ទីរ ស្ថាប័ន ដៃគូអភិវឌ្ឍន៍/សង្គមស៊ីវិល អង្គភាព សហគមន៍ និងវិស័យឯកជន ដែលធ្វើការពាក់ព័ន្ធវិស័យអប់រំ ជាអនុប្រធាន សមាជិក ឬលេខាធិការនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី-ខេត្ត(CDC, 2019)។ ចំពោះចំនួនសមាជិក គួរគប្បីកំណត់ក្នុងបរិមាណមួយសមស្រប និងមានប្រសិទ្ធភាពខ្ពស់។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានី ខេត្ត ដោយពិភាក្សាជាមួយសមាជិក គឺជាអ្នកមានសិទ្ធិសម្រេចចុងក្រោយលើសមាជិករបស់ក្រុមការងារ(CDC, 2019)។ សមាសភាពខាងក្រោមជាគំរូមួយសម្រាប់មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្តនីមួយៗ ធ្វើការពិចារណាជាមូលដ្ឋានដើម្បីបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំទៅតាមស្ថានភាព និងទំហំការងារជាក់ស្តែង (MoEYS, 2019)៖

| | |
|---|---|
| ១. គណៈអភិបាលរាជធានី ខេត្ត (ទទួលបន្ទុកវិស័យអប់រំ) | ប្រធានកិត្តិយស |
| ២. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ប្រធាន |
| ៣. អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា (ទទួលបន្ទុកការងារផែនការ) | អនុប្រធាន |
| ៤. ប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍវិស័យអប់រំ | អនុប្រធាន |
| ៥. ប្រធានឬអនុប្រធានមន្ទីរពាក់ព័ន្ធ | អនុប្រធាន |
| ៦. នាយករដ្ឋបាល ឬនាយករងរដ្ឋបាល សាលារាជធានី ខេត្ត | សមាជិក |
| ៧. ប្រធានឬអនុប្រធានមន្ទីរពាក់ព័ន្ធ | សមាជិក |
| ៨. ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ខណ្ឌ | សមាជិក |
| ៩. ប្រធានឬអនុប្រធានការិយាល័យជំនាញក្រោមឱវាទមន្ទីរអយក | សមាជិក |
| ១០. ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | សមាជិកអចិន្ត្រៃយ៍ |
| ១១. អនុប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | លេខាធិការ |
| ១២. មន្ត្រីជំនាញការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | លេខាធិការ |

ចំពោះករណីមានសមាសភាពក្រៅពីការចាត់តាំងខាងលើ ប្រធានមានសិទ្ធិអញ្ជើញអ្នកដែលមានការពាក់ព័ន្ធនានាមកចូលរួមប្រជុំធ្វើបទបង្ហាញ ឬរាយការណ៍លើប្រធានបទជាក់ស្តែងតាមការឯកភាពគ្នា និងតាមការចាំបាច់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តភារកិច្ចឱ្យបានត្រឹមត្រូវផ្អែកលើកម្មវិធីការងារដែលបានគ្រោងទុក ដើម្បីរួមចំណែកសម្រេចការងារសំខាន់ៗក្នុងវិស័យអប់រំ (MoEYS, 2011)ដូចខាងក្រោម៖

- គៀរគរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សម្រាប់អភិវឌ្ឍវិស័យអប់រំនៅក្នុងរាជធានី ខេត្ត ឱ្យឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការអប់រំឆ្នាំ២០៣០
- ពិភាក្សា និងផ្តល់ធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិ ប្រចាំរបស់រាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងផែនការរបស់ក្រសួង
- ប្រមូល និងគ្រប់គ្រងទិន្នន័យអប់រំ និងប្រើប្រាស់ទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ ជាពិសេសគម្រោងសកម្មភាពកំពុងអនុវត្ត ដោយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋានតាមរាជធានី ខេត្ត
- ពិនិត្យតាមដាន និងពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំទៅតាមក្របខណ្ឌពេលវេលា ដែលបានកំណត់
- រៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ
- ពង្រឹងកិច្ចសហការក្នុងភាពជាដៃគូ និងការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត រៀងរាល់ត្រីមាស ឬអាចរៀបចំប្រជុំផ្សេងទៀតតាមការចាំបាច់។

### ២.៥.៣. តួនាទី និងការទទួលខុសត្រូវ

ដើម្បីឱ្យលទ្ធផលនៃការបំពេញការងារកាន់តែមានគុណភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តទាមទារឱ្យមានការយល់ដឹងពីសារសំខាន់នៃក្រុមការងារ តួនាទីភារកិច្ច និងការទទួលខុសត្រូវបានច្បាស់លាស់។ ក្រុមការងារលេខាធិការដ្ឋាននឹងដើរតួសម្របសម្រួល និងធានាឱ្យមានការចូលរួមយ៉ាងសកម្មតាមរយៈការទទួលបានការគាំទ្រធនធានចាំបាច់នានា ដើម្បីឱ្យការប្រព្រឹត្តទៅរបស់ក្រុមការងារទាំងមុន អំឡុងពេល និងក្រោយពេលបញ្ចប់កិច្ចប្រជុំដំណើរការទៅកាន់តែមានប្រសិទ្ធភាពខ្ពស់។ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវបង្កើតលេខាធិការដ្ឋានមួយដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានក្រុមការងារ ដើម្បីគាំទ្រកិច្ចការរដ្ឋបាលរបស់ក្រុមការងារ តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារដែលបានឯកភាពក្នុងកិច្ចប្រជុំ និងជួយសម្របសម្រួលការផ្តល់ព័ត៌មានទៅគ្រប់អ្នកពាក់ព័ន្ធ (MoEYS, 2019)។

តួនាទី និងទំនួលខុសត្រូវរបស់សមាសភាពនីមួយៗត្រូវបានស្នើឡើងដូចខាងក្រោម៖

### ក. ប្រធានក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត

- អនុម័តលើផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ
- ត្រូវសម្រេចចិត្តលើរបៀបវារៈនៃកិច្ចប្រជុំជាមួយនឹងតំណាងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល
- ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំតាមផែនការដែលបានកំណត់
- គាំទ្រធនធានសម្រាប់កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ
- រាយការណ៍ជូនអភិបាលនៃគណៈអភិបាលដោយផ្ទាល់ពីស្ថានភាពអប់រំនិងស្នើសុំកិច្ចអន្តរាគមន៍ ឬការសម្រេចចិត្តទៅលើប្រធានបទអន្តរវិស័យ ឬកម្រិតខ្ពស់នានា
- ផ្តល់អន្តរាគមន៍ដោយផ្ទាល់ទៅកាន់មន្ទីរ ស្ថាប័នអង្គភាព និងដៃគូអភិវឌ្ឍ ដើម្បីពន្លឿនការអនុវត្តកិច្ចការរបស់ក្រុមការងារប្រកបដោយប្រសិទ្ធភាព។

### គ. សមាជិក

- ចូលរួមប្រជុំ និងផ្តល់ធាតុចូលដែលពាក់ព័ន្ធ
- ជូនដំណឹងអំពីការចូលរួមឬសមាសភាពជំនួសដែលអាចសម្រេចចិត្តបានករណីមិនបានចូលរួម
- រាយការណ៍ជូនថ្នាក់ដឹកនាំស្ថាប័ន អង្គភាពខ្លួន អំពីលទ្ធផលនៃកិច្ចប្រជុំដើម្បីជាព័ត៌មានការសហការ ឬការសម្រេចចិត្ត
- ផ្តល់មតិយោបល់បន្ថែមលើសេចក្តីព្រាងរបាយការណ៍ ឬកំណត់ហេតុ ដែលត្រូវបានរៀបចំដោយលេខាធិការដ្ឋានមុនពេលអនុម័តជាផ្លូវការ ដើម្បីផ្សព្វផ្សាយខ្លឹមសារនៃកិច្ចប្រជុំជូនដល់សមាជិកក្រុមការងារ
- ចូលរួមអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលតាមស្មារតីអង្គប្រជុំ។

### ឃ. លេខាធិការដ្ឋាន

- រៀបចំអាណត្តិការងាររបស់ខ្លួន និងក្រុមការងារឱ្យបានច្បាស់លាស់
- រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំដាក់ជូនប្រធានពិនិត្យ និងសម្រេច
- លើកស្នើរបៀបវារៈសម្រាប់ប្រជុំដោយពិភាក្សាជាមួយលេខាធិការដ្ឋានដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល និងដាក់ជូនទៅប្រធានក្រុមការងារពិនិត្យ និងសម្រេច
- រៀបចំឯកសារពាក់ព័ន្ធសម្រាប់ចែកជូនដល់សមាជិកទាំងអស់ឱ្យបានយ៉ាងតិច១០ថ្ងៃមុនប្រជុំ
- រៀបចំសេចក្តីព្រាងរបាយការណ៍ ឬកំណត់ហេតុ និងផ្ញើជូនទៅអ្នកពាក់ព័ន្ធដើម្បីពិនិត្យ កែសម្រួល និងផ្តល់ធាតុចូលបន្ថែម
- ផ្សព្វផ្សាយរបាយការណ៍ ឬកំណត់ហេតុ និងផ្តល់ដល់សមាជិកទាំងអស់ឱ្យបានទាន់ពេលវេលាយ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីកិច្ចប្រជុំ
- ផ្តល់ព័ត៌មានបច្ចុប្បន្នភាព របាយការណ៍ ឬកំណត់ហេតុ និងទិន្នន័យដែលពាក់ព័ន្ធ ទៅការិយាល័យសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៃនាយកដ្ឋានផែនការតាមពេលវេលាកំណត់ ឬតាមការស្នើសុំចាំបាច់។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានធ្វើឡើងទាំងបរិមាណវិស័យ និងគុណវិស័យ។

៣.១.១. ទីកន្លែងស្រាវជ្រាវ៖ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានកម្រិតគួរឱ្យជឿជាក់ខ្ពស់ អ្នកស្រាវជ្រាវបានជ្រើសរើសលក្ខណ្ឌ ក្នុងនោះរួមមាន៖លក្ខណ្ឌទី១) មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ២)ក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត(P-ESWG) និងទី៣)មន្ទីរវិស័យមួយចំនួនក្នុងខេត្តនៅតាមបណ្ដាខេត្តចំនួន១៣នៃ២៥ រាជធានីខេត្ត រួមមាន៖ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិសាត់ កំពង់ស្ពឺ កំពត ព្រះសីហនុ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ ស្ទឹងត្រែង និងស្វាយរៀង។

៣.១.២. ការជ្រើសរើសសំណាក

- ទិន្នន័យបឋម៖ អ្នកស្រាវជ្រាវបានធ្វើការសិក្សាលើសំណាកសរុបចំនួន១៣៩នាក់នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន១៣ ត្រូវបានជ្រើសរើសដោយកំណត់ពីវិសាលខេត្តដែលបានដំណើរការនៃក្រុមការងារនេះបានល្អ មធ្យម និងមិនសូវល្អតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំ ក្នុងនោះមានសមាសភាពចាប់ពីប្រធាន/អនុប្រធានមន្ទីរចំនួន៣០រូប ប្រធាន/អនុប្រធានការិយាល័យចំនួន ១០០រូប និងមន្ត្រីជំនាញចំនួន០៩រូបដែលជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ក្នុងនោះ ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ចំនួន១០២ ក្រុមP-ESWG ចំនួន១៣និងមន្ទីរវិស័យពាក់ព័ន្ធចំនួន២៤ដែលបានចូលរួមឆ្លើយកម្រងសំណួរនិងធ្វើសំភាសន៍។
- ទិន្នន័យបន្ទាប់បន្សំ៖ អ្នកស្រាវជ្រាវបានស្វែងរកឯកសារដែលមានស្រាប់ពាក់ព័ន្ធនឹងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំទាំងថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្ត សេចក្ដីណែនាំស្ដីពីការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ សេចក្ដីណែនាំស្ដីពីការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ របាយការណ៍វឌ្ឍនភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធដទៃទៀត។

៣.១.៣. ឧបករណ៍ និងនីតិវិធីនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវបានជ្រើសរើសមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន១៣នៃ២៥មន្ទីរអប់រំ យុវជន និងកីឡារាជខេត្តទូទាំងប្រទេសដើម្បីចុះជួបពិភាក្សា និងចែកជូនកម្រងសំណួរ ព្រមទាំង

សំភាសន៍ផង ដោយប្រើប្រាស់សំណួរបើក និងសំណួរបិទ។ មុនចាប់ផ្ដើម អ្នកស្រាវជ្រាវបានបង្ហាញពីវត្ថុបំណង និងពន្យល់ពីខ្លឹមសារសំណួរក្នុងគោលបំណងឱ្យអ្នកឆ្លើយយល់ពីសំណួរ និងការឆ្លើយឱ្យចំតាមសំណួរដែលអ្នកស្រាវជ្រាវចង់បានដោយប្រើរយៈពេល៦០នាទីសម្រាប់បំពេញកម្រងសំណួរ និងសម្ភាសន៍។ អ្នកស្រាវជ្រាវបានបែងចែកក្រុមគោលដៅសម្រាប់បំពេញកម្រងសំណួរ និងសម្ភាសន៍ ក្នុងនោះមាន មន្ទីរអ.យ.ក ការិយាល័យផែនការនិងគ្រប់គ្រងជំនួយជាលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ការិយាល័យជំនាញក្រោមចំណុះមន្ទីរ ក្រុមការងារវិស័យអប់រំតំណាងដៃគូអភិវឌ្ឍន៍ ឬអង្គការមិនមែនរដ្ឋាភិបាល(P-ESWG)ដែលជួយក្នុង វិស័យអប់រំ និងមន្ទីរវិស័យពាក់ព័ន្ធជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។ ជាចុងក្រោយអ្នកស្រាវជ្រាវប្រមូលកម្រងសំណួរត្រឡប់វិញបន្ទាប់ពីបំពេញចប់រួចពិនិត្យទៅលើខ្លឹមសារនីមួយៗនៃសំណួរត្រូវបានឆ្លើយឬបំពេញគ្រប់ចំណុចប្រសិនបើខ្វះចន្លោះនឹងស្នើបំពេញបន្ថែម។ ចំពោះសំណួរសម្ភាសន៍ត្រូវបានយកមកប្រើសម្រាប់ផ្ទៀងផ្ទាត់ពីភាពពិតប្រាកដទៅលើសំណាកនីមួយៗ។

## ៣.២. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៣.២.១. ទំហំនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន១៣ សម្រាប់តំណាងឱ្យមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តទូទាំងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះផ្ដោតលើប្រធានបទដែលមានចំណងជើងថា«ទស្សនៈការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត»។

### ៣.២.២. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្ដោតលើយន្តការនៃដំណើរការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត និងវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ សំណូមពរឬអនុសាសន៍ចាប់តាំងពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩។

### ៣.២.៣. ការវិភាគទិន្នន័យ

អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរ៥ប្រភេទផ្សេងគ្នាតែខ្លឹមសារនៃសំណួរដូចគ្នា សរុប ១៣៩ច្បាប់ និងបានផ្ដល់ដល់ជូនអ្នកត្រូវឆ្លើយសំណួរ១៣៩នាក់ដូចសមាសភាពបង្ហាញខាងលើដែលត្រូវយកមកវិភាគតាមផ្នែកនីមួយៗនៃសំណួរ ដោយផ្អែកតាមសំណួរស្រាវជ្រាវដែលបានកំណត់ពីខាងដើម។ អ្នកស្រាវជ្រាវយកទិន្នន័យដែលប្រមូលបានទៅបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីរៀបចំជាតារាង ឬដ្យាក្រាម និងវិភាគ។

# ជំពូកទី៤
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៤
# លទ្ធផលនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវបានប្រើប្រើប្រាស់ព័ត៌មានដែលបានបំពេញតាមកម្រងសំណួរទាំងអស់ និងបានបញ្ចូលមតិយោបល់ដែលពួកគាត់បានឆ្លើយ ដើម្បីធានាបានថាការវិភាគមានលក្ខណៈសមស្របឆ្លើយតបនឹងវត្ថុបំណង និងសំណួរស្រាវជ្រាវដែលបានកំណត់ដូចខាងក្រោម៖

*១. តើយន្តការនៃដំណើរការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តយ៉ាងណាខ្លះ?*

## ៤.១. ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

មុនដំណើរការកិច្ចប្រជុំនៃក្រុមការងារនេះទៅបានអាស្រ័យលើផែនការសកម្មភាព ដែលត្រូវបានរៀបចំឡើងដោយកំណត់ក្របខណ្ឌពេលវេលាជួបប្រជុំតាមត្រីមាស និងរបៀបវារៈសំខាន់ៗដោយធ្វើឡើងតាមគោលការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាយ៉ាងហោចណាស់៤ដងឬ៤ត្រីមាសក្នុងមួយឆ្នាំ។ តាមរយៈការសិក្សាស្រាវជ្រាវទៅលើអ្នកពាក់ព័ន្ធបានបង្ហាញថា៖

### ៤.១.១. ការពិគ្រោះយោបល់

**រូបភាពទី១៖ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ**




ដើម្បីដំណើរកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនេះបាន ចាំបាច់ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ(៤ត្រីមាស/ឆ្នាំ) ដែលផែនការសកម្មភាពនេះត្រូវបានបង្កើត ឡើងដោយមានការចូលរួមពិគ្រោះយោបល់ពីផ្នែកពាក់ព័ន្ធ និងឯកភាពសម្រាប់លទ្ធផលកិច្ចប្រជុំនីមួយៗដែលត្រូវដោះស្រាយសម្រាប់រយៈពេល១ឆ្នាំ។ រូបភាពទី១ បង្ហាញថាការរៀបចំផែនការសកម្មភាពមានការពិគ្រោះយោយល់រវាងមន្ទីរអយក និងក្រុមការងារវិស័យអប់រំ ៣១% និងជាមួយថ្នាក់ដឹកនាំមន្ទីរមាន៣៣% ប៉ុន្តែបើធៀបនឹងការចូលរួមរបស់មន្ទីរវិស័យមាន១៧% និងមានចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីមាន១៨%។ ដូច្នេះ ការចូលរួមពិគ្រោះយោបល់មិនត្រូវបានចូលរួមគ្រប់ភាគីពាក់ព័ន្ធនៅឡើយ ដោយសារការរៀបចំផែនការសកម្មភាពនេះមានការផ្តោខ្លាំងតែលើវិស័យអប់រំដែលតម្រូវឱ្យកំណត់នូវជនបង្គោលឬអង្គភាពបង្គោលចូលរួមពិភាក្សា និង

ពិគ្រោះយោបល់ភាគច្រើនលើសលុប មានន័យថា ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំមានចូលរួមភាគច្រើនមានតែរវាងមន្ទីរអ.យ.ក និងក្រុមការងារវិស័យអប់រំប៉ុណ្ណោះសរុបជារួមប្រមាណជា ៨០%។

### ៤.១.២. របៀបវារៈបានស្នើ

រូបភាពទី២៖របៀវារៈក្នុងផែនការសកម្មភាពប្រចាំឆ្នាំ




ការរៀបចំផែនការសកម្មភាពគឺ ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធដែលជាសមាសភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ដូចតាមរូបភាពទី២ បានបង្ហាញថា ខ្លឹមសារនៃរបៀបវារៈផ្តោតសំខាន់ខ្លាំងលើការដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន មាន៣០% និងការអភិវឌ្ឍវិស័យអប់រំវិញមាន៣១% ប៉ុន្តែបើប្រៀបធៀបនឹងរបៀបវារៈពាក់ព័ន្ធនឹងការងារតាមការិយាល័យជំនាញមាន១៦% និង១៧%សម្រាប់ការងាររបស់ដៃគូអភិវឌ្ឍន៍។ ដូច្នេះខ្លឹមសាររបៀបវារៈក្នុងផែនការសកម្មភាពមានភាពពាក់ព័ន្ធច្រើនតែលើការដោះស្រាយបញ្ហាប្រឈម និងការអភិវឌ្ឍវិស័យអប់រំក្នុងមូលដ្ឋានមានប្រមាណជាង៦១% និងសម្រាប់សកម្មភាពផ្សេងមានជាង២៩%។

### ៤.១.៣. ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ

**រូបភាពទី៣៖ការអនុវត្តកិច្ចប្រជុំតាមផែនការសកម្មភាពប្រចាំឆ្នាំ**



កិច្ចប្រជុំទាំងឡាយដំណើរការទៅបានអាស្រ័យលើផែនការសកម្មភាពប្រចាំឆ្នាំដែលបានឯកភាពគ្នាក្នុងរយៈពេលមួយឆ្នាំនឹងសម្រេចលទ្ធផលគ្រោងទុក ដែលបានរំលេចក្នុងរបៀបវារៈ ប៉ុន្តែក៏មានរបៀបវារៈមិនបានអនុវត្តតាមទាំងស្រុង ដោយសារមានបញ្ហាប្រឈមមួយចំនួនបង្កភាពរាំងស្ទះដល់ដំណើរការកិច្ចប្រជុំ។ ផែនការសកម្មភាពនៃក្រុមការងារនេះត្រូវរៀបចំឡើងដើម្បីកំណត់ថារាល់កិច្ចប្រជុំនីមួយៗមានវត្ថុបំណងនិងគោលដៅច្បាស់លាស់ជាស្រេច ប៉ុន្តែក៏មានភាពបទបែនតាមស្ថានភាពជាក់ស្តែង។ ការអនុវត្តតាមផែនការសកម្មភាពចង់បង្ហាញពីភាពទៀងទាត់តាមដំណាក់កាល(៤ត្រីមាស/ឆ្នាំ) បើតាមរូបភាពបង្ហាញថា ការអនុវត្តតាមផែនការមាន៦៧.៦%មានន័យថា ការអនុវត្តតាមផែនការមិនបានទាំងស្រុងដោយសារមានបញ្ហាប្រឈមមួយចំនួនដែលតម្រូវឱ្យមានភាពបទបែនការអនុវត្តយ៉ាងហោចណាស់ក៏មាន៣២.៤%។

## ៤.២. ការកំណត់កាលបរិច្ឆេទកិច្ចប្រជុំ

ការកំណត់កាលបរិច្ឆេទគឺជាផ្នែកដ៏សំខាន់ចាំបាច់ក្នុងការធានាបានការដំណើរការកិច្ចប្រជុំតាមផែនការកំណត់ ដែលតម្រូវពិនិត្យពីសមាសភាពពាក់ព័ន្ធកម្រិតខ្ពស់និងមានឥទ្ធិពលក្នុងការសម្រេចចិត្ត និងសម្រាប់អ្នកចូលរួមទាំងអស់។ បើតាមការសិក្សាពីសមាជិកនៃក្រុមការងារនេះបានបង្ហាញពីសមាសភាពដែលអាចមានលទ្ធភាពកំណត់កាលបរិច្ឆេទសម្រាប់ដំណើរប្រជុំ៖

**រូបភាពទី៤៖អ្នកកំណត់កាលបរិច្ឆេទប្រជុំ**




ការកំណត់កាលបរិច្ឆេទចាំបាច់ត្រូវមានការឯកភាពគ្នា ដើម្បីកំណត់យកកាលបរិច្ឆេទប្រជុំជាក់លាក់ក្នុងនោះអ្នកដែលមានសិទ្ធិសម្រេចគឺជាប្រធានក្រុមការងារ ប៉ុន្តែក៏ត្រូវការឆ្លងយោបល់ពីអ្នកពាក់ព័ន្ធផ្សេងទៀតដែលជាតួអង្គសំខាន់។ បើតាមរូបភាពទី៤ បានបង្ហាញថាសមាសភាពសំខាន់ដែលអាចកំណត់កាលបរិច្ឆេទជាបឋមនោះគឺប្រធានមន្ទីរអ.យ.កមាន២២% ប្រធានក្រុមការងារវិស័យអប់រំ(P-ESWG)មាន២០% និងលេខាធិការដ្ឋានមាន១៧%។ ដូច្នេះការកំណត់កាល

បរិច្ឆេទជារួមគឺអាស្រ័យលើប្រធានមន្ទីរអេយក លេខាធិការដ្ឋាន និងក្រុមការងារវិស័យអប់រំ អាចមានលទ្ធភាពជារួមប្រមាណជាង៦០%។

## ៤.៣. នីតិវិធីកំណត់របៀបវារៈសម្រាប់កិច្ចប្រជុំ

របៀបវារៈគឺជាកម្មវិធីសំខាន់សម្រាប់ឱ្យសមាជិកទាំងអស់យល់ពីវត្ថុបំណង និងលទ្ធផលរំពឹងទុកនៃកិច្ចប្រជុំនីមួយៗប្រកបដោយភាពច្បាស់លាស់។

### ៤.៣.១. ការពិនិត្យលើផ្នែកពាក់ព័ន្ធ

**រូបភាពទី៥៖ ផ្នែកពាក់ព័ន្ធ**




ការកំណត់របៀបវារៈប្រជុំគឺ ត្រូវបានជ្រើសរើសចេញពីផែនការសកម្មភាពប្រចាំឆ្នាំជាគោលដែលបានឯកភាពគ្នារវាងសមាជិកនៃក្រុមការងារនេះ ប៉ុន្តែក៏មានការបទបែនតាមស្ថានភាពជាក់ស្តែងណាមួយ។ បើតាមរូបភាពទី៥ បង្ហាញថារបៀបវារៈភាគច្រើនត្រូវបានជ្រើសរើសពីផែនការសកម្មភាពមាន៣០% តាមរយៈការស្នើរបស់ក្រុមការងារវិស័យអប់រំមាន២៤% ប៉ុន្តែក៏មានការស្នើពីមន្ទីរវិស័យមាន១៦% និងតាមការចាំបាច់មាន១៧%។ ដូច្នេះ ការកំណត់របៀបវារៈភាគច្រើនផ្អែកតាមផែនការសកម្មភាពប្រចាំឆ្នាំ និងការស្នើរបស់ដៃគូអភិវឌ្ឍន៍ ប៉ុន្តែក្នុងនោះក៏មានភាពបទបែនតាមស្ថានភាពជាក់ស្តែង នេះមានន័យថាការកំណត់របៀបវារៈមិនត្រូវបានជ្រើសរើសចេញពីផែនការសកម្មភាពមានរហូតដល់ប្រមាណជាង៧០%។

## ៤.៣.២. ការពិគ្រោះយោបល់

**រូបភាពទី៦៖ការឆ្លងយោបល់លើរបៀបវារៈ**




កំណត់របៀបវារៈត្រូវបានធ្វើឡើងដោយមានការឆ្លងយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះឆ្លងយោបល់ពីថ្នាក់ដឹកនាំមន្ទីរអ.យ.កមាន២៩% ប្រធានក្រុមការងារវិស័យអប់រំមាន២៣% និងប្រធានក្រុមការងារដែលមានសមាសប្រធានមន្ទីរឬគណៈអភិបាលខេត្តមាន១៨% និងប្រធានការិយាល័យជំនាញនីមួយៗជាសមាជិកមាន១៦%។ ដូច្នេះ ការឆ្លងរយោបល់លើរបៀបវារៈបានបង្ហាញពីផ្នែកសំខាន់និងមានសិទ្ធិសម្រេចរួមមានថ្នាក់ដឹកនាំមន្ទីរ និងប្រធានក្រុមការងារវិស័យអប់រំដែលមានទំនាក់ទំនង និងកិច្ចសហការជិតស្និទ្ធ។

## ៤.៣.៣. ខ្លឹមសាររបៀបវារៈ

**រូបភាពទី៧៖របៀបវារៈពាក់ព័ន្ធ**




បើតាមរូបភាពទី៧នេះបង្ហាញថារបៀបវារៈមានពាក់ព័ន្ធទៅនឹងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP)មាន១៩%ជាការងារប្រចាំឆ្នាំ ការដោះស្រាយបញ្ហាប្រឈមមាន១៦% និងការងារអភិវឌ្ឍន៍វិស័យអប់រំក្នុងខេត្តក៏ដូចក្នុងមូលដ្ឋានរួមមាន៖របាយការណ៍សន្និបាតអប់រំ ការងារតាមការិយាល័យជំនាញ និងការងារចូលរួមសហការក្នុងវិស័យអប់រំពីដៃគូអភិវឌ្ឍមានប្រមាណជា១០%។ ដូច្នេះជារួម របៀបវារៈដែលជាអាទិភាពសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះមានរឿង

ច្រើនត្រូវពិភាក្សារួមគ្នាដោះស្រាយសម្រាប់វិស័យអប់រំភាគច្រើនត្រូវបានលើកក្នុងកិច្ចប្រជុំគឺ ការរៀបចំផែនការប្រតិបត្តិ(AOP) និងការដោះស្រាយបញ្ហាប្រឈម។

### ៤.៣.៤. ទិស័យពាក់ព័ន្ធនឹងរបៀបវារៈ

**រូបភាពទី៨៖ របៀបវារៈដែលពាក់ព័ន្ធទៅតាមវិស័យនីមួយៗ**




| | 80%-100% | 60%-80% | 50% | 20%-40% | 0%-20% |
|---|---|---|---|---|---|
| ពាក់ព័ន្ធនឹងមន្ទីរអេយក | 56.1% | 36.0% | 4.3% | 2.9% | 0.7% |
| ពាក់ព័ន្ធនឹងមន្ទីរវិស័យ | 8.6% | 23.0% | 18.7% | 28.8% | 20.9% |
| ដៃគូអភិវឌ្ឍន៍ | 24.5% | 20.9% | 26.6% | 21.6% | 6.5% |

រូបភាពទី៨ បង្ហាញថារបៀបវារៈមានភាពពាក់ព័ន្ធភាគច្រើនទៅនឹងមន្ទីរអេយកមានជាង ៥៦% មន្ទីរវិស័យមានត្រឹមតែ៨.៦% និងដៃគូអភិវឌ្ឍន៍មាន២៤.៥% ប៉ុន្តែបើពិនិត្យមើលពីភាពពាក់ព័ន្ធតិចតួចវិញ០-២០% មន្ទីរអេយកសឹងតែគ្មាន ដៃគូអភិវឌ្ឍន៍មានតែ៦.៥% ដោយឡែកមន្ទីរវិស័យពាក់ព័ន្ធវិញមានជាង២០.៩%។ ដូចនេះ ជារួមបង្ហាញថាពាក់ព័ន្ធនឹងវិស័យអប់រំឈានមុខគេ និងនាំមុខបន្ទាប់មានដៃគូអភិវឌ្ឍន៍ប៉ុន្តែពាក់ព័ន្ធនឹងមន្ទីរវិស័យមិនសូវបានលើកយកមកពិភាក្សាដោយក្រុមការងារនេះគេនិយាយផ្តោតតែលើវិស័យអប់រំ ដោយមន្ទីរវិស័យគឺជាចំណែកមួយសម្រាប់គាំទ្រ និងសហការដោយមិនមានសកម្មភាពស៊ីជម្រៅទៅលើការងារអប់រំ។

### ៤.៣.៥. ប្រធានបទនៃរបៀបវារៈ

**រូបភាពទី៩៖ប្រធានបទក្នុងកិច្ចប្រជុំ**




ប្រធានបទមានភាពបទបែនច្រើន និងតាមការចាំបាច់អាស្រ័យលើតម្រូវការដោះស្រាយបញ្ហាប្រឈមនានា និងការងារបច្ចេកទេសផ្សេងៗ ត្រូវការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ ជាមួយគ្នានេះ បើតាមរូបភាពខាងលើ បង្ហាញថាប្រធានបទសំខាន់ ឬត្រូវបានលើកយកពិភាក្សាជាអាទិភាពដែលពាក់ព័ន្ធនឹងវិស័យអប់រំ នៅតែមានភាពពាក់ព័ន្ធមិនអាចខ្វះបាន ដូចជា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ សន្និបាតអប់រំខេត្ត និងវឌ្ឍនភាពការងាររបស់ក្រុមP-ESWGជាដើម។

## ៤.៤. ការសម្របសម្រួលរបស់លេខាធិការដ្ឋាន

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តមានលេខាធិការដ្ឋានមួយដែលមានការិយាល័យផែនការ និងគ្រប់គ្រងជំនួយនៃមន្ទីរអប់រំ យុវជន និងកីឡា និងប្រធានការិយាល័យជាប្រធានដែលមានតួនាទី និងភារកិច្ចជាច្រើនក្នុងការរៀបចំដំណើរការកិច្ចប្រជុំ និងការសម្របសម្រួលនានាជាមួយអ្នកពាក់ ព័ន្ធទាំងអស់ដែលជាសមាជិកនៃក្រុមការងារ។ ខាងក្រោមបានបង្ហាញពីការសិក្សាលើការងារជាប្រចាំដែលលេខាធិការដ្ឋានបានអនុវត្តកន្លងមក៖

## រូបភាពទី១០៖ការសម្របសម្រួលរបស់លេខាធិការដ្ឋាន




រូបភាពនេះ បង្ហាញថាការសម្របសម្រួលរបស់លេខាធិការដ្ឋានស្ថិតក្នុងកម្រិតល្អប្រសើរភាគច្រើនបើធៀបទៅនឹងកម្រិតត្រូវលម្អគិតជាមធ្យមប្រមាណជាង១%។ ដូចនេះលទ្ធផលដូចបានបង្ហាញអាចកំណត់បានថា លេខាធិការដ្ឋានត្រូវបន្តការអនុវត្តនូវយន្តការសម្របសម្រួលទាំងនេះ ដើម្បីរក្សាបាននូវប្រសិទ្ធភាពនៃដំណើរកិច្ចប្រជុំក្រុមការងារនេះ។

### ៤.៥. ការរៀបចំបទបង្ហាញក្នុងកិច្ចប្រជុំ

ការរៀបចំបទបង្ហាញត្រូវបានផ្តល់អាទិភាពដល់សមាជិកពាក់ព័ន្ធ ដែលមានបំណងចង់បង្ហាញពីវឌ្ឍនភាពការងារអភិវឌ្ឍន៍វិស័យអប់រំដែលខ្លួនបានអនុវត្តមកបង្ហាញក្នុងអង្គប្រជុំសម្រាប់ជាការចែករំលែក បញ្ហាប្រឈម និងការរកដំណោះស្រាយក្នុងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំក្នុងរាជធានីខេត្ត។ ការសិក្សាបានបង្ហាញពីផ្នែកពាក់ព័ន្ធសំខាន់ៗលើកយកប្រធានបទរបស់ខ្លួនមកពិភាក្សាដូចខាងក្រោម៖

**រូបភាពទី១១៖បទបង្ហាញរបស់អ្នកពាក់ព័ន្ធ**




ការកំណត់អ្នកទទួលខុសត្រូវលើប្រធានបទឬបទបង្ហាញពីភាពជាម្ចាស់ដែលបង្ហាញពីការចូលរួមនិងភាពពាក់ព័ន្ធផងដែរ បើពិនិត្យពីរូបភាពទី៩ខាងលើបង្ហាញថាប្រធានមន្ទីរអយក១៧% លេខាធិការដ្ឋាន២៣% និងក្រុមការងារវិស័យអប់រំ ២៤% នេះមានន័យថាផ្នែកទាំងបីនេះមានភាពសកម្មជាងមន្ទីរវិស័យឬផ្នែកដទៃដែលមិនសូវពាក់ព័ន្ធបើគិតជារួមមានរហូតដល់ជាង៨៩% បើធៀបនឹងមន្ទីរពាក់ព័ន្ធមានត្រឹមតែ១១% ក្នុងន័យនេះ មានតែជនបង្គោលដឹកនាំ និងអ្នកអនុវត្តសកម្មភាពផ្ទាល់ពាក់ព័ន្ធទៅនឹងវិស័យអប់រំ។

## ៤.៦. ការដំណើរការកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

ការអនុវត្តកិច្ចប្រជុំតាមផែនការសកម្មភាពប្រចាំឆ្នាំបានឆ្លុះបញ្ចាំងពីភាពទៀងទាត់ និងការប្តេជ្ញារបស់ថ្នាក់ដឹកនាំ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ក្នុងការជំរុញឱ្យមានដំណើរការក្រុមការងារនេះពីមួយត្រីមាសទៅមួយត្រីមាស ម្យ៉ាងវិញទៀតដើម្បីកំណត់បានពីលទ្ធភាពដែលអាចប្រព្រឹត្តិទៅបានក្នុងរយៈពេលមួយឆ្នាំមាន៤ត្រីមាសឬ៤ដង នៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។ តាមរយៈការសិក្សាបានបង្ហាញពីការយល់ឃើញរបស់សមាជិកទៅលើចំនួនកិច្ចប្រជុំដែលអាចអនុវត្តបានក្នុងមួយឆ្នាំ ដូចខាងក្រោម៖

## ៤.៦.១. ចំនួនកិច្ចប្រជុំប្រចាំឆ្នាំ

**រូបភាពទី១២៖ដំណើរការកិច្ចប្រជុំប្រចាំឆ្នាំ**




យោងតាមសេចក្តីណែនាំលេខ០០៤ នៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិបានកំណត់ថាដំណើរប្រជុំយ៉ាងតិច៤ដងក្នុង១ឆ្នាំ(៤តីមាស/ឆ្នាំ) មានន័យថា១ត្រីមាសប្រជុំមួយដង។ បើតាមរូបភាពនេះបង្ហាញថា កិច្ចប្រជុំសម្រាប់រាជធានីខេត្តនៃក្រុមការងារនេះត្រូវបានអនុវត្តជាមធ្យមក្នុងចន្លោះពី៣-៤ដងក្នុងមួយឆ្នាំ ដែលនេះជាការយល់ជាទូទៅថាការដំណើរការកិច្ចប្រជុំត្រូវសម្រេចឱ្យបានតាមការណែនាំយ៉ាងតិចបំផុតបាន៤ដង/ឆ្នាំ និងបានរៀបចំដាក់បញ្ចូលក្នុងផែនការកម្មភាពប្រចាំឆ្នាំជាទូទៅ។

## ៤.៦.២. ការដឹកនាំកិច្ចប្រជុំ

**រូបភាពទី១៣៖អ្នកដឹកនាំកិច្ចប្រជុំ**




ថ្នាក់ដឹកនាំនៃអង្គប្រជុំគឺជាបុគ្គលដ៏មានឥទ្ធិពល និងការសម្រេចចិត្តខ្ពស់ ដើម្បីធានាបាននូវលទ្ធផលនៃកិច្ចប្រជុំប្រកបដោយផ្លែផ្កា។ ចំពោះរូបភាពនេះបង្ហាញថាថ្នាក់ដឹកនាំមន្ទីរគឺជាជនបង្គោលដែលមិនអាចខ្វះបានទោះបីមានវត្តមានឬអវត្តមានប្រធានកិត្តិយស សម្រាប់ដឹកនាំគ្រប់ដំណើរការកិច្ចប្រជុំមាន៦៣.៣% បើធៀបនឹង ប្រធានកិត្តិយសមានត្រឹមតែ២៩.៥%។

### ៤.៦.៣. ការចូលរួមកិច្ចប្រជុំ

#### ក. ផ្នែកពាក់ព័ន្ធចូលរួម

**រូបភាពទី១៤៖ផ្នែកពាក់ព័ន្ធចូលរួមកិច្ចប្រជុំ**




ដំណើរការកិច្ចប្រជុំកើតឡើងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដែលជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ បើតាមរូបភាពបង្ហាញថាគ្រប់ភាគីពាក់ព័ន្ធចាំបាច់ត្រូវមានការចូលរួមក្នុងកម្រិតមួយសមស្របទោះបីការចូលរួមនោះនៅមានកម្រិតក៏ដោយ ក្នុងនោះរួមមានផ្នែករដ្ឋបាលសាលាខេត្តមានតែ៦.២% និងអ្នកពាក់ព័ន្ធផ្សេងទៀតមាន២.៣% ហាក់ដូចជាពុំមានការពាក់ព័ន្ធ ឬដំណើរកិច្ចប្រជុំពុំមានភាពទាក់ទាញ។ ដូច្នេះ មន្ទីរអប់រំ យុវជន និងកីឡា ឬលេខាធិការដ្ឋាន ក៏ដូចជាក្រុមការងារវិស័យអប់រំ(P-ESWG) គួរពិនិត្យឡើងវិញ និងកំណត់វិធីសាស្ត្របែបណាដើម្បីទទួលបានការចូលរួមមួយសមស្រប។

#### ខ. សមាសភាពចូលរួមជាប្រចាំ

**រូបភាពទី១៥៖សមាសភាពពាក់ព័ន្ធបានចូលរួមជាប្រចាំ**



ក្នុងកិច្ចប្រជុំត្រូវបានចូលរួមពីភាគីពាក់ព័ន្ធនិងជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ បើតាមរូបភាពនេះបង្ហាញថាសមាជិកមួយចំនួនមិនសូវបានចូលរួមញឹកញាប់រួមមានរដ្ឋបាលសាលារាជធានីខេត្ត មាន៨% និងមន្ទីរវិស័យពាក់ព័ន្ធ១៤.១%បើធៀបនឹងការិយាល័យរបស់មន្ទីរអេយក២០.៤% និងតំណាងដៃគូអភិវឌ្ឍន៍(P-ESWG)មាន២១.៤%។ ដូចនេះ ជាទូទៅសមាជិកដែលមានវត្តមានជាប្រចាំគឺការិយាល័យរបស់មន្ទីរអ.យ.កខ្លួនឯងផ្ទាល់ ក្រុមការងារវិស័យអប់រំ(P-ESWG) និងមន្ទីរវិស័យពាក់ព័ន្ធ។

### គ. ថ្នាក់ដឹកនាំចូលរួម

**រូបភាពទី១៦៖ថ្នាក់ដឹកនាំបានចូលរួម**




សមាសភាពនៃសមាជិកក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំដែលបានចូលរួមកិច្ចប្រជុំ បានបង្ហាញតាមរូបភាពខាងលើនេះអាចកំណត់បានថាចាប់ពីប្រធានក្រុមការងារ និងអនុប្រធាន ដែលទទួលបន្ទុកការងារវិស័យអប់រំ ដោយឡែកគណៈភិបាលខេត្តឬប្រធានកិត្តិយស បានចូលរួម ម្តងម្កាល៧.៦% និងជាតំណាងឬមន្ត្រីមានប្រហែល១០% បានចូលរួមកិច្ចប្រជុំ។

## ៤.៦.៤. ការផ្តល់យោបល់របស់សមាជិកក្នុងកិច្ចប្រជុំ

**តារាទី១៧៖ការផ្តល់យោបល់របស់សមាជិកក្នុងកិច្ចប្រជុំ**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ល្អណាស់ | 5 | 3.6 | 3.6 | 3.6 |
| | ល្អ | 78 | 56.1 | 56.1 | 59.7 |
| | បង្គួរ | 44 | 31.7 | 31.7 | 91.4 |
| | មធ្យម | 11 | 7.9 | 7.9 | 99.3 |
| | គ្មានយោបល់ | 1 | 0.7 | 0.7 | 100.0 |
| | Total | 139 | 100.0 | 100.0 | |

ដើម្បីឱ្យលទ្ធផលនៃកិច្ចប្រជុំទទួលបានជាតុចូលគ្រប់គ្រាន់ និងអាចដោះស្រាយបញ្ហាដែលបានលើកឡើងជុំវិញដល់សមាសភាពនីមួយៗផ្តល់យោបល់ក្នុងកម្រិតបច្ចេកទេសនិងកម្រិតថ្នាក់ដឹកនាំ ដូចក្នុងតារាងនេះបានបង្ហាញថាការផ្តល់យោបល់ឈរក្នុងកម្រិតល្អប្រសើរ មានន័យថាការផ្តល់យោបល់មានភាពសកម្មនិងផុសផុលដើម្បីធ្វើឱ្យលទ្ធផលនៃកិច្ចប្រជុំទទួលបានផ្លែផ្កា។

### ៤.៦.៥. ការរៀបចំរបាយការណ៍កិច្ចប្រជុំ

#### ក. អ្នកចូលរួមរៀបចំរបាយការណ៍

**តារាងទី១៨៖អ្នកចូលរួមរៀបចំរបាយការណ៍នៃកិច្ចប្រជុំ**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ថ្នាក់ដឹកនាំមន្ទីរអេយក | 5 | 3.6 | 3.6 | 3.6 |
| | លេខាធិការដ្ឋាន | 58 | 41.7 | 41.7 | 45.3 |
| | ថ្នាក់ដឹកនាំនិងលេខាធិការដ្ឋាន | 25 | 18.0 | 18.0 | 63.3 |
| | ថ្នាក់ដឹកនាំ លេខាធិការដ្ឋាន និងក្រុមការងារវិស័យអប់រំ | 33 | 23.7 | 23.7 | 87.1 |
| | ថ្នាក់ដឹកនាំ លេខាធិការដ្ឋាន ក្រុមការងារវិស័យអប់រំ និង មន្ទីរវិស័យ | 17 | 12.2 | 12.2 | 99.3 |
| | មិនមានការចូលរួម | 1 | 0.7 | 0.7 | 100.0 |
| | Total | 139 | 100.0 | 100.0 | |

ការរៀបចំរបាយការណ៍មួយមានគុណភាពចាំត្រូវមានការផ្តល់ធាតុចូលបន្ថែមនិងមានការចូលរួមពីអ្នកពាក់ព័ន្ធជាពិសេសពីភាគីទទួលបន្ទុកផ្ទាល់ដូចជាមន្ទីរអេយករួមមាន៖ ថ្នាក់ដឹកនាំមន្ទីរ និង លេខាធិការដ្ឋាន និងក្រុមការងារវិស័យអប់រំ(ESWG)។ បើតាមរូបភាពខាងលើបង្ហាញថា លេខាធិការដ្ឋានមានភារកិច្ចរៀបចំរបាយការណ៍តែម្នាក់ឯងរហូតដល់៤១.៧% បើធៀបនឹងការរៀបចំរបាយការណ៍ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរ និងក្រុមP-ESWG មានត្រឹមតែ២៣.៧% ប៉ុន្តែបើធៀបនឹងការចូលរួមរៀបចំមកពីគ្រប់ភាគីវិញភាគរយគំលាតគ្នាឆ្ងាយ មានប្រមាណ១២%។

### ខ. រយៈពេលរៀបចំរបាយការណ៍

**រូបភាពទី១៩៖ រយៈពេលរៀបចំរបាយការណ៍**




ការរៀបចំរបាយការណ៍ត្រូវការពេលវេលា និងការពិភាក្សាលើខ្លឹមសារតាមស្មារតីអង្គប្រជុំ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ រូបភាពខាងលើបង្ហាញថា ពេលវេលាសមស្របអាចប្រើរយៈពេលយ៉ាងហោចណាស់១សប្តាហ៍មាន៥០.៤% និងចាប់ពី១សប្តាហ៍ឡើងមាន២៣.៧% និងច្រើនជាង២សប្តាហ៍ក៏មាន ដែលឆ្លុះបញ្ចាំងពីសមត្ថភាព និងពេលវេលាសមស្របតាមស្ថានភាពជាក់ស្តែងនៃរាជធានីខេត្តនីមួយៗ ដូច្នេះ ការរៀបចំរបាយការណ៍ត្រូវចំណាយពេលវេលាយ៉ាងហោចណាស់ក៏មួយសប្តាហ៍។

### គ. គុណភាពនៃរបាយការណ៍

**រូបភាពទី២០៖ ខ្លឹមសារនៃរបាយការណ៍**




ខ្លឹមសាររបាយការណ៍អង្គប្រជុំ បង្ហាញពីលទ្ធផលបន្ទាប់ពីពិភាក្សាគ្រប់ជ្រុងជ្រោយដើម្បីជាមូលដ្ឋានក្នុងការអនុវត្តនិងដោះស្រាយរួមគ្នាប្រកបដោយប្រសិទ្ធភាព។ បើតាមរូបភាពខាង លើបង្ហាញថា ខ្លឹមសារនៃរបាយការណ៍ក្នុងកម្រិតមួយល្អប្រសើរ ទោះបីមានចំណុចត្រូវកែលម្អតិចតួចក្តីក៏អាចមានលទ្ធភាពកែលម្អចំណុចខ្វះខាតនាពេលអនាគតបាន។

### ឃ. ការចែករំលែករបាយការណ៍

**រូបភាពទី២១៖ការចែករំលែករបាយការណ៍កិច្ចប្រជុំ**




ការចែករំលែកព័ត៌មានផ្សេងៗជាពិសេសរបាយការណ៍នៃកិច្ចប្រជុំនីមួយៗទៅដល់អ្នកពាក់ព័ន្ធដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពការងារនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។ តាមរូបភាពខាងលើបង្ហាញថារបាយការណ៍មិនត្រូវបានផ្តល់ដល់អ្នកពាក់ព័ន្ធបានពេញលេញនោះទេ ឬការផ្តល់ របាយការណ៍នៅមានកម្រិត បើពិនិត្យមើផ្នែកដែលពាក់ព័ន្ធខ្លាំងដូចជា៖ ការិយាល័យជំនាញពាក់ព័ន្ធមានតែ២០.៨% ក្រុមការងារវិស័យអប់រំ(ESWG)មាន២១.៣% ដោយឡែក មន្ទីរវិស័យវិញមានតែ ០.៧%ប៉ុណ្ណេះ។ ដូចនេះតម្រូវមន្ទីរអប់រំ យុវជន និងកីឡា ឬលេខាធិការដ្ឋាន ចែករំលែកព័ត៌មានឬរបាយករណ៍លទ្ធផលកិច្ចប្រជុំទៅដល់សមាជិកទាំងអស់ ជាពិសេសមន្ទីរវិស័យពាក់ព័ន្ធ។

*២. តើក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តមានបញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ/អនុសាសន៍អ្វីខ្លះ?*

### ៤.៧. បញ្ហាប្រឈមដែលកើតមាន

**រូបភាពទី២២៖បញ្ហាប្រឈមនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ**




បញ្ហាប្រឈមនៃក្រុមការងារនេះបានធ្វើឱ្យប៉ះពាល់ដល់ដំណើរ និងលទ្ធផលនៃកិច្ចប្រជុំនេះផងដែរ តាមរយៈដ្យាក្រាមនេះបានកំណត់ពីបញ្ហាប្រឈមគន្លឹះដែលតែងតែកើតមានសម្រាប់ក្រសួង អប់រំយុវជន និងកីឡា និងថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ពិនិត្យលទ្ធភាពឬវិធាន

ការដោះស្រាយរួមគ្នា។ ដូច្នេះតាមរយៈរូបភាពខាងលើ បង្ហាញពីការយល់ឃើញថាមន្ទីរអេយកឬលេខាធិការដ្ឋានគួរយកចិត្តទុកដាក់ទៅលើការរៀបចំកិច្ចប្រជុំក្រុមការងារនេះតាមផែនការសកម្ម-ភាពប្រចាំមាន១២.៩% ការកំណត់សមាសភាពចូលរួមក៏ជាកត្តាសំខាន់ក្នុងការធានាបានការផ្តល់ធាតុចូលឆ្លើយតបមាន១១.៦% ទៅ១៥.១% ជាមួយគ្នានេះដែរ ភាពមមាញឹកនឹងការងាររបស់សមាជិកនីមួយៗដោយសារកត្តាផ្សេងៗត្រូវយកចិត្តទុកនិងកែលម្អឡើងវិញមាន១៦.៦%។

## ៤.៨. ដំណោះស្រាយ

**រូបភាពទី២៣៖ដំណោះស្រាយសម្រាប់បញ្ហាប្រឈម**




តាមរូបភាពខាងលើនេះ បង្ហាញថាដំណោះស្រាយជាគន្លឹះមានច្រើនប៉ុន្តែត្រូវពិនិត្យពីលទ្ធភាពណាខ្លះអាចដោះស្រាយបាន ក្នុងនោះរួមមាន៖ ការផ្តល់ដំណឹងឬចែករំលែកព័ត៌មានដែលបង្ហាញពីកិច្ចសហការនិងការទំនាក់ទំនង ជំរុញធ្វើយ៉ាងណាឲ្យថ្នាក់ដឹកនាំមានការប្តេជ្ញាអនុវត្តកិច្ចប្រជុំតាមផែនការ ការពិនិត្យតាមដាននិងវាយមតម្លៃត្រូវយកចិត្តទុកដើម្បីបង្ហាញពីយន្តការវាយតម្លៃប្រសិទ្ធភាពនៃកិច្ចប្រជុំ និងដំណោះស្រាយដទៃទៀតទៅតាមបរិបទឬស្ថានភាពនៃរាជធានីខេត្ត។

## ៤.៩. សំណូមពរ

បើតាមរយៈការបកស្រាយពីការយល់ឃើញរបស់សំណាក បានបង្ហាញពីការយកចិត្តទុកដាក់លើផ្នែកសំខាន់ៗជាច្រើន ជាមួយគ្នានោះអ្នកស្រាវជ្រាវបានសំយោគយកការសំណូមពរគន្លឹះដូចខាងក្រោម៖

## រូបភាពទី២៤៖សំណូមពររបស់សមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ




តាមរយៈរូបភាពនេះ បង្ហាញពីការយល់ឃើញពីសំណូមពរជាអាទិភាពសម្រាប់ក្រសួងអប់រំ យុវជននិងកីឡា និងជាពិសេសនាយកដ្ឋានផែនការដែលជាលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្តសម្រាប់ជាមូលដ្ឋានក្នុងការពិចារណានិងពិភាក្សាបន្តទៀត។ ដូចនេះចំពោះការរៀបចំសេចក្តីណែនាំថ្មីនៃក្រុមការងារនេះគឺជាតម្រូវការដ៏ចាំបាច់មួយដែលសេចក្តីណែនាំចាស់នៅមិនទាន់មានការបញ្ជាក់បានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវមានជិត២៦% ដោយឡែកការផ្តល់ថវិកាសម្រាប់ដំណើរការកិច្ចប្រជុំបានគ្រប់គ្រាន់គួរគិតពិចារណានិងយកចិត្តទុកដាក់មាន២៦% និងផ្នែកផ្សេងទៀតក៏មិនត្រូវមើរំលងដែរ ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ .សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សានិងវិភាគតាមខ្លឹមសារនៃសំណួរខាងលើបានឆ្លុះបញ្ចាំងពីភាពពាក់ព័ន្ធគ្នាជាច្រើន ដែលជាយន្តការចំបាច់សម្រាប់ពិចារណាក្នុងការកែលម្អការអនុវត្តរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តកាន់តែមានភាពប្រសើរ រួមទាំងដំណោះស្រាយនិងអនុសាសន៍ក្នុងកម្រិតពិភាក្សាមួយសម្រាប់អភិវឌ្ឍន៍វិស័យអប់រំនៅថ្នាក់រាជធានីខេត្ត។ ឆ្លើយតបទៅនឹងគោលបំណង និងសំណួរស្រាវជ្រាវដែលបានលើកឡើងក្នុងជំពូកទី១ ក្រោមប្រធានបទ «ទស្សនៈការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត» អ្នកស្រាវជ្រាវបានសិក្សាឃើញយន្តការបីសំខាន់ព្រមទាំងបញ្ហាប្រឈម និងដំណោះស្រាយ ដូចខាងក្រោម៖

**១. ការដំណើរការមុនកិច្ចប្រជុំ**៖បានផ្តោតសំខាន់លើការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដែលត្រូវចាំបាច់ត្រូវមានការការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធក្នុងការកំណត់បាននូវលទ្ធផលរំពឹងទុកដែលបានពិភាក្សា និងឯកភាពរួមគ្នាសម្រេចបានដើម្បីលើកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍន៍វិស័យអប់រំក្នុងមូលដ្ឋានឲ្យឆ្លើយតបនឹងកំណែទម្រង់វិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តសាមីដូចជា៖

- ការរៀបចំផែនការសកម្មភាពនៃក្រុមការងារនេះ ពិតជាមានការចូលរួមពីអ្នកពាក់ព័ន្ធដែលជាដៃគូសហការ និងគាំទ្រដល់ដំណើរការអភិវឌ្ឍន៍វិស័យអប់រំក្នុងមូលដ្ឋាន ដោយឡែកការចូលរួមនៅមានកម្រិត មានន័យថា ការចូលរួមខ្លាំងសម្រាប់កិច្ចការនេះមានតែពីភាគីមន្ទីរអប់រំ យុវជន និងកីឡា និងក្រុមការងារវិស័យអប់រំដែលបានបង្ហាញពីអ្នកពាក់ព័ន្ធដ៏ទៀតក៏ជាសមាជិកបានចូលរួមក្នុងសកម្មភាពនៃក្រុមការងារនេះនៅមានកម្រិត ដូចនេះត្រូវស្វែងរកវិធីសាស្ត្របន្ថែមដើម្បីទាក់ទាញពួកគាត់បានចូលរួមជាអតិបរមា។

- ចំពោះការរៀបចំផែនការសកម្មភាពនេះ គឺជាផែនទីបង្ហាញផ្លូវសំខាន់សម្រាប់ដើរឆ្ពោះទៅសម្រេចគោលដៅតាមរយៈរបៀបវារៈ និងប្រធានបទ ធ្វើយ៉ាងណាឱ្យមានការឆ្លើយតប បើតាមការសិក្សាខាងលើរូបភាពទី២ បង្ហាញថារបៀបវារៈដែលត្រូវយកមកពិភាក្សាពិតជាបានផ្សារភ្ជាប់នឹងដំណោះស្រាយបញ្ហាប្រឈមនៅថ្នាក់រាជធានីខេត្តឬថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍន៍វិស័យអប់រំ ដោយមិនផ្តោតតែលើការងារជំនាញតាមការិយាល័យនោះទេ។ ដោយឡែកចំពោះការអនុវត្តតាមផែនការសកម្មភាពប្រចាំឆ្នាំវិញមិនទាន់បានពេញលេញតាមផែនការកំណត់ បើតាមរូប

ភាពទី៣ មានជាង៦៧.៦%បានអនុវត្តតាមផែនការ និងបានដំណើរប្រជុំតាមផែនការបាន ៣ដង ឬ ៣ត្រីមាស/៤ត្រីមាសក្នុងមួយឆ្នាំជារួមមានជាង៦៥%(រូបភាពទី១២) ក្រៅពីនេះបញ្ហាចាំបាច់ផ្សេងទៀតក៏ត្រូវបានដោះស្រាយ។

- ចំពោះការកំណត់របៀបវារៈនេះក៏បង្ហាញពីកិច្ចសហការ និងចូលរួមចំណែកក្នុងការតម្រង់ទិសក្នុងនោះបានការសិក្សាបង្ហាញថារបៀបវារៈជាបឋម ត្រូវពឹងផ្អែកលើផែនការសកម្មភាព ការស្នើបញ្ចូលអ្វីថ្មីបន្ថែមពីតំណាងដៃគូអភិវឌ្ឍន៍ និងទៅតាមភាពទន់ភ្លន់តាមតម្រូវការ ក្នុងមូលដ្ឋាន។ ជាមួយគ្នានេះ ខ្លឹមសាររបៀបវារៈជារឿងសំខាន់ដើម្បីបង្ហាញពីវត្ថុបំណង និងលទ្ធផលរំពឹងដែលចង់បានមានភាពច្បាស់លាស់ ក្នុងនោះ ការសិក្សាបង្ហាញជារួមគឺការលើកយកបញ្ហាប្រឈមមកដោះស្រាយ និងការងារបច្ចេកទេសក្នុងអង្គភាពមន្ទីរអប់រំ យុវជន និងកីឡាមានភាគច្រើន(រូបភាពទី៧) ហាក់ដូចជាមិនសូវបានលើកយកបញ្ហាតាមការិយាល័យ ឬពីផ្នែកពាក់ព័ន្ធដទៃទៀតឲ្យបានច្រើនជាអាទិបរមា រួមមាន៖ ការងារអភិវឌ្ឍន៍វិស័យអប់រំរបស់ដៃគូ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរវិស័យពាក់ព័ន្ធ។

- ការសម្របសម្រួលរបស់លេខាធិការដ្ឋានមានតួនាទី និងភារកិច្ចជាច្រើនដែលត្រូវការចំណេះដឹងនិងជំនាញពាក់ព័ន្ធ តាមពិតទៅ លេខាធិការដ្ឋាននៃក្រុមការងារនេះត្រូវបានជ្រើសរើសការិយាល័យផែនការនៃមន្ទីរអយក និងមានប្រធានការិយាល័យជាអ្នកទទួលបន្ទុកការងារនេះដែលជាបន្ទុកបន្ថែមពីការងាររដ្ឋបាលប្រចាំថ្ងៃរបស់ខ្លួន និងមានមន្ត្រីទទួលបន្ទុកជាជំនួយការ ជាមធ្យមប្រហែល៥នាក់/ការិ. ហើយអ្នកដឹកនាំការងារនេះមានតែប្រធានឬអនុប្រធានប៉ុណ្ណោះ (តាមរបាយការណ៍របស់មន្ទីរអយករាជធានីខេត្តទាំង២៥) ក្នុងករណីនេះក៏ត្រូវពិចារណាការផ្ទេរមជ្ឈ-ការការងារដល់មន្ត្រីជំនាញបន្តទៀត។ ទោះបីជាយ៉ាងណាលេខធិការដ្ឋានបានបំពេញនូវតួនាទីនិងភារកិច្ចរបស់ខ្លួនបានល្អប្រសើរបើតាមការបង្ហាញក្នុងរូបភាពទី១០ ជាមួយគ្នានោះ ចំណុចត្រូវកែលម្អមានតិចតួចជាង១%ពោលគឺការសម្របសម្រួលស្ថិតក្នុងកម្រិតជាវិជ្ជមាន។ ម្យ៉ាងវិញទៀតក៏បានជួយសម្រួលដល់ក្រុមការងារក៏ដូចជាសមាជិកទាំងឡាយទទួលបានឱកាសស្មើគ្នា ក្នុងការបង្ហាញពីវឌ្ឍនភាពការងាររបស់ខ្លួន ប៉ុន្តែភាពពាក់ព័ន្ធខ្លាំងលើជនបង្គោលអនុវត្តលើការងារអភិវឌ្ឍន៍វិស័យអប់រំ ជារួមមានតែមន្ទីរអប់រំ យុវជន និងកីឡាមានភារកិច្ចក្នុងរៀបចំដំណើរការ បទបង្ហាញនិងការសម្របសម្រួលដែលមានដៃគូសហការពីតំណាងអង្គការដៃគូអភិវឌ្ឍន៍និងការគាំទ្រមានជិត៩០%ធៀបនឹងផ្នែកវិស័យពាក់ព័ន្ធមាន១១% (រូបភាពទី១១)។

**២. ការដំណើរការពេលកិច្ចប្រជុំ**៖បានផ្ដោតលើការរៀបចំដំណើរការប្រជុំ ដែលត្រូវបានធ្វើឡើងតាមរយៈផែនការសកម្មភាព និងយោងតាមការចាំបាច់សម្រាប់តម្រូវការអាទិភាពដោះ-ស្រាយបញ្ហាប្រឈម និងការងារបច្ចេកទេសនៅតាមមូលដ្ឋានឬអង្គភាព។ ការចូលរួមគឺជាធាតុចូលដ៏សំខាន់មិនអាចខ្វះបានក្នុងការកំណត់ពីភាពជោគជ័យ និងលទ្ធផលតាមរបៀបវារៈបានលើកឡើង។ ពិតណាស់ការចូលរួមទៀមទាឱ្យកំណត់ពីសមាសភាពពាក់ព័ន្ធ និងជាសមាជិកនៃក្រុមការងារពិគ្រោះយោបល់ដូចក្នុងរូបភាពទី១៤ ១៥និង១៦ បានបង្ហាញថា ការចូលរួមសុទ្ធតែមកពីផ្នែកពាក់ព័ន្ធដែលមានតួនាទី ការទទួលខុស និងមានភាពសកម្មក្នុងការពិភាក្សាពិគ្រោះយោបល់។ បើតាមរូបភាពទី១៧ ទោះបីជាមានការផ្លាស់ប្ដូរសមាសភាពញឹកញាប់ឬបញ្ហាមួយចំនួនមិនសូវប៉ះពាល់ដល់ក្របខណ្ឌនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ និងដំណើរការកិច្ចប្រជុំប្រកបដោយនិរន្តរភាពផងដែរ។ ក្នុងដំណើរការកិច្ចប្រជុំលេខាធិការដ្ឋាន មានតួនាទីយ៉ាងសំខាន់ច្រើនទាំងការសម្របសម្រួលនានា រៀបចំប្រធានបទ បទបង្ហាញ និងការរៀបចំរបាយការណ៍មួយឆ្លុះបញ្ចាំងពីស្មារតីអង្គប្រជុំដែលមានភាពស្មុគស្មាញច្រើនក្នុងគោលបំណងចង់បានដំណើរការមួយមានភាពសកម្ម និងទាក់ទាញការចូលរួម ក្នុងនោះការសិក្សាខាងលើបង្ហាញឱ្យឃើញថារបៀបវារៈឬប្រធានបទ និងការកំណត់សមាសភាពចូលរួមជារឿងចម្បង។

**៣. ការដំណើរការក្រោយកិច្ចប្រជុំ**៖ ឆ្លុះបញ្ចាំងពីការកំណត់បាននូវធាតុចេញមួយប្រកបដោយគុណភាព និងអាចជាមូលដ្ឋានក្នុងការគិតពិចារណាសម្រាប់ស្វែងរកយុទ្ធសាស្ត្រ និងការគាំ-ទ្រកម្រិតណាមួយអាចដោះស្រាយបញ្ហាបានលើកឡើងក្នុងកិច្ចប្រជុំ។ តាមរយៈការសិក្សាបង្ហាញថាការរៀបចំរបាយការណ៍ត្រូវបានចូលរួមពីផ្នែកពាក់ព័ន្ធ និងព្រាងរបាយការណ៍ជាមួយអ្នកពាក់ព័ន្ធទាំងនោះដើម្បីធានាថាព័ត៌មានដែលទទួលបានមានលក្ខណៈគ្រប់ជ្រុងជ្រោយ ជារួម ការចូលរួមរៀបចំជាទូទៅមានតែភាគីមន្ទីរអប់រំ យុវជន និងកីឡាភាគច្រើនលើសលុបមានជាង៨៨%បើធៀបនឹងមន្ទីរវិស័យពាក់ព័ន្ធផ្សេងទៀតមានជាង១២%ប៉ុណ្ណោះ(រូបភាពទី១៨)។ ការរៀបចំរបាយការណ៍ប្រកបដោយគុណ និងប្រើប្រាស់រយៈពេលរៀបចំស្ថិតក្នុងកម្រិតល្អប្រសើរ (រូបភាពទី១៩ និងទី២០) ប៉ុន្តែការចែករំលែកនូវព័ត៌មានឬរបាយការណ៍នៃកិច្ចប្រជុំនេះផងដែរ មិនទាន់បានទៅដល់ដៃអ្នកពាក់ព័ន្ធឬសមាជិកទាំងអស់នៅឡើយ ជាពិសេសមន្ទីរវិស័យពាក់ព័ន្ធមានមិនដល់១% មន្ទីរវិស័យនេះក៏ជាសមាជិកនៃក្រុមការងារនេះដែលជាផ្នែកជួយសហការ និងគាំទ្រមួយសំខាន់ (រូបភាពទី២១)។

បញ្ហាប្រឈមគន្លឹះ និងដំណោះស្រាយឬយុទ្ធសាស្ត្រ តាមយៈការសិក្សាស្រាវជ្រាវខាងលើ និងការអង្កេតជាទូទៅទៅលើការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាពិនិត្យពិចារណា និងពិភាក្សា(រូបភាពទី២២ និង២៣)។ ខាងក្រោមនេះបានបង្ហាញពីការសិក្សាជារួមក្នុងតារាង៖

| បញ្ហាប្រឈម | យុទ្ធសាស្រ្ត |
|---|---|
| - ការរៀបចំផែនការសកម្មភាពមានតែពីភាគីមន្ទីរអេយក និងក្រុមការងារវិស័យអប់រំ | - បង្កើនការចូលរួមពិភាក្សា និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ការកំណត់របៀបវារៈឬប្រធានបទ និងការរៀបចំរបាយការណ៍ |
| - ការប្រជុំមិនតាមផែនការសកម្មភាពប្រចាំឆ្នាំ | - ពង្រឹងប្រធានកិត្តិយសឬប្រធានក្រុមការងារបច្ចេកទេសចម្រុះចូលរួមដឹកនាំរាល់កិច្ចប្រជុំនីមួយៗ<br>- ពង្រឹងអ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមសហការ និងតាមដានការអនុវត្តរួមគ្នា |
| - ការទំនាក់ទំនងរវាង មន្ទីរអ.យ.ក មន្ទីរពាក់ព័ន្ធ និងក្រុមការងារវិស័យអប់រំ | - ជំរុញការចែករំលែក និងការផ្តល់ព័ត៌មានផ្សេងៗដល់អ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាប |
| - ការផ្តល់ធាតុចូលពីផ្នែកពាក់ព័ន្ធ | - បង្កើនការសម្របសម្រួលរវាងអន្តរក្រសួងពាក់ព័ន្ធ និងក្រុមESWGដើម្បីជំរុញការចូលរួមរបស់អង្គភាពក្រោមឱវាទ |
| - ថវិកាសម្រាប់ដំណើរការប្រជុំពុំទាន់សមស្រប | - បង្កើនការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ |
| - ភាពមមាញឹកនឹងរបស់លេខាធិការដ្ឋាន<br>- សមត្ថភាពលេខាធិការដ្ឋានទាក់ទងនឹងការសម្របសម្រួល និងការរៀបចំរបាយការណ៍នៅមានកម្រិត<br>- សមាសភាពចូលរួមប្រជុំមិនមែនជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ<br>- ពុំទាន់មានកម្មវិធីពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តតាមស្មារតីអង្គប្រជុំ | - កែលម្អសេចក្តីណែនាំថ្មីដោយមានការបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់សមាជិកនីមួយៗបានច្បាស់លាស់<br>- រៀបចំរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តមុនចូលរបៀបវារៈថ្មីក្នុងអង្គប្រជុំ |

## ៥.២.សំណូមពរ

### ក. ក្រសួងអប់រំ យុវជន និងកីឡា៖

- រៀបចំសេចក្តីណែនាំថ្មីដោយមានការបញ្ជាក់ពីតួនាទី និងការទទួលខុស
- លើកទឹកចិត្តដល់លេខាធិការដ្ឋានក្នុងការរៀបចំដំណើរការប្រជុំបានល្អ
- ផ្តល់ថវិកាគាំទ្រដំណើរការប្រជុំ
- បំប៉នសមត្ថភាពលេខាធិការដ្ឋាន
- ក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារ វិស័យអប់រំ និងក្រសួងពាក់ព័ន្ធ ជំរុញកិច្ចសហការ និងការចូលរួមនៃក្រុមការងារ
- បង្កើនកិច្ចសហការរវាងមន្ទីរ និងក្រុមការងារវិស័យអប់រំ(P-ESWG)
- ពិនិត្យលទ្ធភាពរៀបចំទស្សនកិច្ចសិក្សាចំពោះដំណើរការប្រជុំនៅថ្នាក់ជាតិ ឬរាជធានីខេត្តដែលមានការអនុវត្តបានល្អ
- ត្រូវមានយន្តការក្នុងការគ្រប់គ្រងអង្គការដៃគូ និងមន្ទីរវិស័យពាក់ព័ន្ធ

### ខ. ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត(P-JTWG)៖

- របៀបវារៈត្រូវមានការពិភាក្សារជាមួយអ្នកពាក់ព័ន្ធ
- ការចូលរួមកិច្ចប្រជុំជាសមាជិកនៃក្រុមការងារ និងចូលរួមប្រជុំឱ្យបានទៀងទាត់
- កិច្ចប្រជុំត្រូវផ្អែកតាមផែនការសកម្មភាពប្រចាំឆ្នាំ
- ជូនដំណឹងដល់អ្នកពាក់ព័ន្ធដែលជាសមាជិកពីការចូលរួមកិច្ចប្រជុំឲ្យបានយ៉ាងតិច១សប្តាហ៍មុន
- ត្រូវមានការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តនៃក្រុមការងារនេះ
- បង្កើនកិច្ចសហការរវាងមន្ទីរ និងក្រុមការងារវិស័យអប់រំ(P-ESWG)
- ត្រូវធ្វើបច្ចុប្បន្នភាពសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំជាប្រចាំ
- សមាជិកនៃក្រុមការងារនេះគួរបញ្ចូលសមាសភាពមកពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- មន្ទីរវិស័យគួរមានបទបង្ហាញពីវឌ្ឍនភាពការងាររបស់ខ្លួនពាក់ព័ន្ធនឹងវិស័យអប់រំ
- មន្ទីរវិស័យគួរមានបទបង្ហាញពីវឌ្ឍនភាពការងាររបស់ខ្លួនពាក់ព័ន្ធនឹងវិស័យអប់រំ
- មន្ទីរវិស័យត្រូវចូលរួមសហការ និងដោះស្រាយរួមគ្នាក្រោមក្រខណ្ឌនៃក្រុមការងារ
- ថ្នាក់ដឹកមន្ទីរត្រូវតែចូលរួមរាល់កិច្ចប្រជុំ
- បញ្ចូលគណៈអភិបាលខេត្តជាប្រធានកិត្តិយស
- លេខាធិការដ្ឋានត្រូវចែករំលែកព័ត៌មាននានាដល់អ្នកពាក់ព័ន្ធទាំងអស់ រួមមានផែនការសកម្មភាពប្រចាំឆ្នាំ ការរៀបចំកិច្ចប្រជុំ របាយការណ៍ និងការងារពាក់ព័ន្ធផ្សេងទៀត។

ជាចុងបញ្ចប់អ្នកសិក្សាលើកទឹកដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយស្រាវជ្រាវបន្ត និងបង្កើនសំណាកឱ្យបានកាន់តែច្រើនបន្ថែមទៀត ដើម្បីសិក្សាស៊ីជម្រៅលម្អិតលើយន្តការនៃក្រុមការងារបច្ចេក-ទេសចម្រុះវិស័យអប់រំនៅថ្នាក់រាជធានីខេត្ត។ អ្នកសិក្សាស្រាវជ្រាវគិតថាការសិក្សានេះជាជំហានដំបូងអាចនឹងមិនទាន់ច្បាស់លាស់គ្រប់ជ្រុងជ្រោយ ទោះជាយ៉ាងណាក៏លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះជាព័ត៌មានជាមូលដ្ឋានអាចទទួលយកបានសម្រាប់ជាឯកសារពិគ្រោះ និងសិក្សាបន្ត។

# ឯកសារយោង

# ឯកសារយោង


- សេចក្តីណែនាំលេខ០៤អយក សណន ស្តីពីការបង្កើតនិងប្រព្រឹត្តិទៅនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១
- សេចក្តីណែនាំលេខ៥២អយក សណន ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុជន និងកីឡា
- សេចក្តីណែនាំស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ, ឆ្នាំ២០១៩
- សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ឆ្នាំ២០១០
- សៀវភៅណែនាំស្តីពីការដឹកនាំបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ខែកុម្ភៈ ឆ្នាំ២០១៧
- សៀវភៅអភិបាលកិច្ចល្អ ក្រសួងមហាផ្ទៃ ឆ្នាំ២០១៣
- សៀវភៅការគ្រប់គ្រងសមាគមអាជីវកម្មធុនតូច អង្គការពលកម្មអន្តរជាតិកម្ពុជា២០០៧
- របាយការណ៍ពិនិត្យពិនិតឡើងវិញពីវឌ្ឍនភាពការអនុវត្តក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧ ២០១៨ និង២០១៩
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និង២០១៩-២០២៣
- សន្និបាតអប់រំឆ្នាំ២០១៦-២០១៧ និងឆ្នាំ២០១៧-២០១៨ ទិសដៅឆ្នាំ២០១៩
- ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា
- យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ ខែមករា ឆ្នាំ២០១៩
- ការវាយតម្លៃលទ្ធផលនៃមូនិធិភាពជាដៃគូដើម្បីអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ ដំណាក់កាលទី១ និងទី២ នៅកម្ពុជា ឆ្នាំ២០១៨ (https://www.unicef.org/cambodia/media/1221/file/CDPF%20outcome%20evaluation%20Vol%20I.pdf)
- វចនានុក្រមខ្មែរ របស់សម្តេចពោធិញាណ ជួន ណាត
- http://www.unesco.org/new/en/phnompenh/education/unesco-working-groups-in-education/joint-technical-working-group-in-education/)
- http://www.unesco.org/new/en/phnompenh/education/unesco-working-groups-in-education/education-sector-working-group/
- http://www.cdc-crdb.gov.kh/cdc/twg_guideline.htm

# ឧបសម្ព័ន្ធទី១

## សេចក្តីណែនាំស្តីពីក្រុមការងារបច្ចេកទេសចម្រុះ និងក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់រាជធានី ខេត្ត

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខ:** ០៤ **អយក** ស ណាង

**សេចក្តីណែនាំ**
**ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ**

ការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ គឺផ្អែកលើសេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីខែតុលា ឆ្នាំ ២០១០ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៨ ស.ស.រ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១០។

ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ គឺជាអង្គភាពសម្រាប់ផ្តល់ការគាំទ្រ និងកិច្ចសម្របសម្រួល ហើយក៏មិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួង និងស្ថាប័នសាមីឡើយ។ ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវមានគណនេយ្យភាពចំពោះក្រសួង និងស្ថាប័នរបស់ខ្លួន ។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តទាំងអស់ ឲ្យបង្កើតក្រុមការងារបច្ចេកទេសរបស់ខ្លួន និងដាក់ឲ្យដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

**១. គោលបំណង**

គោលបំណងរួមនៃក្រុមការងារបច្ចេកទេសចម្រុះរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឬហៅថាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ គឺសំដៅលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក៏ដូចជាអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធាន និងបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អភិវឌ្ឍវិស័យអប់រំនៅក្នុងមូលដ្ឋានរៀងៗខ្លួន ។

**២. សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ**

សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ រួមមានមន្ត្រីជាតំណាងមន្ទីរ ស្ថាប័នរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍ និងតំណាងសង្គមស៊ីវិលដែលមានពាក់ព័ន្ធនឹងវិស័យអប់រំនៅតាមរាជធានី ខេត្ត ។ ដើម្បីធានាបានប្រសិទ្ធភាពការងារ ក្រុមការងារនេះ គប្បីដឹកនាំ

1

ដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងមានប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍជាអនុប្រធានម្នាក់ក្នុងចំណោមអនុប្រធានដទៃទៀត ។ ចំពោះចំនួនសមាជិក ក៏គប្បីកំណត់ក្នុងបរិមាណមួយសមស្របងាយស្រួលគ្រប់គ្រង និងដឹកនាំការប្រជុំប្រកបដោយប្រសិទ្ធភាពខ្ពស់។ សមាសភាពខាងក្រោមជាគំរូមួយ សម្រាប់មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្ត ធ្វើការពិចារណាជាមូលដ្ឋានដើម្បីបង្កើតក្រុមការងាររបស់ខ្លួន៖

១. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ....................................................ប្រធាន

២. អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា (ទទួលបន្ទុកការងារផែនការ).................... អនុប្រធាន

៣. ប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍវិស័យអប់រំ ...........................................អនុប្រធាន

៤. ប្រធានឬអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ......................................... អនុប្រធាន

៥. ប្រធានឬអនុប្រធានខុទ្ទកាល័យសាលារាជធានី ខេត្ត ...................................... សមាជិក

៦. ប្រធានឬអនុប្រធានមន្ទីរផែនការ ............................................................... សមាជិក

៧.ប្រធានឬអនុប្រធានមន្ទីរកិច្ចការនារី ............................................................ សមាជិក

៨. ប្រធានឬអនុប្រធានមន្ទីរសុខាភិបាល ........................................................ សមាជិក

៩. ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ............................................... សមាជិក

១០. ប្រធានឬតំណាងក្រុមភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ ..... សមាជិក

១១. ប្រធានឬតំណាងអង្គការអន្តរជាតិដែលកំពុងគាំទ្រវិស័យអប់រំ ........................ សមាជិក

១២. ប្រធានឬអនុប្រធានការិយាល័យគណនេយ្យ ........................................................សមាជិក

១៣. ប្រធានឬអនុប្រធានការិយាល័យបុគ្គលិក ...........................................................សមាជិក

១៤. ប្រធានការិយាល័យផែនការ (ផែនការគណនេយ្យនិងសម្ភារៈ) .....................សមាជិកអចិន្ត្រៃយ៍

១៥. អនុប្រធានការិយាល័យផែនការ (ផែនការគណនេយ្យនិងសម្ភារៈ) ................ លេខាធិការ

ក្រៅពីសមាជិកដែលបានចាត់តាំងខាងលើ ប្រធានក្រុមការងារ មានសិទ្ធអញ្ជើញអ្នកដែលមានការពាក់ព័ន្ធនានា មកចូលរួមធ្វើបទបង្ហាញ ឬរាយការណ៍លើប្រធានបទជាក់ស្តែង តាមការឯកភាពគ្នា និងតាមការចាំបាច់របស់ក្រុមការងារ ។

### ៣. ភារកិច្ចនិងភារទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវបង្កើតលេខាធិការដ្ឋានមួយដោយទទួលបានការគាំទ្រជាធនធានចាំបាច់នានា ដើម្បីជួយសម្របសម្រួលដំណើរការរបស់ខ្លួន ។ តួនាទីរបស់លេខាធិការដ្ឋានរួមមាន ការសម្របសម្រួលកិច្ចប្រជុំ ការចែកឯកសារ របាយការណ៍ និងការរៀបចំកំណត់ហេតុប្រជុំនីមួយៗ ជាដើម ។

2

ក្រុមការងារបច្ចេកទេសក្នុងវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវអនុវត្តភារកិច្ចយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាពដោយផ្អែកលើកម្មវិធីការងារដែលបានគ្រោងទុក ដើម្បីរួមចំណែកសម្រេចបាន:

(i). ចំណុចដៅនានារបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣

(ii). ការពិនិត្យតាមដាននិង ការពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំ

(iii). ការប្រមូល និងគ្រប់គ្រងទិន្នន័យជំនួយអភិវឌ្ឍផ្លូវការ ជាពិសេសគម្រោងសកម្មភាពកំពុងអនុវត្តដោយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា

(iv) ការពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាប្រចាំឆ្នាំ និងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំជាដើម

(v) ការកំណត់សកម្មភាពពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូ

(vi) ការធ្វើរបាយការណ៍រួមស្តីពីវឌ្ឍនភាពសូចនាករសំខាន់ចាំបាច់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩- ២០១៣

(vii) កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅរៀងរាល់បីខែម្តង ឬអាចរៀបចំប្រជុំផ្សេងទៀតតាមការចាំបាច់

(viii) ការកំណត់របៀបវារៈប្រជុំច្បាស់លាស់ តាមផែនការការងារប្រចាំឆ្នាំ និងសូចនាករពិនិត្យតាមដាន ក្នុងកិច្ចប្រជុំនីមួយៗ នឹងបន្តកែលម្អឱ្យស៊ីចង្វាក់គ្នា ។

(ix) ប្រធានក្រុមការងារ ឬអ្នកតំណាងប្រធានក្រុមការងារ និងអ្នកដឹកនាំសម្របសម្រួលត្រូវធ្វើទំនាក់ទំនងគ្នាជាប្រចាំពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយ ដើម្បីតាមដានសកម្មភាពដែលបានឯកភាពហើយ។

លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានភារកិច្ចចាត់ចែងអនុវត្តសេចក្តីណែនាំនេះឱ្យទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាព។

**រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១១**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល</u>

-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-អង្គភាពពាក់ព័ន្ធ

-សាលារាជធានី-ខេត្ត

*«ដើម្បីជូនជ្រាបជាព័ត៌មាន»*

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

*«ដើម្បីមុខការ»*

-ឯកសារ-កាលប្បវត្តិ

3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥៧ អយក.សណន

## សេចក្តីណែនាំ
## ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត

### ១. សាវតារ

រាជរដ្ឋាភិបាលបានណែនាំឱ្យបង្កើតក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យ និងបានចេញសេចក្តីណែនាំស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ កាលពីឆ្នាំ២០០៤។ បន្ទាប់ពីពិនិត្យឡើងវិញក្របខណ្ឌយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តសេចក្តីសម្រេចស្តីពីការអនុវត្តយន្តការពិគ្រោះយោបល់ និងឧបករណ៍នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩។

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិនៅឆ្នាំ២០០៤ និងបានណែនាំរាជធានី ខេត្ត ឱ្យបង្កើតក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានី ខេត្តនៅឆ្នាំ២០១១។ ក្រុមការងាបច្ចេកទេសចម្រុះវិស័យអប់រំ ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត នៅតែជាយន្តការដ៏មានប្រសិទ្ធភាពក្នុងភាពជាដៃគូ សហប្រតិបត្តិការ ការពិភាក្សា និងពិគ្រោះយោបល់ក្នុងកម្រិតគោលនយោបាយ បច្ចេកទេស រួមទាំងការកៀរគរធនធាន ដើម្បីគាំទ្រវិស័យអប់រំនៅគ្រប់កម្រិត។

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងផ្អែកតាមក្របខណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការកែសម្រួលសេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តទាំងអស់រៀបចំកែសម្រួលក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនិងដំណើរការ ឱ្យកាន់តែមានប្រសិទ្ធភាព ដូចមានក្នុងខ្លឹមសារខាងក្រោមៈ

### ២. គោលបំណង

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ចូលរួមចំណែកជួយគាំទ្រដល់កិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការសម្របសម្រួលកិច្ចពិភាក្សាកម្រិតបច្ចេកទេស និង

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

កៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងការអនុវត្តគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ម្យ៉ាងវិញទៀត ក្រុមការងារនេះមិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់ជាមួយនឹងមន្ទីរ ឬអង្គភាពនានាឡើយ។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត មានគោលបំណងដូចតទៅ៖

- លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ភាពជាដៃគូកម្រិតបច្ចេកទេស ការសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ
- ជំរុញការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងតម្រូវការអាទិភាពរបស់មន្ទីរ
- តាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពរួមគ្នារវាងស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលបានរំលេចសកម្មភាពក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

### ៣. គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះ ថ្នាក់រាជធានី ខេត្ត

ដើម្បីជំរុញការអនុវត្តរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ប្រកបដោយប្រសិទ្ធភាពស្របតាមយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ មន្ទីរអប់រំ យុវជន និងកីឡាត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍សំខាន់០៤ ដូចខាងក្រោម៖

**១. ភាពជាម្ចាស់៖** ត្រូវប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន ដោយឈរលើគោលការណ៍ភាពជាម្ចាស់ដើម្បីពង្រឹងទំនាក់ទំនងដែលមានការទុកចិត្ត និងការគោរពគ្នាទៅវិញទៅមកតាមរយៈការអនុវត្តផែនការសកម្មភាពការងារផ្អែកលើលទ្ធផល។

**២. ភាពជាដៃគូ៖** ត្រូវដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូក្នុងមូលដ្ឋានទាំងអស់ ដើម្បីកៀរគរធនធានសំដៅសម្រេចបានលទ្ធផលដែលបានកំណត់ក្នុងចំណុចដៅរបស់ក្រុមការងារ ស្របតាមផែនការប្រតិបត្តិប្រចាំឆ្នាំ និងឈានទៅសម្រេចបានចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា។

**៣. ការតម្រឹម និងលទ្ធផល៖** យន្តការនៃភាពជាដៃគូ និងការសម្របសម្រួលត្រូវបញ្ជាក់នូវគោលដៅច្បាស់លាស់ ដើម្បីតម្រឹមធនធានជាមួយនឹងអាទិភាព និងកំណត់ប្រព័ន្ធពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព ដែលត្រូវប្រើប្រាស់ដោយផ្សារភ្ជាប់ទៅនឹងក្របខណ្ឌលទ្ធផលដែលមានស្រាប់។

**៤. គណនេយ្យភាព៖** សមាជិកក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ទាំងអស់ ត្រូវមានគណនេយ្យភាពទៅវិញទៅមកក្នុងការសម្រេចលទ្ធផលការងារ។

## ៤. សមាសភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត

សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ក្នុងចំនួនមួយសមស្របរួមមាន៖ គណៈអភិបាលរាជធានី ខេត្ត ជាប្រធានកិត្តិយសនៃក្រុមការងារ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ជាប្រធានដឹកនាំប្រចាំការ ថ្នាក់ដឹកនាំ តំណាង ឬមន្ត្រីជំនាញមកពីមន្ទីរ ស្ថាប័នដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិលមួយចំនួនដែលធ្វើការពាក់ព័ន្ធនឹងវិស័យអប់រំ រួមទាំងមានលេខាធិការដ្ឋានដើម្បីជួយគាំទ្រ។

ខាងក្រោមនេះជាគំរូមួយសម្រាប់មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្តនីមួយៗ ធ្វើការពិចារណាជាមូលដ្ឋានក្នុងការរៀបចំសមាសភាពនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ៖

| | |
|---|---|
| ១. គណៈអភិបាលរាជធានី ខេត្ត (ទទួលបន្ទុកវិស័យអប់រំ) | ប្រធានកិត្តិយស |
| ២. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ប្រធាន |
| ៣. អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា (ទទួលបន្ទុកការងារផែនការ) | អនុប្រធាន |
| ៤. ប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍន៍វិស័យអប់រំ | អនុប្រធាន |
| ៥. ប្រធានឬអនុប្រធានមន្ទីរពាក់ព័ន្ធ | អនុប្រធាន |
| ៦. នាយករដ្ឋបាល ឬនាយករងរដ្ឋបាល សាលារាជធានី ខេត្ត | សមាជិក |
| ៧. ប្រធានឬអនុប្រធានមន្ទីរពាក់ព័ន្ធ | សមាជិក |
| ៨. ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ខណ្ឌ | សមាជិក |
| ៩. ប្រធានឬអនុប្រធានការិយាល័យជំនាញក្រោមឱវាទមន្ទីរអយក | សមាជិក |
| ១០. ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | សមាជិកអចិន្ត្រៃយ៍ |
| ១១. អនុប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | លេខាធិការ |
| ១២. មន្ត្រីជំនាញការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | លេខាធិការ |

ចំពោះករណីមានសមាសភាពក្រៅពីការចាត់តាំងខាងលើ ប្រធានមានសិទ្ធិអញ្ជើញអ្នកដែលមានការពាក់ព័ន្ធនានាមកចូលរួមប្រជុំធ្វើបទបង្ហាញ ឬរាយការណ៍លើប្រធានបទជាក់ស្តែងតាមការឯកភាពគ្នា និងតាមការចាំបាច់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។

## ៥. ភារកិច្ច និងការទទួលខុសត្រូវ

ប្រធាន អនុប្រធាន សមាជិក និងលេខាធិការនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ថ្នាក់រាជធានី ខេត្ត មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

**ក. ប្រធាន៖**

- អនុម័តលើផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត

- ត្រូវសម្រេចចិត្តលើរបៀបវារៈនៃកិច្ចប្រជុំជាមួយនឹងតំណាងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល
- ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំតាមផែនការ ដែលបានកំណត់
- គាំទ្រធនធានសម្រាប់កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត
- រាយការណ៍ជូនអភិបាលនៃគណៈអភិបាលដោយផ្ទាល់ពីស្ថានភាពអប់រំ និងស្នើសុំកិច្ចអន្តរាគមន៍ ឬការសម្រេចចិត្តទៅលើប្រធានបទអន្តរវិស័យ ឬកម្រិតខ្ពស់នានា
- ផ្តល់អន្តរាគមន៍ដោយផ្ទាល់ទៅមន្ទីរ ស្ថាប័នអង្គភាព និងដៃគូអភិវឌ្ឍន៍ ដើម្បីពន្លឿនការអនុវត្តកិច្ចការ របស់ក្រុមការងារប្រកបដោយប្រសិទ្ធភាព។

**ខ. សមាជិក៖**

- ចូលរួមប្រជុំ និងផ្តល់ធាតុចូលដែលពាក់ព័ន្ធ
- ជូនដំណឹងអំពីការចូលរួម ឬសមាសភាពជំនួស ដែលអាចសម្រេចចិត្តបាន ក្នុងករណីមិនបានចូលរួម
- រាយការណ៍ជូនថ្នាក់ដឹកនាំស្ថាប័ន អង្គភាពខ្លួន អំពីលទ្ធផលនៃកិច្ចប្រជុំដើម្បីជាព័ត៌មានការសហការ ឬការសម្រេចចិត្ត
- ផ្តល់មតិយោបល់បន្ថែមលើសេចក្តីព្រាងរបាយការណ៍ ឬកំណត់ហេតុ ដែលត្រូវបានរៀបចំដោយលេខាធិការដ្ឋានមុនពេលអនុម័តជាផ្លូវការ ដើម្បីផ្សព្វផ្សាយខ្លឹមសារនៃកិច្ចប្រជុំជូនដល់សមាជិកក្រុមការងារ
- ចូលរួមអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលតាមស្មារតីអង្គប្រជុំ។

**គ. លេខាធិការដ្ឋាន៖**

- រៀបចំអាណត្តិការងាររបស់ខ្លួន និងក្រុមការងារឱ្យបានច្បាស់លាស់
- រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ក្រុមការងារ ដាក់ជូនប្រធានពិនិត្យ និងសម្រេច
- លើកសំណើរបៀបវារៈសម្រាប់ប្រជុំដោយពិភាក្សា ជាមួយលេខាធិការដ្ឋានដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល និងដាក់ជូនទៅប្រធានក្រុមការងារពិនិត្យ និងសម្រេច
- រៀបចំឯកសារពាក់ព័ន្ធសម្រាប់ចែកជូនដល់សមាជិកទាំងអស់ឱ្យបានយ៉ាងតិច១០ថ្ងៃមុនពេលប្រជុំ
- រៀបចំសេចក្តីព្រាងរបាយការណ៍ ឬកំណត់ហេតុ និងផ្ញើជូនទៅអ្នកពាក់ព័ន្ធដើម្បីពិនិត្យ កែសម្រួល និងផ្តល់ធាតុចូលបន្ថែម
- ផ្សព្វផ្សាយរបាយការណ៍ ឬកំណត់ហេតុ និងផ្តល់ដល់សមាជិកទាំងអស់ឱ្យបានទាន់ពេលវេលា យ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីកិច្ចប្រជុំ
- ផ្តល់ព័ត៌មានបច្ចុប្បន្នភាព របាយការណ៍ ឬកំណត់ហេតុ និងទិន្នន័យដែលពាក់ព័ន្ធជូនទៅការិយាល័យសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៃនាយកដ្ឋានផែនការតាមពេលវេលាកំណត់ ឬតាមការស្នើសុំចាំបាច់។

**ចំពោះក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត មានភារកិច្ច ដូចខាងក្រោម៖**

- កៀរគរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សម្រាប់អភិវឌ្ឍវិស័យអប់រំនៅក្នុងរាជធានី ខេត្ត ឱ្យឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំនៅកម្ពុជា ឆ្នាំ២០៣០
- ពិភាក្សា និងផ្តល់ធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំរបស់រាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងផែនការរបស់ក្រសួង
- ប្រមូល និងគ្រប់គ្រងទិន្នន័យអប់រំ និងប្រើប្រាស់ទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ ជាពិសេសគម្រោងសកម្មភាពកំពុងអនុវត្ត ដោយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន តាមរាជធានី ខេត្ត
- ពិនិត្យតាមដាន និងពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំទៅតាមក្របខណ្ឌពេលវេលាដែលបានកំណត់
- រៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ
- ពង្រឹងកិច្ចសហការក្នុងភាពជាដៃគូ និងការលើកកម្ពស់ប្រសិទ្ធភាព នៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់រាជធានី ខេត្ត រៀងរាល់ត្រីមាស ឬអាចរៀបចំប្រជុំផ្សេងទៀត តាមការចាំបាច់។

លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានភារកិច្ចចាត់ចែង អនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលជាផ្លែផ្កា។

ថ្ងៃ ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-សាលារាជធានី ខេត្ត
"ដើម្បីសហការ"
-អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
-គ្រប់អង្គភាពពាក់ព័ន្ធ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានផែនការ

**សេចក្តីណែនាំ**
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ**
**ខែកុម្ភៈ ឆ្នាំ២០១៩**

## I - បរិការណ៍

រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះ ក្នុងឆ្នាំ២០០៤ សម្រាប់ជាយន្តការសម្របសម្រួល និងពិគ្រោះយោបល់ក្នុងភាពជាដៃគូ ដែលមានការចូលរួមពីតំណាងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីគាំទ្រការអនុវត្តឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។ បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសចម្រុះចំនួន ២០ ត្រូវបានបង្កើត និងកំពុងបំពេញការងាររបស់ខ្លួននៅតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។

ការពិនិត្យសមិទ្ធកម្មនៃក្រុមការងារបច្ចេកទេសចម្រុះ ក្នុងឆ្នាំ២០១៨ បង្ហាញថា ក្រុមការងារបច្ចេកទេសចម្រុះនៅតែជាយន្តការភាពជាដៃគូប្រកបដោយប្រសិទ្ធភាព សម្រាប់សម្របសម្រួលកិច្ចពិគ្រោះយោបល់ និងហិរញ្ញប្បទានក្រៅប្រទេស ។ ការពិនិត្យនេះក៏បានកំណត់បញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធនឹងសមត្ថភាពរបស់ក្រុមការងារក្នុងការអនុវត្តឱ្យបានសម្រេចនូវគោលដៅ ទន្ទឹមនឹងតម្រូវការក្នុងការសម្របខ្លួនទៅនឹងបរិការណ៍ប្រែប្រួលយ៉ាងឆាប់រហ័សនៃភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គួបផ្សំនឹងបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រង, ភាពជាអ្នកដឹកនាំ, សមាសភាព, និងរចនាសម្ព័ន្ធស្ថាប័ន ។

សេចក្តីណែនាំបានកំណត់គោលបំណង, គោលការណ៍, អាទិភាពការងារ, និងយន្តការស្ថាប័នសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ ក៏ដូចជាការផ្សារភ្ជាប់គ្នារវាងយន្តការនេះជាមួយនឹងកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ។ ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ អាចប្រើប្រាស់សេចក្តីណែនាំនេះ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ តាមរយៈការរៀបចំកម្មវិធីច្បាស់លាស់ ដែលអាចឆ្លើយតបទៅនឹងការងារអាទិភាព និងរបៀបអនុវត្តការងារដែលមានលក្ខណៈស្របនឹងស្ថានភាពជាក់ស្តែងរបស់ខ្លួន ។

## II - គោលបំណងនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះ

គោលបំណងចម្បងនៃក្រុមការងារបច្ចេកទេសចម្រុះ គឺជួយគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលកិច្ចពិភាក្សាកម្រិតបច្ចេកទេស, កៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយ ឬផែនការតាមវិស័យ និងកម្មវិធីកែទម្រង់ ស្របតាមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា ។ យន្តការនេះពុំមានគោលបំណងបំពេញមុខងារជំនួស ឬត្រួតជាន់គ្នាជាមួយនឹងតួនាទីរបស់ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាលឡើយ ។ គោលបំណងជាក់លាក់នៃក្រុមការងារបច្ចេកទេសចម្រុះ គឺ៖

1

១- លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ភាពជាដៃគូកម្រិតបច្ចេកទេស សម្រាប់សម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ។

២- ជំរុញការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងតម្រូវការអាទិភាពរបស់ក្រុមការងារ ។

៣-តាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពរួមគ្នា រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលបានរំលេចក្នុងផែនការសកម្មភាព និងសូចនាករតាមដានរួមគ្នា ។

៤-បំពេញបន្ថែមឱ្យយន្តការភាពជាដៃគូដទៃទៀត ដូចជាកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី/ខេត្ត និងកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ។

## III - គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះ

សេចក្តីណែនាំបានលើកគោលការណ៍សំខាន់ៗមួយចំនួន ដើម្បីជំរុញប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះ ស្របតាមយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដូចខាងក្រោម ÷

១- *ភាពជាម្ចាស់* - រាជរដ្ឋាភិបាលប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍន៍ ដោយឈរលើគោលការណ៍ភាពជាម្ចាស់ ដើម្បីពង្រឹងទំនាក់ទំនងដែលមានការជឿទុកចិត្ត និងការគោរពគ្នាទៅវិញទៅមក តាមរយៈការដាក់ឱ្យអនុវត្តនូវក្របខណ្ឌគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។

២- *ភាពជាដៃគូ* - រាជរដ្ឋាភិបាលនឹងដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយនឹងសមាជិកក្រុមការងារទាំងអស់ ដើម្បីកៀរគរធនធាន និងសម្រេចបានលទ្ធផលដែលបានកំណត់ក្នុងគោលដៅរបស់ក្រុមការងារ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។

៣- *ការតម្រឹម និងលទ្ធផល* - យន្តការនៃភាពជាដៃគូ និងសម្របសម្រួល ត្រូវបញ្ជាក់គោលដៅច្បាស់លាស់ ដើម្បីតម្រឹមធនធានជាមួយនឹងអាទិភាព និងកំណត់ប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធភាព ដែលត្រូវផ្សារភ្ជាប់នឹងក្របខណ្ឌលទ្ធផលដែលមានស្រាប់ ។

៤- *គណនេយ្យភាព* - សមាជិកក្រុមការងារទាំងអស់ត្រូវមានគណនេយ្យភាពទៅវិញទៅមក ក្នុងការសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។

## IV - អាទិភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ

សេចក្តីណែនាំបានកំណត់អាទិភាពការងារ ៥ សម្រាប់ក្រុមការងារ ។ ក្រុមការងារអាចយកសេចក្តីណែនាំនេះ ជាលក្ខខណ្ឌយោងសម្រាប់រៀបចំផែនការសកម្មភាពការងារ ។ ប៉ុន្តែ ក្រុមការងារក៏អាចរៀបចំលក្ខខណ្ឌយោងរបស់ខ្លួនដែរ ដោយផ្អែកលើអាទិភាពការងារដទៃទៀត ។ ក្រុមការងារនីមួយៗអាចកំណត់គោលការណ៍ដើម្បីកំណត់អាទិភាពការងាររបស់ខ្លួន ដោយផ្អែកលើតម្រូវការ, ធនធាន និងសមត្ថភាពដែលមានស្រាប់ ។

១- *ការតម្រឹម, ការសម្របសម្រួល និងការកៀរគរ និងប្រើប្រាស់ធនធាន*

ការសម្របសម្រួល និងកៀរគរធនធាន គឺជាអាទិភាពស្នូលរបស់ក្រុមការងារដែលត្រូវអនុវត្តដូចខាងក្រោម÷

2

- ធានាបាននូវការតម្រឹមនៃហិរញ្ញប្បទានក្រៅប្រទេសជាមួយនឹងអាទិភាពរបស់ក្រុមការងារ ។
- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលកំពុងដំណើរការ នៅក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងប្រើប្រាស់ព័ត៌មានទាំងនេះសម្រាប់សម្របសម្រួល និងពិគ្រោះយោបល់។
- ប្រើប្រាស់ទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យទាំងនេះ សម្រាប់កំណត់ប្រភពធនធាន និងគម្រោងដែលផ្តល់គាំទ្រដោយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅតាមក្រុមការងារនីមួយៗ ។
- កំណត់ទំហំធនធានដែលត្រូវកៀរគរបន្ថែម និងគម្រោងត្រៀមបម្រុង ដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពនៃផែនការសកម្មភាពរបស់ក្រុមការងារ ។

*២- កិច្ចពិគ្រោះយោបល់ភាពជាដៃគូ*

កិច្ចពិគ្រោះយោបល់ត្រូវផ្អែកតាមគោលការណ៍ភាពជាដៃគូ និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។ ក្រុមការងារបច្ចេកទេសចម្រុះគប្បីផ្តោតលើការងារដូចខាងក្រោម÷

- លើកកម្ពស់កិច្ចពិភាក្សាអំពីការប្រើប្រាស់ក្របខណ្ឌលទ្ធផលរបស់គម្រោង ឬកម្មវិធីដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមការងារ ។
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធជាតិ ពិសេសគម្រោងឬកម្មវិធីពាក់ព័ន្ធនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ពិភាក្សា និងលើកកម្ពស់ការអនុវត្តសូចនាករពាក់ព័ន្ធនឹងភាពជាដៃគូ និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ រួមទាំងហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ និងភាពទស្សន៍ទាយបាននូវហិរញ្ញប្បទានសហប្រតិបត្តិការ ។
- ផ្តោតការយកចិត្តទុកដាក់លើបញ្ហាអន្តរវិស័យ និងការកែទម្រង់ដែលពាក់ព័ន្ធនឹងក្រុមការងារ ហើយតម្រូវឱ្យមានកិច្ចសហការពីបណ្តាក្រសួងនិងស្ថាប័ន ឬតួអង្គពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានក្នុងកិច្ចពិភាក្សា និងកិច្ចសហការដោះស្រាយរួមគ្នា ។
- រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាព និងការពិនិត្យមុខងារឡើងវិញ ក្នុងគោលដៅលើកកម្ពស់សមិទ្ធិកម្មរបស់ក្រុមការងារ ។

*៣- ការតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពការងារ*

ក្រុមការងារបច្ចេកទេសចម្រុះត្រូវវាយតម្លៃជាប្រចាំ អំពីសមិទ្ធិកម្មរបស់ខ្លួន ដោយរំលេចអំពីបញ្ហាប្រឈមដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅរបស់វិស័យ ។ ការពិនិត្យ និងការតាមដាននេះត្រូវផ្សារភ្ជាប់ជាមួយការអភិវឌ្ឍសមត្ថភាព ដើម្បីក្រុមការងារមានប្រព័ន្ធតាមដាន និងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់វាយតម្លៃ ។ ក្រុមការងារគប្បីអនុវត្តការងារមួយចំនួនដូចខាងក្រោម÷

3

- រៀបចំកិច្ចប្រជុំទៀងទាត់ ដើម្បីពិនិត្យ និងតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការការងារ និងសូចនាករតាមដានរួមគ្នា ក៏ដូចជាពិភាក្សាលើការងារពាក់ព័ន្ធបញ្ហាអន្តរវិស័យ ។
- ធ្វើសពុលភាពទិន្នន័យ សម្រាប់តាមដានវឌ្ឍនភាពការអនុវត្តសូចនាករតាមដានរួមគ្នា ។ ទន្ទឹមនេះ ក៏ត្រូវធ្វើការងារដែលមានចរិតជាការវិភាគមួយចំនួន ដែលក្រុមការងារអាចផ្តល់ការគាំទ្រ ដើម្បីពង្រឹងប្រព័ន្ធតាមដាន និងរបាយការណ៍ ។
- ជំរុញការប្រើប្រាស់សូចនាករតាមដានរួមគ្នាដែលផ្តោតលើលទ្ធផល ដោយផ្សារភ្ជាប់នឹងក្របខណ្ឌលទ្ធផលរបស់វិស័យ សម្រាប់ពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពការងារ និងកំណត់អាទិភាពរបស់ក្រុមការងារ ។
- ពិនិត្យ និងតាមដានបញ្ហានានា ដែលបានលើកឡើងក្នុងវេទិកាដទៃ ។

*៤- <u>បញ្ហាអន្តរវិស័យ</u>*

ក្រុមការងារបច្ចេកទេសចម្រុះត្រូវផ្តោតការងារជាសំខាន់ ទៅលើវិស័យ ឬកម្មវិធីកែទម្រង់ ឬប្រធានបទជាក់លាក់ ទន្ទឹមនឹងការកំណត់បញ្ហាអន្តរវិស័យដែលក្រុមការងារអាចផ្តល់ការគាំទ្រ ។ បញ្ហាអន្តរវិស័យសំខាន់ៗដែលក្រុមការងារត្រូវផ្តោតការយកចិត្តទុកដាក់ រួមមាន ÷ ការបញ្ជ្រាបយេនឌ័រ, បរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច និងការលើកកម្ពស់គុណភាពសេវាសាធារណៈ ។ ដើម្បីដោះស្រាយបញ្ហាអន្តរវិស័យ ក្រុមការងារបច្ចេកទេសចម្រុះគប្បីអនុវត្តដូចខាងក្រោម÷

- សមាជិកភាពរបស់ក្រុមការងារត្រូវមានសង្គតិភាពជាមួយបញ្ហាអន្តរវិស័យដែលត្រូវពិភាក្សា ។
- ពិនិត្យលទ្ធភាពបង្កើតអនុក្រុមការងារ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាអន្តរវិស័យ ។ អនុក្រុមការងារត្រូវរាយការណ៍អំពីលទ្ធផលការងារ ជូនក្រុមការងារបច្ចេកទេសចម្រុះ ។
- អាចចាត់តាំងមន្ត្រីបង្គោលរបស់ស្ថាប័នសាមី ឱ្យទទួលខុសត្រូវ និងគ្រប់គ្រងបញ្ហាអន្តរវិស័យដែលពាក់ព័ន្ធនឹងក្រុមការងាររបស់ខ្លួន ។
- ពិនិត្យ និងរៀបចំកិច្ចប្រជុំរវាងសមាជិកស្នូលនៃបណ្តាក្រុមការងារពាក់ព័ន្ធ ដើម្បីធានាសង្គតិភាព និងជំរុញការតាមដាន ។
- កិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះនឹងផ្តល់កាលានុវត្តភាពបន្ថែមសម្រាប់កិច្ចសម្របសម្រួលអន្តរក្រសួង និងដោះស្រាយបញ្ហាប្រឈមអន្តរវិស័យ ។

*៥- <u>ការចែករំលែកព័ត៌មាន</u>*

ការចែករំលែកព័ត៌មានសម្រាប់សមាជិកក្រុមការងារទាំងអស់អាចបំពេញភារកិច្ចជាបុគ្គលនិងជាក្រុម គឺជាភារកិច្ចអប្បបរមារបស់ក្រុមការងារបច្ចេកទេសចម្រុះ។ ក្រុមការងារគប្បីបំពេញការងារដូចខាងក្រោម÷

- ក្រុមការងារបច្ចេកទេសចម្រុះ គឺជាវេទិកាសម្រាប់ចែករំលែកព័ត៌មានស្តីពីកិច្ចការដែលកំពុងអនុវត្ត ហើយដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ក្រុមការងារ(ដូចជាការសិក្សាស្រាវជ្រាវ, បេសកកម្ម និងការត្រួតពិនិត្យ) ។

4

- ផ្តល់ព័ត៌មានដល់សមាជិកគ្រប់រូប អំពីកិច្ចប្រជុំ ឬកិច្ចពិគ្រោះយោបល់ដទៃ ពិសេសការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងក្រុមការងារ ។
- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់សមាជិកគ្រប់រូប អំពីការរៀបចំកម្មវិធី ឬការអនុវត្តសកម្មភាពដែលជះឥទ្ធិពលដល់ការសម្រេចគោលដៅរបស់ក្រុមការងារ ដូចមានចែងក្នុងផែនការប្រចាំឆ្នាំ ។
- ចែករំលែកព័ត៌មានស្តីពីការគាំទ្ររបស់តួអង្គអភិវឌ្ឍន៍ដទៃទៀត (ដូចជាវិស័យឯកជន, ដៃគូអភិវឌ្ឍន៍ដែលមិនមានវត្តមាននៅកម្ពុជា ឬដៃគូមិនមែនជាសមាជិកនៃក្រុមការងារ) ដែលពាក់ព័ន្ធនឹងក្រុមការងារ ។
- រៀបចំ និងពង្រឹងបន្ថែមប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដើម្បីឱ្យរាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះអាចទទួលព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលា ដែលមានចែងក្នុងឯកសារគម្រោង ឬកិច្ចព្រមព្រៀង ។

## V- យន្តការស្ថាប័ន

### ១- *គណនេយ្យភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ*

ក្រុមការងារបច្ចេកទេសចម្រុះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នសាមី ហើយក៏ត្រូវមានគណនេយ្យភាពចំពោះក្រសួង ឬស្ថាប័នសាមី ។ ប្រធានក្រុមការងារដែលត្រូវបានតែងតាំង គឺជាអ្នកមានសិទ្ធិសម្រេចចុងក្រោយលើរាល់កិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនេះ ក៏ត្រូវជំរុញឱ្យមានកិច្ចពិភាក្សា និងការឯកភាពរួមគ្នា ដោយឈរលើស្មារតីភាពជាដៃគូដែលជាគោលការណ៍ស្នូលក្នុងការអនុវត្តការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

ក្រុមការងារត្រូវរាយការណ៍ជូនក្រសួង ឬស្ថាប័នសាមី អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តផែនការសកម្មភាព, សូចនាករតាមដានរួមគ្នា និងបញ្ហាអន្តរវិស័យ ។ ក្រសួង ឬស្ថាប័នសាមីត្រូវដោះស្រាយបណ្តាបញ្ហាដែលមិនទាន់ត្រូវបានដោះស្រាយនៅក្រុមការងារបច្ចេកទេសចម្រុះ ឬអាចលើកយកបញ្ហាទាំងនោះទៅពិភាក្សានៅក្នុងកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ។

ដៃគូអភិវឌ្ឍន៍ត្រូវសហការជាមួយសមភាគីនៃរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីតម្រឹមធនធាន និងតម្រង់ទិសការងារ ដើម្បីរួមចំណែកអនុវត្តឱ្យបានសម្រេចនូវសូចនាករតាមដានរួមគ្នា និងការងារដែលពាក់ព័ន្ធនឹងក្រុមការងាររបស់ខ្លួន។ ដៃគូអភិវឌ្ឍន៍នីមួយៗ អាចចូលរួមចំណែកដោយផ្ទាល់ ឬតាមរយៈប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ក្នុងកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ស្របតាមតួនាទី និងភារកិច្ចដែលកំណត់ក្នុងសេចក្តីណែនាំនេះ។

### ២- *សមាសភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ*

ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗត្រូវមានសមាជិកដែលជាតំណាងរបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដោយពិភាក្សាជាមួយសមាជិកដែលមានបច្ចុប្បន្ន គឺជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ លើសមាជិកភាពរបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ដើម្បីធានាកិច្ចពិភាក្សាឱ្យមានប្រសិទ្ធភាព ក្រុមការងារបច្ចេកទេសចម្រុះគួរយកចិត្តទុកដាក់លើបណ្តាចំណុចដូចខាងក្រោម÷

- *ប្រធានក្រុមការងារបច្ចេកទេសចម្រុះតែងតាំងដោយរាជរដ្ឋាភិបាល* : ប្រធានក្រុមការងារត្រូវបានតែងតាំងដោយប្រធានក្រសួង ឬស្ថាប័ន និងត្រូវបំពេញការងារជូនស្ថាប័នរបស់ខ្លួន ។ ប្រធានក្រុមការងារត្រូវមានសមត្ថភាពដោះស្រាយបញ្ហានានារបស់ក្រុមការងារ និងត្រូវដឹកនាំកិច្ចពិភាក្សាឱ្យមានភាពរលូន ។ ទន្ទឹមនឹងនេះ ប្រធានត្រូវមានការប្តេជ្ញាចិត្តខ្ពស់, ត្រូវទំនាក់ទំនង និងតាមដានវឌ្ឍនភាពការងារជាមួយក្រសួង និងស្ថាប័នដទៃដែលមានតំណាងរបស់ខ្លួនក្នុងក្រុមការងារ ព្រមទាំងយល់ដឹងអំពីគម្រោង ឬកម្មវិធីដែលដៃគូអភិវឌ្ឍន៍កំពុងគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ ។
- *ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍* : ប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ គឺជាតំណាងជាន់ខ្ពស់នៃស្ថាប័ន ឬប្រទេសផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ហើយត្រូវមានសមត្ថភាព និងជំនាញច្បាស់លាស់ក្នុងការងាររបស់ក្រុមការងារ និងមានឆន្ទៈក្នុងការចែករំលែកព័ត៌មានដល់ដៃគូអភិវឌ្ឍន៍ដទៃ ។ ដៃគូអភិវឌ្ឍន៍ត្រូវកំណត់បែបបទសម្រាប់ជ្រើសតាំង ឬផ្លាស់ប្តូរប្រធានសម្របសម្រួល ។ ប៉ុន្តែ ដើម្បីធានាចីរភាពនៃការងារប្រធានសម្របសម្រួលអាចមានអាណត្តិកាលក្នុងក្រុមការងារ រយៈពេល ២ឆ្នាំ យ៉ាងតិច ។ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ នឹងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដទៃ ដើម្បីបញ្ជាក់អំពីការប្តេជ្ញាផ្តល់ និងកៀរគរធនធាន សម្រាប់គាំទ្រក្រុមការងារបច្ចេកទេសចម្រុះ ។
- *លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះ* : ក្រសួង ឬស្ថាប័នសាមីបង្កើតលេខាធិការដ្ឋានមួយ ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានក្រុមការងារ ដើម្បីគាំទ្រកិច្ចការរដ្ឋបាលរបស់ក្រុមការងារ, តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារដែលបានឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមការងារ និងជួយសម្របសម្រួលការគ្រប់គ្រងព័ត៌មាន ព្រមទាំងជាតំណាងក្រុមការងាររបស់ខ្លួនក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។
- *តំណាងក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល* : សមាជិកទាំងនេះត្រូវផ្តល់ការគាំទ្រដល់កិច្ចសម្របសម្រួលអន្តរស្ថាប័ន ពិសេសក្នុងការដ្ឋានកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ត្រូវមានសមត្ថភាព និងការយល់ដឹងខ្ពស់ខាងបច្ចេកទេស ព្រមទាំងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ធ្វើជាតំណាងឱ្យក្រសួង ឬស្ថាប័ន ។ លើសពីនេះ ក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការលើកទស្សនៈ និងបញ្ចេញមតិ ក្នុងនាមស្ថាប័នសាមី ព្រមទាំងមានលទ្ធភាពក្នុងការផ្តល់ព័ត៌មាន ក៏ដូចជាការសម្របសម្រួលតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្ម ភាពការងារនៅក្នុងក្រសួង ឬស្ថាប័នរបស់ខ្លួន ។ សមាជិកដែលជាតំណាងក្រសួង ឬស្ថាប័ននីមួយៗ ត្រូវចែករំលែកព័ត៌មាន និងចំណេះដឹងរបស់ខ្លួន ក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ហើយពាំនាំព័ត៌មាន, សកម្មភាពដែលត្រូវអនុវត្ត និងការសម្រេចនានាជម្រាបជូនក្រសួង ឬស្ថាប័នសាមី ។
- *ដៃគូអភិវឌ្ឍន៍ដទៃដែលធ្វើការក្នុងវិស័យ* : ដៃគូអភិវឌ្ឍន៍ដែលចូលរួមក្នុងក្រុមការងារ ត្រូវមានតួនាទី និងសមត្ថភាពសមស្រប និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចែករំលែកព័ត៌មាន និងផ្តល់ការគាំទ្រដល់ប្រធានក្រុមការងារក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ។ ដៃគូអភិវឌ្ឍន៍ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកម្មវិធី

6

ឬកម្មវិធីដែលកំពុងគាំទ្រ ឬគ្រោងផ្តល់ការគាំទ្រ ។ លើសពីនេះ ក៏ត្រូវចែករំលែកព័ត៌មានស្តីពីការសម្រេចរបស់ក្រុមការងារដល់ដៃគូអភិវឌ្ឍន៍ដទៃផងដែរ ។

- *តំណាងគណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក)* : មន្ត្រីជាន់ខ្ពស់នៃ គ.ជ.ន/ក.អ.ក គឺជាសមាជិករបស់ក្រុមការងារ ដែលអាចផ្តល់ប្រឹក្សាយោបល់ និងការគាំទ្រផ្នែកបច្ចេកទេស ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងស័ក្តិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍ ស្របតាមយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩២០២៣ ។ ទន្ទឹមនេះ ក៏អាចផ្តល់ការគាំទ្រ ផ្អែកតាមសំណើជាក់ស្តែងរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះ (សូមពិនិត្យខ្លឹមសារលម្អិតក្នុងទំព័រទី ៩)។
- *មន្ត្រីបង្គោលសម្រាប់កិច្ចការអន្តរវិស័យ* : មន្ត្រីបង្គោលត្រូវចាត់តាំងដោយប្រធានក្រុមការងារ ដោយត្រូវពិភាក្សាជាមួយក្រសួង ឬស្ថាប័នស្ថាប័នសាមី ។ ក្នុងករណីចាំបាច់ មន្ត្រីបង្គោលសម្រាប់ការងារអន្តរៈវិស័យ អាចជាសមាជិក នៃក្រុមការងារបញ្ញាបយេនឌ័រ ការកែទម្រង់វិស័យសាធារណៈ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុនៅតាមក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។
- *ទីប្រឹក្សាបច្ចេកទេសក្នុងគម្រោងឬកម្មវិធី នៅតាមក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល*: ទីប្រឹក្សាបច្ចេកទេស (សញ្ជាតិខ្មែរ ឬបរទេស) អាចចូលរួមកិច្ចប្រជុំរបស់ក្រុមការងារក្នុងឋានៈជាអ្នកជំនាញការ និងជាប្រភពធនធានសំខាន់សម្រាប់ការអភិវឌ្ឍសមត្ថភាព ។ ប៉ុន្តែ ទីប្រឹក្សាទាំងនោះមិនត្រូវបំពេញតួនាទីជាប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ឬក៏បំពេញមុខងារជំនួសឱ្យក្រសួង និងស្ថាប័នបានឡើយ ។
- *តំណាងសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាល* :ក្រុមការងារបច្ចេកទេសចម្រុះអាចអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ឱ្យចូលរួមក្នុងក្រុមការងារ ។ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនេះ ត្រូវមានតួនាទីច្បាស់លាស់ ឬ/និងត្រូវផ្តល់ការគាំទ្រ ឬ/និងផ្តល់សេវាក្នុងវិស័យដែលពាក់ព័ន្ធនឹងក្រុមការងារ ។ លើសពីនេះ ក៏ត្រូវបង្ហាញអំពីសមត្ថភាព និងឆន្ទៈក្នុងការធ្វើជាតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលទាំងមូល ហើយត្រូវផ្តល់ព័ត៌មានស្តីពីគម្រោងដែលកំពុងអនុវត្ត (តាមរយៈប្រព័ន្ធទិន្នន័យអង្គការមិនមែនរដ្ឋាភិបាលរបស់ គ.ជ.ន/ ក.អ.ក) ។ តំណាងសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវសម្របសម្រួលជាមួយភាគីរៀងៗខ្លួន និងកំណត់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ ។

៣- <u>*ទំហំរបស់ក្រុមការងារបច្ចេកទេសចម្រុះ នឹងការប្រើប្រាស់អនុក្រុមការងារ*</u>

កិច្ចប្រជុំពេញអង្គរបស់ក្រុមការងារ បានផ្តល់កាលានុវត្តភាពសម្រាប់ចែករំលែកព័ត៌មាន ប៉ុន្តែដំណើរការបែបនេះក៏អាចជាឧបសគ្គរាំងស្ទះដល់ប្រសិទ្ធភាពនៃកិច្ចប្រជុំ ។ ក្រុមការងារចម្រុះត្រូវមានរចនាសម្ព័ន្ធ និងទំហំសមល្មមដែលមានតំណាងពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាបានលទ្ធផលខ្ពស់ក្នុងការពិភាក្សា ។ ក្នុងន័យនេះ ក្រុមការងារគប្បីអនុវត្តតាមគោលការណ៍ដូចខាងក្រោម÷

7

- ប្រធានក្រុមការងារ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ដោយពិភាក្សាជាមួយសមាជិក ត្រូវកំណត់ចំនួនសមាជិកអតិបរមារបស់ខ្លួន ។
- ក្នុងករណីតម្រូវឱ្យមានសមាជិកច្រើន ដែលស្ថានភាពនេះអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចពិភាក្សា ក្រុមការងារអាចបង្កើតក្រុមការងារស្នូល ដែលអាចជួបប្រជុំទៀងទាត់ ហើយត្រូវរាយការណ៍ពីលទ្ធផលការងារជូនអង្គប្រជុំពេញអង្គរបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុមការងារស្នូល អាចចែករំលែកព័ត៌មានស្ដីពីវឌ្ឍនភាពការងារដល់ដៃគូអភិវឌ្ឍន៍ដទៃ ។
- ក្រុមការងារអាចបង្កើតអនុក្រុមការងារ (ដូចធ្លាប់បានអនុវត្តក្នុងក្រុមការងារមួយចំនួន) ដើម្បីឆ្លើយតបនឹងការប្រែប្រួលបរិការណ៍ និងតម្រូវការរបស់ខ្លួន។ អនុក្រុមការងារអាចជាយន្តការសម្រាប់ដោះស្រាយលម្អិត នូវបញ្ហាជាក់លាក់ និងតាមកាលបរិច្ឆេទកំណត់ ឬអាចបំពេញការងារជាប្រចាំ ។ ការបង្កើតអនុក្រុមការងារមានសារៈប្រយោជន៍ សម្រាប់គាំទ្រការកែទម្រង់ និងការអភិវឌ្ឍសមត្ថភាព ព្រមទាំងដោះស្រាយបញ្ហាអន្តរវិស័យ ។ លទ្ធផលនៃកិច្ចពិភាក្សាក្នុងអនុក្រុមការងារត្រូវរាយការណ៍ក្នុងកិច្ចប្រជុំពេញអង្គរបស់ក្រុមការងារ ដើម្បីពិភាក្សា និងឯកភាពលើការងារចាំបាច់សម្រាប់អនុវត្តបន្ត ។

៤- <u>*កិច្ចដំណើរការប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ*</u>

ដើម្បីធានាប្រសិទ្ធភាព ក្រុមការងារគប្បីគួរយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម សម្រាប់រៀបចំក្រុមការងារ និងកំណត់របៀបដំណើរការកិច្ចប្រជុំរបស់ខ្លួន÷

- ផែនការសកម្មភាពប្រចាំឆ្នាំ និងសូចនាករតាមដានរួមគ្នា ព្រមទាំងសកម្មភាពសម្រាប់ដោះស្រាយបញ្ហាអន្តរវិស័យ គឺជាមូលដ្ឋានសម្រាប់រៀបចំកិច្ចប្រជុំ ដើម្បីធានាថា កិច្ចពិភាក្សាបានផ្ដោតចំគោលដៅ ។
- ក្រុមការងារអាចជួបប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ឬតាមការចាំបាច់ ។ កិច្ចប្រជុំត្រូវមានរបៀបវារៈច្បាស់លាស់ និងមានសំណុំឯកសារចាំបាច់ ដែលត្រូវចែកជូនសមាជិកចូលរួម ឱ្យបានយ៉ាងតិច ១០ ថ្ងៃ មុនពេលកិច្ចប្រជុំ ។
- ការប្រជុំត្រៀម ឬកិច្ចប្រជុំតាមដានវឌ្ឍនភាពការងារ រវាងប្រធានក្រុមការងារ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងសមាជិកសំខាន់ៗ ក៏ដូចជាការប្រជុំត្រៀមរបស់ដៃគូអភិវឌ្ឍន៍ អាចជួយឱ្យការពិភាក្សា និងការតាមដានវឌ្ឍនភាពរបស់ក្រុមការងារ បានចំគោលដៅ និងមានប្រសិទ្ធភាព ។
- កិច្ចប្រជុំត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សា ហើយសមាជិកទាំងអស់មានឱកាសគ្រប់ៗគ្នា សម្រាប់លើកបញ្ហាសំខាន់ៗជូនអង្គប្រជុំ ។

៥- <u>*យន្តការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ*</u>

<u>*យន្តការគាំទ្រផ្ទៃក្នុង*</u>

ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ត្រូវជួបប្រជុំទៀងទាត់

8

សម្រាប់តាមដានវឌ្ឍនភាពការងារដែលបានឯកភាពគ្នា ពិសេសមុនកិច្ចប្រជុំរបស់ក្រុមការងារ ។ ដំណើរការតាមរបៀបនេះអាចបង្កើនជំនឿទុកចិត្តទៅវិញទៅមក និងជំរុញឱ្យមានការពិភាក្សាដោយបើកចំហរ ។

ការរៀបចំលេខាធិការដ្ឋានរបស់ក្រុមការងារប្រកបដោយសមត្ថភាព និងមានធនធានគ្រប់គ្រាន់នៅតាមក្រសួង ឬស្ថាប័ន គឺជាការចាំបាច់សម្រាប់គាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ។ លេខាធិការដ្ឋានត្រូវបំពេញភារកិច្ចដូចខាងក្រោម÷

- រៀបចំអាណត្តិការងាររបស់ខ្លួនឱ្យបានច្បាស់លាស់ ។
- រៀបចំកិច្ចប្រជុំ, រៀបចំកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងារ ឬអនុក្រុមការងារ និងចែករំលែកព័ត៌មានទាំងនេះដល់សមាជិក មុនឬក្រោយពេលប្រជុំ ។
- ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពដែលបានឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ។
- បំពេញតួនាទីជាចំណុចប្រមូលផ្តុំសម្រាប់ទំនាក់ទំនងរវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក៏ដូចជាសមាជិកដទៃ ។
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារ និងរបាយការណ៍វឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា ព្រមទាំងបំពេញតួនាទីជាចំណុចប្រមូលផ្តុំសម្រាប់សម្របសម្រួលជាមួយ គ.ជ.ន/ក.អ.ក ។

ដើម្បីចៀសវាងការបង្កើតរចនាសម្ព័ន្ធថ្មីបន្ថែម លេខាធិការដ្ឋានអាចជាផ្នែកមួយនៃរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួង ឬស្ថាប័ន ដូចជានាយកដ្ឋានផែនការ ឬនាយកដ្ឋានសហប្រតិបត្តិការជាដើម ។ ក្រុមការងារត្រូវកៀរគរធនធាន ទាំងក្នុងប្រទេស ទាំងពីដៃគូអភិវឌ្ឍន៍ (ធនធានមួយផ្នែករបស់ក្រសួង និងស្ថាប័នសម្រាប់អភិវឌ្ឍសមត្ថភាព ឬជាធនធានសម្រាប់គាំទ្រផ្ទាល់ដល់ក្រុមការងារ) ដើម្បីគាំទ្រសកម្មភាពរបស់លេខាធិការដ្ឋាន ។

*<u>ការគាំទ្ររបស់ គ.ជ.ន/ក.អ.ក ដល់ក្រុមការងារបច្ចេកទេសចម្រុះ</u>*

គ.ជ.ន/ក.អ.ក ផ្តល់ការគាំទ្រដល់ក្រុមការងារ ក្នុងឋានៈជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ និងអ្នករៀបចំកិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ។

- មន្ត្រីបង្គោលរបស់ គ.ជ.ន/ក.អ.ក ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ដើម្បីផ្តល់ការគាំទ្រ និងផ្តល់ប្រឹក្សាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ ក៏អាចផ្តល់ការគាំទ្រចាំបាច់ដែលពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍, ឧបករណ៍ និងយន្តការនានា ដូចមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។
- គ.ជ.ន/ក.អ.ក បំពេញតួនាទីជាមជ្ឈមណ្ឌលប្រមូលផ្តុំសម្រាប់ចែករំលែកព័ត៌មានដល់ក្រុមការងារទាំងអស់ និងរៀបចំកិច្ចប្រជុំរបស់បណ្តាញក្រុមការងារ ដើម្បីផ្តល់កាលានុវត្តភាពដល់ក្រុមការងារទាំងអស់អាចចែករំលែកព័ត៌មាន និងបទពិសោធន៍ ព្រមទាំងឯកភាពលើវិធានការដែលត្រូវអនុវត្តបន្ត ក្នុងគោលដៅលើកកម្ពស់សមិទ្ធកម្មរបស់ក្រុមការងារ ។

9

- គ.ជ.នា/ក.អ.ក នឹងបន្តសម្របសម្រួលដល់កិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ដែលនឹងត្រូវរៀបចំម្តងក្នុង១ឆ្នាំ ឬតាមការចាំបាច់ ។ កិច្ចប្រជុំនេះនឹងផ្តល់កាលានុវត្តភាពសម្រាប់ក្រុមការងារចែករំលែកព័ត៌មាន និងបទពិសោធន៍ ព្រមទាំងឧត្តមានុវត្តន៍ ។

៦- _លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតក្រុមការងារបច្ចេកទេសចម្រុះថ្មី_

លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតក្រុមការងារបច្ចេកទេសចម្រុះ ដូចខាងក្រោម÷

- ក្រុមការងារត្រូវកំណត់គោលដៅច្បាស់លាស់ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬយុទ្ធសាស្ត្រតាមវិស័យ សម្រាប់គាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល តាមរយៈការងាររបស់ខ្លួន ។
- មិនចាំបាច់បង្កើតយន្តការស្រប ឬយន្តការបន្ថែម ក្នុងករណីដែលមានយន្តការសម្របសម្រួល និងចែករំលែកព័ត៌មានរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។
- ក្រុមការងារត្រូវកំណត់ប្រធានបទ ឬវិស័យទទួលខុសត្រូវឱ្យច្បាស់លាស់ ។ ក្នុងករណីចាំបាច់ ក្រុមការងារអាចបង្កើតអនុក្រុមការងារ សម្រាប់ដោះស្រាយបញ្ហាតាមសមាសភាគនីមួយៗនៃប្រធានបទ ឬវិស័យ ។
- ក្រុមការងារមិនគួរកំណត់ប្រធានបទ ឬវិស័យទូលំទូលាយពេកទេ ព្រោះអាចបង្កការលំបាកដល់ការកំណត់ភារកិច្ចទទួលខុសត្រូវ ក៏ដូចជាការតាមដានអំពីវឌ្ឍនភាពនៅតាមក្រសួង ឬស្ថាប័នពាក់ព័ន្ធ (បញ្ហាអន្តរវិស័យត្រូវបានបញ្ជ្រាបនៅតាមវិស័យ និងក្រុមការងារ)។
- មុននឹងបង្កើត ឬរំលាយក្រុមការងារ, ក្រសួង ឬស្ថាប័នសាមី (ក្នុងករណីចាំបាច់ អាចពិភាក្សាជាមួយនឹង គ.ជ.នា/ក.អ.ក) ត្រូវរៀបចំសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច ។

## VI - ការផ្សារភ្ជាប់ជាមួយកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ

ក្នុងបរិការណ៍ប្រែប្រួលយ៉ាងឆាប់រហ័សនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, រាជរដ្ឋាភិបាលទទួលស្គាល់ពីភាពចាំបាច់ឱ្យមានកិច្ចពិគ្រោះយោបល់ពហុភាគី ដែលមានកម្រិតខ្ពស់ជាងកម្រិតបច្ចេកទេស ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ បានកំណត់ថា កិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ គឺជាយន្តការភាពជាដៃគូប្រកបដោយប្រសិទ្ធភាព សម្រាប់លើកកម្ពស់ការពិភាក្សា និងការសម្របសម្រួល ពីកម្រិតបច្ចេកទេស ទៅកម្រិតមួយខ្ពស់ជាងនេះ ។ សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ត្រូវបានរៀបចំ ដើម្បីធានាប្រសិទ្ធភាពខ្ពស់នៃកិច្ចពិគ្រោះយោបល់ ។ យន្តការទាំងពីរនេះមានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក ប៉ុន្តែមិនជំនួសឱ្យគ្នាបានឡើយ ។ ក្រុមការងារបច្ចេកទេសចម្រុះនៅរក្សាតួនាទីសំខាន់ ដូចមានចែងក្នុងសេចក្តីណែនាំរបស់ខ្លួន ។ រីឯកិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ អាចផ្តល់តម្លៃបន្ថែម ពីព្រោះ ÷ ក) ជាកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់, ខ) ជាវេទិកាសម្រាប់ការសម្រេចចិត្តកម្រិតខ្ពស់, គ) មានការចូលរួមទូលំទូលាយពីតួអង្គពាក់ព័ន្ធ, ឃ) ផ្តល់កាលានុវត្តភាពសម្រាប់ធ្វើការប្តេជ្ញាផ្តល់ធនធាន ពិសេសដៃគូអភិវឌ្ឍន៍ និង ង) កំណត់ផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ ឬរយៈពេលមធ្យម ។

10

# ឧបសម្ព័ន្ធទី២
# កម្រងសំណួរ

# ឧបសម្ព័ន្ធទី២

**កម្រងសំណួរ**

**ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត**

( P-JTWG )

វត្ថុបំណង៖

១.ដើម្បីសិក្សាស្វែងយល់ពីយន្តការនៃការដំណើរក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តដែលបាន ដំណើរការចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និង

២.បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ/អនុសាសន៍ ដែលបានជួបប្រទះកន្លងមក។

ឈ្មោះ..................................... ភេទ ☐ប្រុស ☐ស្រី

តួនាទី៖.....................................

អង្គភាព៖.....................................

1. **តើយន្តការនៃដំណើរការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តយ៉ាងដូចម្តេចខ្លះ**?

1.1. **ការដំណើរការមុនកិច្ចប្រជុំ**

**1.1.1. តើការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់កិច្ចប្រជុំក្រុមការងារ(PJTWG)មានការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធណាខ្លះ?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំមន្ទីរ ☐2. ពិគ្រោះយោបល់ជាមួយក្រុមការងារវិស័យអប់រំ

☐3.ពិគ្រោះយោបល់ជាមួយមន្ទីរវិស័យ ☐4.ពិគ្រោះយោបល់គ្រប់ផ្នែកទាំងអស់

☐3.មិនពិគ្រោះយោបល់

1.1.2. **តើក្រុមការងារនេះបានពិគ្រោះយោបល់ពាក់ព័ន្ធនឹងអ្វីខ្លះក្នុងផែនការសម្មភាពប្រចាំឆ្នាំ?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ការអភិវឌ្ឍវិស័យអប់រំក្នុងមូលដ្ឋាន ☐2.ដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន

☐3.វឌ្ឍនភាពតាមការិយាល័យជំនាញ ☐4.វឌ្ឍនភាពរបស់P-ESWG

☐5.ការងារឆ្លងវិស័យ(សុខភាពចំណីអាហារ ចរាចរណ៍ គ្រឿងញៀន...) ☐6.ផ្សេងទៀត.........

**1.1.3. តើការកំណត់កាលបរិច្ឆេទប្រជុំធ្វើឡើងដោយមានសមាសភាពណាខ្លះចូលរួម?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ប្រធានក្រុមការងារ ☐2.ប្រធានមន្ទីរ ☐3.លេខាធិការដ្ឋាន

☐4.ប្រធានក្រុមការងារវិស័យអប់រំ(PESWG)

☐5.ប្រធានការិយាល័យ ☐6.គ្រប់ផ្នែកទាំងអស់ ☐7.ផ្សេងទៀត៖......

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

**1.1.4. តើការកំណត់របៀបវារៈប្រជុំធ្វើឡើងដោយផ្អែកលើភាគីពាក់ព័ន្ធ/ផ្នែកណាខ្លះ?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ផែនការសកម្មភាព ☐2.ការស្នើរបស់ក្រុមការងារESWG ☐3.ការស្នើរបស់មន្ទីរវិស័យ

☐4.តាមការចាំបាច់ ☐5.គ្រប់ផ្នែកទាំងអស់ ☐6.ផ្សេងទៀត៖.........

**1.1.5. តើការកំណត់របៀបវារៈប្រជុំបានឆ្លងយោបល់ជាមួយអ្នកពាក់ព័ន្ធណាខ្លះ?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ប្រធានក្រុមការងារ ☐2.ថ្នាក់ដឹកនាំមន្ទីរ ☐3.ប្រធានក្រុមការងារESWG

☐4.ប្រធានការិយាល័យជំនាញ ☐5.គ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ ☐6.មិនបានឆ្លងផ្នែកណាទេ

☐7.ផ្សេងទៀត៖.....

**1.1.6. តើការកំណត់របៀបវារៈមានពាក់ព័ន្ធនឹងសកម្មភាពអ្វីខ្លះ?**

**ចូរគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

☐2.ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរាជធានីខេត្ត

☐3.ការរៀបចំរបាយការណ៍សន្និបាតអប់រំរាជធានីខេត្ត

☐4.វឌ្ឍនភាពការងារអប់រំរបស់ដៃគូអភិវឌ្ឍន៍ ☐5.លទ្ធផលការងារតាមផ្នែកការិយាល័យ

☐6.លទ្ធផលការងារវិស័យអប់រំក្នុងរាជធានីខេត្ត ☐7.ការពិនិត្យតាមដាននិងវាយតម្លៃ

☐8.បញ្ហាប្រឈមនិងដំណោះស្រាយ ☐9.ផ្សេងទៀត៖....

**1.1.7. តើការកំណត់របៀបវារៈមានការពាក់ព័ន្ធនឹងផ្នែកវិស័យពាក់ព័ន្ធ ដូចជា៖ មន្ទីរអេយក មន្ទីរវិស័យពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍កម្រិតណា?**

**ចូលគូស✓លើប្រអប់ចម្លើយមួយខាងក្រោម៖**

**1.1.7.1. មន្ទីរអេយក**

☐1.៨០% -១០០% ☐2.៦០%-៨០% ☐3.៥០% ☐4.២០%-៤០%

☐5.0%-២០%

**1.1.7.2. មន្ទីរវិស័យពាក់ព័ន្ធ**

☐1. ៨០% -១០០% ☐2.៦០%-៨០% ☐3.៥០% ☐4.២០%-៤០%

☐5.0%-២០%

**1.1.7.3. ដៃគូអភិវឌ្ឍន៍**

☐1. ៨០% -១០០% ☐2.៦០%-៨០% ☐3.៥០% ☐4.២០%-៤០%

☐5.0%-២០%

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

2.1.8. **តើការសម្របសម្រួលរបស់លេខាធិការដ្ឋានសម្រាប់ដំណើរការប្រជុំកម្រិតណាខ្លះ?**

ចូរគូស✓តាមកម្រិត ដូចខាងក្រោម៖

| ល.រ | សកម្មភាព | 1 ល្អណាស់ | 2 ល្អ | 3 បង្គួរ | 4 មធ្យម | 5 ត្រូវកែលម្អ |
|---|---|---|---|---|---|---|
| 2.1.8.1 | ឆ្លងកម្មវិធីប្រជុំជាមួយថ្នាក់ដឹកនាំមន្ទីរ | | | | | |
| 2.1.8.2 | រៀបចំកម្មវិធីប្រជុំមានរបៀបវារៈច្បាស់លាស់ | | | | | |
| 2.1.8.3 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយផ្នែកវិស័យ/ការិយាល័យជំនាញ | | | | | |
| 2.1.8.4 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយក្រុមESWG | | | | | |
| 2.1.8.5 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយមន្ទីរវិស័យ | | | | | |
| 2.1.8.6 | ការផ្ញើបទបង្ហាញមានផ្នែកទទួលខុសត្រូវច្បាស់លាស់ | | | | | |
| 2.1.8.7 | ជូនដំណឹងពីកម្មវិធីប្រជុំដល់ផ្នែកពាក់ព័ន្ធ | | | | | |
| 2.1.8.8 | សម្ភារឧបទ្ទេសសមស្របសម្រាប់បទបង្ហាញ | | | | | |
| 2.1.8.9 | មានលេខាកត់ត្រាកំណត់ហេតុ/របាយការណ៍ | | | | | |
| 2.1.8.10 | កិច្ចប្រជុំស្របតាមកម្មវិធីបានកំណត់ | | | | | |
| 2.1.8.11 | បូកសរុបលទ្ធផលកិច្ចប្រជុំ | | | | | |
| 2.1.8.12 | ទីកន្លែងប្រជុំសមស្រប | | | | | |
| 2.1.8.13 | ចំនួនអ្នកចូលរួមសមស្រប | | | | | |
| 2.1.8.14 | អាហារសំរ៉ន់សម្រាប់អ្នកចូលរួម | | | | | |
| 2.1.8.15 | ការរៀបចំរបាយការណ៍ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | | | | | |
| 2.1.8.16 | ផ្ញើរបាយការណ៍ជូនផ្នែកពាក់ព័ន្ធ | | | | | |

1.1.8. **តើអ្នកពាក់ព័ន្ធណាខ្លះតែងតែធ្វើបទបង្ហាញក្នុងកិច្ចប្រជុំ?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ប្រធានមន្ទីរ 2.☐លេខាធិការដ្ឋាន ☐3. ប្រធានក្រុមESWG ☐4.មន្ទីរវិស័យ

☐5.លេខាធិការដ្ឋាននិងESWG ☐6.គ្រប់ផ្នែកខាងលើ ☐7.ផ្សេងទៀត៖....

1.2. **ការដំណើរការពេលកិច្ចប្រជុំ**

1.2.1. **តើកិច្ចប្រជុំអនុវត្តតាមផែនការសកម្មភាពបានទៀងទាត់ដែរឬទេ?**

☐1.បាទ ☐2.អត់ទេ

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

បើអត់ទេ សូមបញ្ជាក់៖ ……………………………………………

**1.2.2. តើកិច្ចប្រជុំបានដំណើរការប៉ុន្មានដងក្នុង១ឆ្នាំ?**

**ចូលគូស✓លើប្រអប់ចម្លើយមួយខាងក្រោម៖**

☐1.ប្រជុំបាន១ដង ☐2. ប្រជុំបាន២ដង ☐3. ប្រជុំបាន៣ដង ☐4.ប្រជុំបាន៤ដង

☐5.មិនបានប្រជុំសោះ

☐6.ផ្សេងទៀត៖……

**1.2.3. តើថ្នាក់ដឹកនាំណាមួយជាប្រធានដឹកនាំអង្គប្រជុំ?**

**ចូលគូស✓លើប្រអប់ចម្លើយមួយខាងក្រោម៖**

☐1.គណៈអភិបាលខេត្ត ☐2.ប្រធានមន្ទីរអយក ☐3.ប្រធានលេខាធិការដ្ឋាន

☐4.ផ្សេងទៀត៖………

**1.2.4. តើសមាជិកនៃក្រុមការងារPJTWGណាខ្លះតែងតែចូលរួមកិច្ចប្រជុំញឹកញាប់?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.រដ្ឋបាលរាជធានីខេត្ត ☐2.ការិយាល័យទាំងអស់នៃមន្ទីរ ☐3.ការិយាល័យពាក់ព័ន្ធនៃមន្ទីរ

☐4.មន្ទីរវិស័យពាក់ព័ន្ធទាំងអស់ ☐5.មន្ទីរវិស័យពាក់ព័ន្ធខ្លះ ☐6.ក្រុមESWG ☐7.ផ្សេងទៀត៖

………………………

**1.2.5. តើសមាសភាពថ្នាក់ដឹកនាំនៃក្រុមការងារP-JTWGណាខ្លះតែងតែបានចូលរួមកិច្ចប្រជុំញឹកញាប់?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.គណៈអភិបាលខេត្ត/ប្រធានកិត្តិយស ☐2.ប្រធាន/អនុប្រធានP-JTWG

☐3.ប្រធាន/អនុប្រធានការិយាល័យនៃមន្ទីរ ☐4.ប្រធាន/អនុប្រធានការិយាល័យនៃមន្ទីរវិស័យ

☐5.ប្រធាន/ប្រធានP-ESWG ☐6.តំណាងជំនួស

**1.2.6. តើក្រុមការងារP-JTWGបានពិភាក្សាលើរបៀបវារៈដែលបានកំណត់ក្នុងផែនការសកម្មភាពឬទេ?**

☐1.បាទ ☐2.អត់ទេ

បើអត់ទេ សូមបញ្ជាក់៖……………………………………………

1.2.6.1. **តើក្រុមការងារP-JTWGបានពិភាក្សាលើប្រធានបទពាក់ព័ន្ធអ្វីខ្លះ?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1. ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ☐2.ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

☐3.ផែនការយុទ្ធសាស្ត្រវិស័យអប់រំរាជធានី ខេត្ត ☐4.ការរៀបចំសន្និបាតអប់រំរាជធានីខេត្ត

☐5.ការងាររៀននិងបង្រៀន ☐6.ការងារនៃការិយាល័យជំនាញ

☐7.ការងារឆ្លងវិស័យ(សុខភាពចំណីអាហារ ចរាចរណ៍ គ្រឿងញៀន...) ☐8.ការងារក្រុមP-ESWG ☐9.ផ្សេងទៀត………

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

1.2.6.2. **តើក្រុមការងារP-JTWGបានពិភាក្សាលើប្រធានបទពាក់ព័ន្ធអ្វីខ្លះ? ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1. ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ☐2.ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

☐3.ផែនការយុទ្ធសាស្ត្រវិស័យអប់រំរាជធានី ខេត្ត ☐4.ការរៀបចំសន្និបាតអប់រំរាជធានីខេត្ត

☐5.ការងាររៀននិងបង្រៀន ☐6.ការងារនៃការិយាល័យជំនាញ

☐7.ការងារឆ្លងវិស័យ(សុខភាពចំណីអាហារ ចរាចរណ៍ គ្រឿងញៀន...) ☐8.ការងារក្រុមP-ESWG ☐9.ផ្សេងទៀត.........

1.2.7. **តើសមាជិកនីមួយៗបានចូលរួមផ្ដល់យោបល់ក្នុងកិច្ចប្រជុំកម្រិតណាខ្លះ? ចូលគូស✓លើប្រអប់ចម្លើយមួយខាងក្រោម៖**

☐1.ល្អណាស់ ☐2.ល្អ ☐3.ល្អបង្គួរ ☐4.មធ្យម

☐5.គ្មានយោបល់

បើជ្រើសរើសកម្រិតណាមួយ សូមបញ្ជាក់៖...............................................

1.2.8. **តើអង្គភាពជាសមាជិកពាក់ព័ន្ធណាខ្លះសមស្របដែលអាចដំណើរការប្រជុំក្រុមP-JTWGបាន? ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ការិយាល័យទាំងអស់នៃមន្ទីរអយក ☐2.ការិយាល័យពាក់ព័ន្ធនៃមន្ទីរអយក

☐3.ក្រុមESWG

☐4.មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ☐5.ខុទ្ទការល័យសាលារាជធានីខេត្ត

☐6.មន្ទីរផែនការ ☐7.មន្ទីរកិច្ចការនារី ☐8.មន្ទីរសុខាភិបាល

☐9.មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ☐10.អង្គការមិនមែនរាជរដ្ឋាភិបាល

☐11.ផ្សេងទៀត៖....

2.3. **ដំណើរការក្រោយកិច្ចប្រជុំ**

2.3.1. **តើការរៀបចំរបាយការណ៍ធ្វើឡើងយ៉ាងដូចម្ដេច? ចូរគូស✓ក្នុងប្រអប់ចម្លើយមួយខាងក្រោម៖**

☐1. ថ្នាក់ដឹកនាំមន្ទីររៀបចំ

☐2. លេខាធិការដ្ឋានរៀបចំ

☐3. ថ្នាក់ដឹកនាំមន្ទីរ និងលេខាធិការដ្ឋានរៀបចំ

☐4. ថ្នាក់ដឹកមន្ទីរនាំ លេខាធិការដ្ឋាន និងក្រុមESWGរៀបចំ

☐5. ថ្នាក់ដឹកនាំមន្ទីរ លេខាធិការដ្ឋាន ក្រុមESWG និងមន្ទីរវិស័យរៀបចំ

☐6. មិនមានការចូលរួមពីអ្នកពាក់ព័ន្ធរៀបចំ

2.3.2. **តើខ្លឹមសាររបាយការណ៍នៃអង្គប្រជុំកម្រិតណាខ្លះ? ចូរគូស(✓)លើតារាងតាមកម្រិតខាងក្រោម៖**

| ល.រ | ខ្លឹមសារ | 1<br>ល្អណាស់ | 2<br>ល្អ | 3<br>ល្អបង្គួរ | 4<br>មធ្យម | 5<br>ត្រូវកែលម្អ |
|---|---|---|---|---|---|---|
| ១ | ស្របតាមស្មារតីអង្គប្រជុំ | | | | | |
| ២ | វត្ថុបំណង | | | | | |

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | របៀបវារៈ | | | | | |
| ៤ | ខ្លឹមសារតាមរបៀបវារៈ | | | | | |
| ៥ | បញ្ជាក់ពីចំណុចឯកភាព | | | | | |
| ៦ | បូកសរុបលទ្ធផល | | | | | |
| ៧ | ទិសដៅអនុវត្តបន្ត | | | | | |

2.3.3. **តើការរៀបចំរបាយការណ៍រួចរាល់ប្រើរយៈពេលប៉ុន្មាន?**

**ចូលគូស✓លើប្រអប់ចម្លើយមួយខាងក្រោម៖**

☐1.ចាប់ពី១-៣ថ្ងៃ ☐2.ចាប់ពី៣ថ្ងៃ-១សប្តាហ៍ ☐3.ចាប់ពី១-២សប្តាហ៍

☐4.ចាប់ពី២សប្តាហ៍

**2.3.4. តើរបាយការណ៍ត្រូវបានចែកជូនដល់ផ្នែកពាក់ព័ន្ធណាខ្លះ?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយ ខាងក្រោម៖**

☐1.ក្រសួងអប់រំ យុវជន និងកីឡា ☐2.សាលារាជធានីខេត្ត ☐3.ប្រធានមន្ទីរ

☐4.ការិយាល័យពាក់ព័ន្ធ ☐5.ក្រុមESWG ☐6.មន្ទីរវិស័យពាក់ព័ន្ធ 7.ផ្សេងទៀត៖.....

3. **តើការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្តមានបញ្ហាប្រឈមចំបងៗ ដំណោះស្រាយ និងសំណូមពរឬអនុសាសន៍អ្វីខ្លះ?**

**3.3. តើដំណើរការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំបានជួបបញ្ហាប្រឈមអ្វីខ្លះ?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ការប្រជុំមិនតាមផែនការសកម្មភាពប្រចាំឆ្នាំ

☐2.ថ្នាក់ដឹកនាំមន្ទីរពុំមានការតាំងចិត្តខ្ពស់

☐3.ការទំនាក់ទំនងរវាង មន្ទីរអយក មន្ទីរពាក់ព័ន្ធ និងក្រុមP-ESWG

☐5.ការផ្តល់ធាតុចូលពីផ្នែកពាក់ព័ន្ធ

☐6.ថវិកាសម្រាប់ដំណើរការប្រជុំ

☐7.សមាសភាពចូលរួមមិនគ្រប់គ្រាន់ និងមិនមែនជាសមាជិកក្រុមការងារ

☐8.ភាពមមាញឹកនឹងការងាររបស់សមាជិកនៃក្រុមការងារ

☐9.ការកំណត់ពីតួនាទី និងការទទួលខុសត្រូវនៃក្រុម P-JTWG មិនទាន់ច្បាស់លាស់

☐10.សមត្ថភាពនៃក្រុមលេខាធិកាដ្ឋាន លើការងារសម្របសម្រួល និងរៀបចំរបាយការណ៍នៅមានកម្រិត

☐11.ការពិនិត្យតាមដាន និងវាយតម្លៃទៅលើការអនុវត្ត

☐12.ផ្សេងទៀត៖............................................

**3.4. តើក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តមានដំណោះស្រាយអ្វីខ្លះ?**

**ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.លេខាធិការដ្ឋានជំរុញថ្នាក់ដឹកនាំកំណត់ពេលវេលាប្រជុំតាមផែនការ

☐2.ថ្នាក់ដឹកនាំឬប្រធានអង្គប្រជុំត្រូវមានការប្តេជ្ញាចិត្ត

☐3.ប្រើប្រាស់ថវិកាផ្សេងទៀតជំនួស/

☐4.ពុំចាំបាច់មានថវិកាក៏អាចដំណើរការប្រជុំបាន

☐5.កៀរគរថវិកាពីដៃគូអភិវឌ្ឍន៍បន្ថែម

☐6.ជូនដំណឹងដល់ផ្នែកពាក់ព័ន្ធពីសមាសភាពចូលរួម

☐7.សមាជិកក្រុមការងារជាពិសេសក្រុមESWGត្រូវរំលឹកដល់លេខាធិការដ្ឋាន

☐8.លេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡាត្រូវរំលឹក/ជំរុញដល់លេខាធិការដ្ឋាន

☐9.លេខាធិការដ្ឋានត្រូវពិនិត្យតាមដាន និងវាយតម្លៃ

☐10.ដាក់ចេញនូវវិធានការផ្សេងៗពីភាពអសកម្មភាព

☐11.ផ្សេងទៀត៖.....

**3.5. តើក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្តមានសំណូមពរខ្លះ? ចូលគូស✓លើប្រអប់ចម្លើយច្រើនជាងមួយខាងក្រោម៖**

☐1.ក្រសួងអយកសហការជាមួយអន្តរក្រសួងពាក់ព័ន្ធ និងក្រុមការងារESWGជំរុញដល់មន្ទីរពាក់ព័ន្ធក្រោមឱវាទ និងក្រុមP-ESWG

☐2.រៀបចំសេចក្តីណែនាំថ្មីដោយបញ្ជាក់ពីតួនាទី និងភារកិច្ចឲ្យបានច្បាស់

☐3.ពង្រឹងសមត្ថភាពលេខាធិការដ្ឋាននៃក្រុមការងារ

☐4.ផ្តល់ថវិកាដំណើរការប្រជុំបានគ្រប់គ្រាន់ និងទាន់ពេល

☐5.ផ្សេងទៀត៖.....

4 .**សំណួរសម្ភាសន៍ផ្ទាល់មាត់**

**4.1 តើលោកលោកស្រីគិតថាមានយន្តការអ្វីផ្សេងដើម្បីឲ្យដំណើរក្រុមការងារនេះប្រព្រឹត្តទៅបានល្អប្រសើរ?**

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

**4.2. តើលោកលោកស្រីមានយុទ្ធសាស្ត្រអ្វីខ្លះក្នុងការជំរុញដល់ថ្នាក់ដឹកនាំក៏ដូចជាអ្នកពាក់ព័ន្ធប្រើប្រាស់យន្តការ នៃក្រុមការងារនេះទទួលបានលទ្ធផលផ្លែផ្កា?**

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

4.3. **តើលោកលោកស្រីមានសំណូមពរឬអនុសាសន៍សំខាន់ៗអ្វីផ្សេងទៀតសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ**?

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

ការប្រតិបត្តិនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានីខេត្ត

# ឧបសម្ព័ន្ធទី៣
# បញ្ជីតារាង និងដ្យាក្រាម

# ឧបសម្ព័ន្ធទី៣

តារាងទី១៖ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើស | % បានជ្រើសរើស | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំមន្ទីរ | 98 | 70.50 | 33% |
| 2 | ពិគ្រោះយោបល់ជាមួយក្រុមការងារវិស័យអប់រំ | 94 | 67.60 | 31% |
| 3 | ពិគ្រោះយោបល់ជាមួយមន្ទីរវិស័យ | 51 | 36.70 | 17% |
| 4 | ពិគ្រោះយោបល់គ្រប់ផ្នែកទាំងអស់ | 53 | 38.10 | 18% |
| 5 | មិនពិគ្រោះយោបល់ | 5 | 3.60 | 2% |
| | Total | 301 | | 100% |

តារាងទី២៖ របៀបវារៈក្នុងផែនការសកម្មភាពប្រចាំឆ្នាំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | % នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ការអភិវឌ្ឍវិស័យអប់រំក្នុងមូលដ្ឋាន | 98 | 70.5 | 31% |
| 2 | ដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន | 94 | 67.6 | 30% |
| 3 | វឌ្ឍនភាពតាមការិយាល័យជំនាញ | 51 | 36.7 | 16% |
| 4 | វឌ្ឍនភាពរបស់P-ESWG | 53 | 38.1 | 17% |
| 5 | ការងារឆ្លងវិស័យ | 5 | 3.6 | 2% |
| 6 | ផ្សេងៗ | 12 | 8.6 | 4% |
| | Total | 313 | | |

តារាងទី៣៖ការអនុវត្តកិច្ចប្រជុំតាមផែនការសកម្មភាពប្រចាំឆ្នាំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក |
|---|---|---|---|
| 1 | អនុវត្តតាមផែនការសកម្មភាព | 94 | 67.6% |
| 2 | មិនអនុវត្តតាមផែនការសកម្មភាព | 45 | 32.4% |
| | Total | | |

តារាងទី៤៖ អ្នកកំណត់កាលបរិច្ឆេទប្រជុំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | % នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ប្រធានក្រុមការងារPJTWG | 65 | 46.8% | 15% |
| 2 | ប្រធានមន្ទីរអយក | 97 | 69.8% | 22% |
| 3 | លេខាធិការដ្ឋាន | 76 | 54.7% | 17% |
| 4 | ប្រធានPESWG | 90 | 64.7% | 20% |
| 5 | ប្រធានការិយាល័យ | 55 | 39.6% | 12% |
| 6 | គ្រប់ផ្នែកទាំងអស់ | 55 | 39.6% | 12% |
| 7 | ផ្សេងទៀត | 9 | 6.5% | 2% |
| | Total | 447 | | |

តារាងទី៥៖ ផ្នែកពាក់ព័ន្ធ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើស | % បានជ្រើសរើស | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ផែនការសកម្មភាព | 96 | 69.1% | 30% |
| 2 | ការស្នើរបស់ក្រុមPESWG | 77 | 55.4% | 24% |
| 3 | ការស្នើរបស់មន្ទីរវិស័យ | 51 | 36.7% | 16% |
| 4 | តាមការចាំបាច់ | 53 | 38.1% | 17% |
| 5 | គ្រប់ផ្នែកទាំងអស់ | 36 | 25.9% | 11% |
| 6 | ផ្សេងទៀត | 8 | 5.8% | 2% |
| | Total | 321 | | |

តារាងទី៦៖ ការឆ្លងយោបល់លើរបៀបវារៈ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើស | % បានជ្រើសរើស | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ប្រធានក្រុមការងារ | 62 | 44.6% | 18% |
| 2 | ថ្នាក់ដឹកនាំមន្ទីរ | 100 | 71.9% | 29% |
| 3 | ប្រធានក្រុមPESWG | 77 | 55.4% | 23% |
| 4 | ប្រធានការិ.ជំនាញ | 54 | 38.8% | 16% |
| 5 | គ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ | 40 | 28.8% | 12% |
| 6 | មិនបានឆ្លងផ្នែកណាទេ | 3 | 2.2% | 1% |
| 7 | ផ្សេងទៀត | 3 | 2.2% | 1% |

| | | | | |
|---|---|---|---|---|
| | Total | 339 | | |

តារាងទី៧៖ របៀបវារៈពាក់ព័ន្ធ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើស | % បានជ្រើសរើស | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | AOP | 112 | 80.6% | 19% |
| 2 | P-ESP | 89 | 64.0% | 15% |
| 3 | ការរៀបចំរបាយការណ៍សន្និបាតអប់រំខេត្ត | 56 | 40.3% | 10% |
| 4 | វឌ្ឍនៈភាពការងារអប់រំរបស់ដៃគូអភិវឌ្ឍន៍ | 47 | 33.8% | 8% |
| 5 | លទ្ធផលការងារតាមការិយាល័យ | 59 | 42.4% | 10% |
| 6 | លទ្ធផលការងារវិស័យអប់រំក្នុងខេត្ត | 60 | 43.2% | 10% |
| 7 | ការពិនិត្យតាមដាននិងវាយតម្លៃ | 48 | 34.5% | 8% |
| 8 | បញ្ហាប្រឈមនិងដំណោះស្រាយ | 94 | 67.6% | 16% |
| 9 | ផ្សេងទៀត | 10 | 7.2% | 2% |
| | Total | 575 | | |

តារាងទី៨៖ របៀបវារៈដែលពាកព័ន្ធទៅតាមវិស័យនីមួយៗ

| ផ្នែកពាក់ព័ន្ធ | 80%-100% | 60%-80% | 50% | 20%-40% | 0%-20% |
|---|---|---|---|---|---|
| មន្ទីរអេយក | 56.1% | 36.0% | 4.3% | 2.9% | 0.7% |
| មន្ទីរវិស័យ | 8.6% | 23.0% | 18.7% | 28.8% | 20.9% |
| ដៃគូអភិវឌ្ឍន៍ | 24.5% | 20.9% | 26.6% | 21.6% | 6.5% |

តារាងទី៩៖ ប្រធានបទក្នុងកិច្ចប្រជុំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ការរៀបចំAOP | 112 | 80.6% | 18.5% |
| 2 | ការរៀបចំBSP | 89 | 64.0% | 14.7% |
| 3 | P-ESP | 56 | 40.3% | 9.2% |
| 4 | ការរៀបចំសន្និបាតអប់រំខេត្ត | 91 | 65.5% | 15.0% |
| 5 | ការងាររៀននិងបង្រៀន | 47 | 33.8% | 7.7% |
| 6 | ការងារការិយាល័យជំនាញ | 60 | 43.2% | 9.9% |
| 7 | ការងារឆ្លងវិស័យ | 48 | 34.5% | 7.9% |
| 8 | ការងារP-ESWG | 94 | 67.6% | 15.5% |

| | | | | |
|---|---|---|---|---|
| 9 | ផ្សេងទៀត | 10 | 7.2% | 1.6% |
| | Total | 607 | | |

តារាងទី១០៖ ការសម្របសម្រួលរបស់លេខាធិការដ្ឋាន

| ល.រ | ខ្លឹមសារ | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ត្រូវកែលម្អ |
|---|---|---|---|---|---|---|
| 1 | ឆ្លងកម្មវិធីជាមួយថ្នាក់ដឹកនាំមន្ទីរ | 15% | 64% | 14% | 6% | 1% |
| 2 | រៀបចំកម្មវិធីប្រជុំមានរបៀបវារៈច្បាស់លាស់ | 17% | 60% | 17% | 6% | 1% |
| 3 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយផ្នែកវិស័យ/កាវិ.ជំនាញ | 6% | 50% | 31% | 12% | 1% |
| 4 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយ ESWG | 6% | 50% | 26% | 16% | 2% |
| 5 | ពិភាក្សាជ្រើសរើសប្រធានបទជាមួយមន្ទីរវិស័យ | 10% | 63% | 19% | 8% | 1% |
| 6 | ការធ្វើបទបង្ហាញមានផ្នែកទទួលខុសត្រូវច្បាស់លាស់ | 13% | 67% | 14% | 6% | 0% |
| 7 | ជូនដំណឹងពីកម្មវិធីប្រជុំដល់ផ្នែកពាក់ព័ន្ធ | 9% | 58% | 27% | 6% | 1% |
| 8 | សម្ភារឧបទ្ទេសសមស្របសម្រាប់បទបង្ហាញ | 11% | 71% | 14% | 4% | 1% |
| 9 | មានកំណត់ហេតុ/របាយការណ៍ | 14% | 56% | 24% | 4% | 3% |
| 10 | កិច្ចប្រជុំស្របតាមកម្មវិធីបានកំណត់ | 12% | 63% | 19% | 4% | 3% |
| 11 | បូកសរុបលទ្ធផលកិច្ចប្រជុំ | 14% | 56% | 24% | 4% | 3% |
| 12 | ទីកន្លែងប្រជុំសមស្រប | 19% | 63% | 14% | 4% | 0% |
| 13 | ចំនួនអ្នកចូលរួមសមស្រប | 7% | 57% | 29% | 6% | 1% |
| 14 | អាហារសំរ៉ន់សម្រាប់អ្នកចូលរួម | 8% | 53% | 28% | 10% | 1% |
| 15 | ការរៀបចំរបាយការណ៍មានការចូលរួមពីអ្នកពាក់ព័ន្ធ | 7% | 50% | 32% | 7% | 4% |
| 16 | ផ្ញើរបាយការណ៍ជូនផ្នែកពាក់ព័ន្ធ | 6% | 50% | 26% | 15% | 4% |

តារាងទី១១៖ បទបង្ហាញរបស់អ្នកពាក់ព័ន្ធ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ប្រធានមន្ទីរ | 57 | 41% | 17% |
| 2 | លេខាធិការដ្ឋាន | 78 | 56% | 23% |
| 3 | ប្រធានPESWG | 81 | 58% | 24% |
| 4 | មន្ទីរវិស័យ | 38 | 27% | 11% |
| 5 | លេខាធិការដ្ឋាន និងESWG | 54 | 39% | 16% |
| 6 | គ្រប់ផ្នែកខាងលើ | 23 | 17% | 7% |
| 7 | ផ្សេងៗ | 7 | 5% | 2% |
| | Total | 338 | | 100% |

រូបភាពទី១២៖ ដំណើរការកិច្ចប្រជុំប្រចាំឆ្នាំ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ១ដង | 21 | 15.1 | 15.1 | 15.1 |
| | ២ដង | 24 | 17.3 | 17.3 | 32.4 |
| | ៣ដង | 45 | 32.4 | 32.4 | 64.7 |
| | ៤ដង | 46 | 33.1 | 33.1 | 97.8 |
| | មិនមាន | 2 | 1.4 | 1.4 | 99.3 |
| | ផ្សេងទៀត | 1 | 0.7 | 0.7 | 100.0 |
| | Total | 139 | 100.0 | 100.0 | |

តារាងទី១៣៖ អ្នកដឹកនាំកិច្ចប្រជុំ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | គណៈអភិបាលខេត្ត | 41 | 29.5 | 29.5 | 29.5 |
| | ប្រធានមន្ទីរអយក | 88 | 63.3 | 63.3 | 92.8 |
| | ប្រធានលេខាធិការដ្ឋាន | 7 | 5.0 | 5.0 | 97.8 |
| | ផ្សេងទៀត | 3 | 2.2 | 2.2 | 100.0 |
| | Total | 139 | 100.0 | 100.0 | |

### តារាងទី១៤៖ ផ្នែកពាក់ព័ន្ធចូលរួមកិច្ចប្រជុំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ការិយាល័យទាំងអស់នៃមន្ទីរអេយក | 95 | 68.3% | 10.9% |
| 2 | ការិយាល័យពាក់ព័ន្ធនៃមន្ទីរអេយក | 80 | 57.6% | 9.2% |
| 3 | ក្រុមP-ESWG | 100 | 71.9% | 11.5% |
| 4 | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 94 | 67.6% | 10.8% |
| 5 | ខុទ្ទការល័យសាលាខេត្ត | 54 | 38.8% | 6.2% |
| 6 | មន្ទីរផែនការ | 86 | 61.9% | 9.9% |
| 7 | មន្ទីរកិច្ចការនារី | 91 | 65.5% | 10.4% |
| 8 | មន្ទីរសុខាភិបាល | 95 | 68.3% | 10.9% |
| 9 | មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 81 | 58.3% | 9.3% |
| 10 | អង្គការមិនមែនរដ្ឋាភិបាល | 77 | 55.4% | 8.8% |
| 11 | ផ្សេងទៀត | 20 | 14.4% | 2.3% |
| | Total | 873 | | |

### តារាងទី១៥៖ សមាសភាពពាក់ព័ន្ធបានចូលរួមជាប្រចាំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើស | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | រដ្ឋបាលរាជធានីខេត្ត | 33 | 23.7% | 8.0% |
| 2 | ការិ.ទាំងអស់នៃមន្ទីរ | 84 | 60.4% | 20.4% |
| 3 | ការិ.ពាក់ព័ន្ធនៃមន្ទីរ | 76 | 54.7% | 18.4% |
| 4 | មន្ទីរពាក់ព័ន្ធទាំងអស់ | 58 | 41.7% | 14.1% |
| 5 | មន្ទីរវិស័យពាក់ព័ន្ធខ្លះ | 66 | 47.5% | 16.0% |
| 6 | ក្រុមESWG | 88 | 63.3% | 21.4% |
| 7 | ផ្សេងទៀត | 7 | 5.0% | 1.7% |
| | total | 412 | | |

តារាងទី១៦៖ ថ្នាក់ដឹកនាំបានចូលរួម

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | គណៈអភិបាលខេត្ត/ប្រធានកិត្តិយស | 33 | 23.7% | 7.6% |
| 2 | ប្រធាន/អនុប្រធានPJTWG | 107 | 77.0% | 24.7% |
| 3 | ប្រធាន/អនុប្រធានការិ.នៃមន្ទីរ | 99 | 71.2% | 22.8% |
| 4 | ប្រធាន/អនុប្រធានការិ.នៃមន្ទីរវិស័យ | 86 | 61.9% | 19.8% |
| 5 | ប្រធាន/អនុប្រធានPESWG | 66 | 47.5% | 15.2% |
| 6 | តំណាងជំនួស | 43 | 30.9% | 9.9% |
| | total | 434 | | |







**រូបភាពទី១៧៖ ការផ្ដល់យោបល់របស់សមាជិកក្នុងកិច្ចប្រជុំ រូបភាពទី១៨៖ អ្នកចូលរួមរៀបចំរបាយការណ៍ប្រជុំ**

តារាងទី១៩៖ រយៈពេលរៀបចំរបាយការណ៍

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1-3 days | 21 | 15.1 | 15.1 | 15.1 |
| | 3 days -1 week | 70 | 50.4 | 50.4 | 65.5 |
| | 1-2 weeks | 33 | 23.7 | 23.7 | 89.2 |
| | Over 2 weeks | 15 | 10.8 | 10.8 | 100.0 |
| | Total | 139 | 100.0 | 100.0 | |

តារាងទី២០៖ ខ្លឹមសារនៃរបាយការណ៍

| ល.រ | ខ្លឹមសារ | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ត្រូវកែលម្អ |
|---|---|---|---|---|---|---|
| 1 | ស្របតាមស្មារតីអង្គប្រជុំ | 8.6% | 64.0% | 17.3% | 8.6% | 1.4% |
| 2 | វត្ថុបំណង | 7.2% | 64.0% | 19.4% | 7.9% | 1.4% |
| 3 | របៀបវារៈ | 8.6% | 61.9% | 16.5% | 11.5% | 1.4% |
| 4 | ខ្លឹមសារតាមរបៀបវារៈ | 7.9% | 62.6% | 17.3% | 10.8% | 1.4% |
| 5 | បញ្ជាក់ពីចំណុចឯកភាព | 5.8% | 56.1% | 27.3% | 8.6% | 2.2% |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ប្ដូកសរុបលទ្ធផល | 10.1% | 56.8% | 21.6% | 10.1% | 1.4% |
| 7 | ទិសដៅអនុវត្តបន្ត | 7.2% | 61.9% | 19.4% | 10.1% | 1.4% |

## តារាងទី២១៖ ការចែករំលែករបាយការណ៍កិច្ចប្រជុំ

| ល.រ | ខ្លឹមសារ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ក្រសួងអយក | 82 | 59.0% | 19.2% |
| 2 | សាលារាជធានីខេត្ត | 71 | 51.1% | 16.6% |
| 3 | ប្រធានមន្ទីរ | 90 | 64.7% | 21.1% |
| 4 | ការិយាល័យពាក់ព័ន្ធ | 89 | 64.0% | 20.8% |
| 5 | ក្រុមP-ESWG | 91 | 65.5% | 21.3% |
| 6 | មន្ទីរវិស័យពាក់ព័ន្ធ | 3 | 2.2% | 0.7% |
| 7 | ផ្សេងទៀត | 1 | 0.7% | 0.2% |

## តារាងទី២២៖ បញ្ហាប្រឈមនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ការប្រជុំមិនតាមផែនការសកម្មភាពប្រចាំឆ្នាំ | 59 | 42.4% | 12.9% |
| 2 | ថ្នាក់ដឹកនាំមន្ទីរពុំមានការតាំងចិត្តខ្ពស់ | 7 | 5.0% | 1.5% |
| 3 | ការទំនាក់ទំនងរវាង មន្ទីរអយក មន្ទីរពាក់ព័ន្ធ និងក្រុមP-ESWG | 44 | 31.7% | 9.6% |
| 5 | ការផ្ដល់ធាតុចូលពីផ្នែកពាក់ព័ន្ធ | 69 | 49.6% | 15.1% |
| 6 | ថវិកាសម្រាប់ដំណើរការប្រជុំ | 47 | 33.8% | 10.3% |
| 7 | សមាសភាពចូលរួមមិនគ្រប់គ្រាន់ និងមិនមែនជាសមាជិកក្រុមការងារ | 53 | 38.1% | 11.6% |
| 8 | ភាពមមាញឹកនឹងការងាររបស់សមាជិកនៃក្រុមការងារ | 76 | 54.7% | 16.6% |
| 9 | ការកំណត់ពីតួនាទី និងការទទួលខុសត្រូវនៃក្រុម P-JTWG មិនទាន់ច្បាស់លាស់ | 22 | 15.8% | 4.8% |
| 10 | សមត្ថភាពនៃក្រុមលេខាធិកាដ្ឋាន លើការងារសម្របសម្រួល និងរៀបចំរបាយការណ៍នៅមានកម្រិត | 33 | 23.7% | 7.2% |
| 11 | ការពិនិត្យតាមដាន និងវាយតម្លៃទៅលើការអនុវត្ត | 43 | 30.9% | 9.4% |
| 12 | ផ្សេងទៀត | 5 | 3.6% | 1.1% |

តារាងទី២៣៖ដំណោះស្រាយសម្រាប់បញ្ហាប្រឈម

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | លេខាធិការដ្ឋានជំរុញថ្នាក់ដឹកនាំកំណត់ពេលវេលាប្រជុំតាមផែនការ | 77 | 55.4% | 14.2% |
| 2 | ថ្នាក់ដឹកនាំឬប្រធានអង្គភាពត្រូវមានការប្តេជ្ញាចិត្ត | 60 | 43.2% | 11.1% |
| 3 | ប្រើប្រាស់ថវិកាផ្សេងទៀតជំនួស | 34 | 24.5% | 6.3% |
| 4 | ពុំចាំបាច់មានថវិកាក៏អាចដំណើរការប្រជុំបាន | 26 | 18.7% | 4.8% |
| 5 | គៀរគរថវិកាពីដៃគូអភិវឌ្ឍន៍បន្ថែម | 61 | 43.9% | 11.3% |
| 6 | ជូនដំណឹងដល់អ្នកពាក់ព័ន្ធពីសមាសភាពចូលរួម | 86 | 61.9% | 15.9% |
| 7 | សមាជិកក្រុមការងារជាពិសេសក្រុមESWGត្រូវរំលឹកដល់លេខាធិការដ្ឋាន | 49 | 35.3% | 9.1% |
| 8 | លេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិក្រសួងអប់រំ យុវជន និងកីឡាត្រូវរំលឹក/ជំរុញដល់លេខាធិការដ្ឋាន | 32 | 23.0% | 5.9% |
| 9 | លេខាធិការដ្ឋានត្រូវពិនិត្យតាមដាន និងវាយតម្លៃ | 60 | 43.2% | 11.1% |
| 10 | ដាក់ចេញនូវវិធានការផ្សេងៗពីភាពអសកម្ម | 48 | 34.5% | 8.9% |
| 11 | ផ្សេងទៀត | 8 | 5.8% | 1.5% |
| | Total | 541 | | 100% |

តារាងទី២៤៖ សំណូមពររបស់សមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

| ល.រ | កម្រងចម្លើយ | ចំនួនជ្រើសរើសយក | %នៃការជ្រើសរើសយក | %ចម្លើយបានជ្រើសរើស |
|---|---|---|---|---|
| 1 | ក្រសួងអយកសហការជាមួយអន្តរក្រសួងពាក់ព័ន្ធ និងក្រុមការងារESWGជំរុញដល់មន្ទីរពាក់ព័ន្ធក្រោមឱវាទ និងក្រុមP-ESWG | 77 | 55.4% | 24.1% |
| 2 | រៀបចំសេចក្តីណែនាំថ្មីដោយបញ្ជាក់ពីតួនាទី និងភារកិច្ចឲ្យបានច្បាស់ | 82 | 59.0% | 25.7% |
| 3 | ពង្រឹងសមត្ថភាពលេខាធិការដ្ឋាននៃក្រុមការងារ | 75 | 54.0% | 23.5% |
| 4 | ផ្តល់ថវិកាដំណើរការប្រជុំបានគ្រប់គ្រាន់ និងទាន់ពេល | 83 | 59.7% | 26.0% |
| 5 | ផ្សេងទៀត | 2 | 1.4% | 0.6% |